ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី២១)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

លោក ម៉ាតូ គ្រីស្តារ *(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាចាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Sturart FORD)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

កញ្ញា ទី ស្រ៊ីនណា

លោក យុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

លោកស្រីអេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ជំនាញ៖** ណាយ៉ាន់ ចាន់ដា

សួរបន្តដោយ លោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ........................................................ទំព័រ ១

សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ..........................................................ទំព័រ ៥

សួរដោយ លោក ហុង គឹមសួន ផ្តើមពី ......................................................................ទំព័រ ៧

សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្តើមពី .................................................................ទំព័រ ១៩

សួរដោយ លោក ការ សាវុត្ថ ផ្តើមពី.........................................................................ទំព័រ ២០

សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី.......................................................................ទំព័រ ២៨

**សាក្សីជំនាញ** ៖ ក្រេក អេតឆេសាន់

សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ..............................................................ទំព័រ ៤១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| លោក ណាយ៉ាន់ ចាន់ដា, សាក្សី | អង់គ្លេស |
| លោក ក្រេក អេតធេសាន់ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន | បារាំង |
| លោកស្រី អេលីហ្សាប៉ែត រ៉ាបេសសាន់ដ្រាតាណា | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |
| ទ្រី ស្រ៊ីនណា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:១៥:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ដើម្បីធ្វើការពិភាក្សាដេញដោលលើអ្នកជំនាញ ណាយ៉ាន់ ចាន់ដា ពាក់ព័ន្ធជាមួយនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ។ ហើយមុននឹងចាប់ផ្តើមដំណើរ គឺក្រឡាបញ្ជីឡើងរាយការណ៍អំពីវត្តមាន និងអវត្តមានភាគី និងអ្នកត្រូវចូលរួមក្នុងដំណើរការនីតិវិធីនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមក្នុងដំណើរនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន ចំណែកឯអ្នកជំនាញក៏មានវត្តមានក្នុងបន្ទប់សវនាការផងដែរ ។

**ប្រធានអង្គជំនុំ៖**

កាលពីដំណើរការសវនាការពីម្សិលមិញ គឺបានដំណើរការប្រព្រឹត្តទៅរហូតដល់វេទិកានៃតំណាងសហព្រះរាជអាជ្ញា ឡើងធ្វើការសួរដេញដោលដល់អ្នកជំនាញ ។ ហើយតាមលទ្ធភាពនៃដំណើរម្សិលមិញគឺយើងបានធ្វើមួយចំនួនហើយ ហើយនៅមានសេសសល់នូវសំណួរមួយចំនួនទៀត ។

ដូច្នេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅឲ្យតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តសួរដេញដោលដល់អ្នកជំនាញរូបនេះជាបន្ត ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ អារុណសួស្តីលោក ចាន់ដា!

**ស៖** ប៉ុន្តែ ដំបូងខ្ញុំសូមរំឭកលោកជាមុនទៅលើបញ្ហានេះ ។ លោកបានលើកឡើងកាលពីម្សិលមិញ នៅពេលដែលលោកទៅខេត្តតាមព្រំដែននៅក្នុងខែមីនា ឆ្នាំ១៩៧៨ នៅវៀតណាម ។ លោកបានដឹងថានៅប្រាំខែដំបូងបន្ទាប់ពីខ្មែរក្រហមកាន់កាប់អំណាច បានន័យថាបន្ទាប់ពី១៧ ខែមេសា ឆ្នាំ១៩៧៥ មនុស្សជាង១៥0000នាក់ គឺបានរត់ទៅព្រំដែនវៀតណាមពីប្រទេសកម្ពុជា ។ ខ្ញុំសូមសួរលោក ថាតើលោកអាចរំឭកបានដែរឬទេ ថាតើលោកស្តាប់ឮព័ត៌មាននេះចេញពីណា? ហើយប្រភពនោះគឺចេញមកពីណា ទាក់ទងនឹងព័ត៌មានទាំងអស់នេះ?

[០៩:១៧:៤០]

**ឆ៖** តាមអ្វីដែលខ្ញុំចាំនោះ គឺព័ត៌មានដែលទទួលបានពីអាជ្ញាធរនិងមន្ទីរការបរទេសពីហូជីមិញ។ គឺមន្ត្រីនោះគាត់ទទួលបន្ទុក គាត់ធ្វើការងារជាមួយអ្នកសារព័ត៌មាន ហើយគាត់ទៅជាមួយខ្ញុំ ទៅជំរំដែលខ្ញុំទៅបានទស្សនានៅក្នុងខែមីនា ឆ្នាំ១៩៧៨ ។

**ស៖** តើលោកអាចរៀបរាប់ជំរំនោះក្នុងន័យទូទៅបានដែរឬទេ? អ្វីដែលលោកបានឃើញ ថាតើលោកមានធ្វើការសម្ភាសន៍ជាមួយនឹងមនុស្សនៅក្នុងជំរំនោះដែរឬទេ?

**ឆ៖** ជំរំដែលខ្ញុំទៅទស្សនកិច្ចនោះ គឺមានទំហំខុសៗគ្នា ធំជាងជំរំដែលជាទីតាំងយោធា ហើយទីតាំងជំរំនោះគឺវាមានលក្ខណៈធំទូលំទូលាយ ហើយមនុស្សបានកសាងខ្ទមដោយប្រើឫស្សីផ្សេងៗ និងស្លឹក ។ ហើយវាហាក់ដូចជាបង្ហាញថា អ្នកជ្រកកោនមួយចំនួនទាំងក្មេង ទាំងបុរស ទាំងស្ត្រីនោះ គឺគាត់ធ្វើការថែទាំ ឬក៏គាត់រក្សាវិន័យ និងសណ្តាប់ធ្នាប់ផ្សេងៗនៅក្នុងជំរំទាំងអស់នោះ ។ ហើយខ្ញុំបានធ្វើការសម្ភាសន៍អ្នកដែលនៅជំរំនោះមួយចំនួនតូច អ្នកទាំងអស់នោះគឺនៅពេលដែលខ្ញុំសម្ភាសន៍នោះ គឺមិនមានមន្ត្រីគាត់វត្តមាននៅទីនោះទេ ។ ហើយប្រហែលជាគេនិយាយប្រាប់ការពិតទៅលើបញ្ហានេះដោយសារមិនមានវត្តមានរបស់មន្ត្រីផ្លូវការ ។ ហើយអ្នកទាំងអស់នោះគឺគាត់រស់នៅដោយមានការភ័យខ្លាច ការមកដល់របស់រថក្រោះរបស់វៀតណាម ហើយនិងខ្មែរក្រហមគឺអនុញ្ញាតឲ្យពួកគេចាកចេញពីប្រទេសកម្ពុជានៅភូមិភាគបូព៌ា ចូលមកប្រទេសវៀតណាម ។ ហើយពួកគេមានការរីករាយក្នុងគេចចេញពីប្រទេសដើមរបស់ពួកគេ ។ ហើយអ្នកទាំងអស់នោះគឺបង្ហាញសេចក្តីសង្ឃឹមថា ពួកគាត់នឹងត្រឡប់ទៅប្រទេសកម្ពុជាវិញ នៅពេលដែលមានការរំដោះពីខ្មែរក្រហម ។ ហើយបន្ទាប់មកគឺមានការរំដោះ ។ ពួកគេបានរំពឹងទៅលើបញ្ហាហ្នឹង ហើយនិយាយថា វៀតណាមគឺជាប្រទេសតែមួយដែលអាចធ្វើការផ្តួលរំលំរបបខ្មែរក្រហម ហើយអនុញ្ញាតឲ្យពួកគេត្រឡប់ទៅប្រទេសរបស់ពួកគេវិញ ។

**ស៖** សូមលោកបញ្ជាក់ឲ្យបានច្បាស់ពីជាតិពន្ធនៃមនុស្សដែលរស់នៅក្នុងជំរំនោះ តើពួកគេជាមនុស្សដែលមានជាតិពន្ធតែមួយទេ? ឬក៏ជាមនុស្សដែលមានប្រភពមកពីជាតិពន្ធច្រើន?

**ឆ៖** ខ្ញុំមិនប្រាកដមួយរយភាគទេចំពោះអ្នកដែលខ្ញុំបាននិយាយមួយចំនួននោះ។ ប៉ុន្តែ ភាគច្រើនគេមើលទៅដូចជាជនជាតិខ្មែរ ។ ហើយសម្ភាសន៍នោះគឺធ្វើឡើងតាមរយៈអ្នកបកប្រែខ្មែរ-អង់គ្លេស ។

**ស៖** លោកបាននិយាយថាជំរំហ្នឹងមានទំហំផ្សេងៗគ្នា ហើយដូច្នេះប្រហែលជាពិបាកនៅពេលដែលយើងត្រឡប់និយាយអំពីចំណុចនោះ ។ តើពេលនុ៎ងគឺថាមានអ្នកភៀសខ្លួនចំនួនប៉ុន្មាន? ប្អូនដប់

នាក់ ឬក៏រាប់រយនាក់ ឬក៏ច្រើននាក់?

[០៩:២២:១១]

**ឆ៖** បាទ, គឺមានរាប់ពាន់នាក់ ។

**ស៖** អ៊ីចឹង ខ្ញុំចង់និយាយទៅចំណុចមួយ ដែលលោកបាននិយាយប្រាប់បញ្ជាក់ទៅលោកស្រីចៅក្រម ខាតរ៉ាយថ៌ កាលពីម្សិលមិញ ។ លោកបានពិភាក្សាអំពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះអ្នកជាប់ទោស ឬក៏អ្នកដែលគេចាប់បាននៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធនោះ ។ ខ្ញុំចង់ឲ្យលោកធ្វើការបញ្ជាក់បន្ថែមទៀតទៅលើចំណុចដែលលោកបាននិយាយថា ជាទូទៅ បើសិនជាការកត់សម្គាល់របស់ខ្ញុំត្រឹមត្រូវនោះ មានន័យថាគោលនយោបាយរបស់គេ គឺគេមិនទទួលយកនូវឈ្លើយសឹកទេ ។ តើលោកអាចពន្យល់ប្រាប់ទេ តើនរណាគេ ឬក៏អ្វីទៅជាប្រភពរបស់លោកក្នុងការបញ្ជាក់អំពីចំណុច ហើយតើខ្មែរក្រហមមានហេតុផលអ្វីក្នុងការមិនទទួលអ្នកទោសជាឈ្លើយសឹកសង្គ្រាមនោះ?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ច្បាស់លាស់ពីប្រភពទៅលើការអង្កេតរបស់ខ្ញុំនោះទេ ។ នេះគឺជាអ្វីដែលយើងបានយល់ដឹងបន្ទាប់ពីយើងបានពិនិត្យមើលឃើញផ្ទាល់អំពីការវាយប្រហាររបស់ខ្មែរក្រហម ហើយនិងព្រឹត្តិការណ៍ក្រោយពីការវាយប្រហារនោះមក ។ នៅពេលដែលខ្មែរក្រហមចាប់អ្នកទោសបាន ភាគច្រើនបំផុតនោះគេនឹងធ្វើការចាក់ផ្សាយតាមវិទ្យុនៅទីក្រុងភ្នំពេញ ។ ដោយគេធ្វើការបញ្ជាក់ថា ឥឡូវនេះនៅក្នុងដៃរបស់យើងគឺ មានអ្នកដែលយើងចាប់ ដែលជាអំពើឈ្លានពានរបស់ប្រទេសនោះ ។ ប៉ុន្តែរបាយការណ៍ប្រភេទនេះទៅតាមការចងចាំរបស់ខ្ញុំ គឺវាមានមិនច្រើនប៉ុន្មានទេ ។ ក៏ប៉ុន្តែ យើងបានដឹងថា មានការវាយប្រហារដ៏ច្រើនរបស់ខ្មែរក្រហមនៅតាមតំបន់ព្រំដែនជាមួយវៀតណាមនៅក្នុងអំឡុងពេលនោះ ។ អ៊ីចឹងដោយយើងពិនិត្យមើលថា មិនមានឃើញអ្នកទោសច្រើន ដែលត្រូវបានរាយការណ៍ ហើយចាក់ផ្សាយនោះ និងសំដៅទៅលើភាពឃោរឃៅជាទូទៅរបស់ពួកគេ ដែលយើងបានឃើញក្រោយពីការវាយប្រហារនោះ ។ នោះហើយគឺជាការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ។

**ស៖** លោកបាននិយាយអំពីការចាក់ផ្សាយតាមវិទ្យុ ហើយក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រមកាលពីម្សិលមិញ បើសិនជាការកត់សម្គាល់របស់ខ្ញុំមិនត្រឹមត្រូវទេ សូមប្រាប់ឲ្យខ្ញុំដឹងផង ។ ជាទូទៅ អ្នកទោសហ្នឹងគឺថាគេមិនចាប់យកមកទេ លើកលែងតែអ្នកនុំងមានអត្ថប្រយោជន៍សំខាន់ ។ តើលោកអាចបញ្ជាក់បានទេ តើអ្នកទោសប្រភេទណាទៅជាអ្នកទោសដែលមានអត្ថប្រយោជន៍នោះ?

[០៩:២៥:០៩]

**ឆ៖** តាមការគិតរបស់ខ្ញុំ អ្នកដែលគេចាប់មកជាឈ្លើយសង្គ្រាមនោះ គឺពួកខ្មែរក្រហមគិតថា ពួកគេហ្នឹងឯងមានឋានៈនៅក្នុងជួរ ដែលមានព័ត៌មានច្រើនសម្រាប់ពួកគេ ។ ដែលមានន័យថាពួកគេជានាយទាហាន មិនមែនជាទាហានសាមញ្ញធម្មតានោះទេ ។ ហើយប្រសិនបើការចងចាំរបស់ខ្ញុំត្រឹមត្រូវនោះ នៅពេលដែលខ្ញុំបានអានប្រតិចារឹកនៃការចាក់ផ្សាយវិទ្យុនៅទីក្រុងភ្នំពេញ និយាយអំពីឈ្លើយសឹកសង្គ្រាមវៀតណាម គឺគេមានផ្តល់អំពីឋានៈរបស់ទាហាននោះ ។ ប៉ុន្តែ ខ្ញុំមិនដឹងថាតើឋានៈរបស់គេនោះត្រឹមត្រូវ ឬក៏អត់ទេ ខ្ញុំមិនអាចនិយាយបានទេ ។ ប៉ុន្តែ កម្រមានការបង្ហាញអំពីឈ្មោះអ្នកទោស ដែលជាទាហានធម្មតាណាស់ ។

**ស៖** តើលោកមានបានធ្វើការកត់សម្គាល់អ្វីជាក់លាក់ទេ អំពីអត្ថន័យនៃការចាក់ផ្សាយអំពីការសារភាពរបស់ទាហានវៀតណាមដែលមានឋានៈនោះ? តើគេមានគោលបំណងអ្វីទៅ?

**ឆ៖** ជាថ្មីម្តងទៀត ខ្ញុំសូមធ្វើការសារភាពថា ខ្ញុំមិនមានការចងចាំឲ្យបានជាក់លាក់អំពីចំណុចនោះទេពីព្រោះពេលវេលាកន្លងទៅរាប់សិបឆ្នាំមកហើយ ។ ការចងចាំរបស់ខ្ញុំគឺថា មិនមានតម្លៃអ្វីទេនោះគឺគ្រាន់តែបង្ហាញថានោះគឺជាបុគ្គលិកយោធារបស់វៀតណាម ហើយដែលថាវៀតណាមហ្នឹងឯងគឺថាមានបំណងឈ្លានពានកម្ពុជា ។ នេះគេធ្វើដើម្បីពង្រឹងគោលជំហររបស់ខ្លួន ដែលថាវៀតណាមមានបំណងចង់លេបយកទឹកដីរបស់ខ្មែរនោះ ប៉ុន្តែ មិនមានព័ត៌មានណាជាក់លាក់ដែលត្រូវបានផ្តល់ទៅឲ្យសាធារណជននោះទេ ។

**ស៖** ប្រធានបទចុងក្រោយនៃសំណួររបស់ខ្ញុំ គឺនិយាយអំពីចំណុចដែលយើងបាននិយាយអំពីការវាយប្រហារគ្នាកាលពីម្សិលមិញនោះ ។ សំណួររបស់ខ្ញុំគឺថា បន្ទាប់ពីការវាយប្រហារលើកទីមួយរបស់វៀតណាមនិងកម្ពុជានោះ នៅលើកោះកាលពីឆ្នាំ៧៥ ហើយរហូតដល់ពេលមានការវាយប្រហារទ្រង់ទ្រាយធំរបស់វៀតណាមចូលមកទឹកដីកម្ពុជា នៅឆ្នាំ៧៨នោះ គឺនៅចុងឆ្នាំ៧៨នោះ តើមានព្រឹត្តិការណ៍អ្វីផ្សេងទៀតដែលយើងអាចចាត់ទុកថាជាការសន្និដ្ឋានអំពីដំណាក់កាល ឬក៏អំឡុងពេលសន្តិសុខរវាងសន្តិភាពរវាងវៀតណាម និងកម្ពុជាទេ?

**ឆ៖** ខ្ញុំមិនមានការចងចាំអំពីកិច្ចព្រមព្រៀងសន្តិភាពអ្វីទេ លើកលែងតែការចាត់ចែងក្នុងមូលដ្ឋានមួយចំនួនតូចដែលខ្ញុំបានដឹងពីប្រភពរបស់វៀតណាម ដែលដូចជាមានការអៀនខ្មាសបន្តិចចំពោះកិច្ចព្រមព្រៀងរវាងមន្ត្រីថ្នាក់ខេត្តនៅខាងភាគីវៀតណាម និងជាមួយខ្មែរក្រហមក្នុងការយកទៅវិញ

មនុស្សដែលបានភៀសខ្លួនពីកម្ពុជាទៅវៀតណាមប៉ុន្មានខែ បន្ទាប់ពីខាងខ្មែរក្រហមមានជោគជ័យជម្នះនោះ ។ ហើយជាញឹកញាប់ណាស់ ជនអស់ទាំងនោះត្រូវបានបញ្ជូនទៅវិញ ដែលជាជនជាតិខ្មែរ ឬក៏ចាម ឬក៏អ្នកដែលមិនមែនជាជនវៀតណាម ។ ហើយពួកគេបញ្ជូនមនុស្សនោះត្រឡប់មកជាការផ្លាស់ប្តូរជាមួយនឹងសត្វពាហនៈ ឬក៏វត្ថុអ្វីផ្សេង ។ នៅអំឡុងពេលនៃការប្រគល់អ្នកដែលបានគេចខ្លួនពីកម្ពុជាមកឲ្យកម្ពុជាវិញ នោះគឺជាអ្វីដែលខ្ញុំចងចាំអំពីការរៀបចំតាមមូលដ្ឋានទាក់ទងទៅនឹងកិច្ចព្រមព្រៀងសន្តិភាព ហើយនឹងការប្រគល់អ្នកដែលបានភៀសខ្លួននោះឲ្យមកកម្ពុជាវិញ ។

**ស៖** ក្រៅពីកិច្ចព្រមព្រៀងតាមមូលដ្ឋានបែបនេះ តើលោកអាចចងចាំអំពីគោលនយោបាយជាផ្លូវការអ្វីទេ? គឺកិច្ចព្រមព្រៀងជាផ្លូវការរវាងប្រទេសទាំងពីរនេះទាក់ទងនឹងការចរចាសន្តិភាពនោះ ។

[០៩:៣០:០០]

**ឆ៖** មិនមានទេ ប៉ុន្តែគឺមានការព្យាយាមជាច្រើននិងទស្សនកិច្ចជាច្រើនរបស់ប្រទេសវៀតណាមមកភ្នំពេញនៅឆ្នាំ៧៥ ហើយក៏មានធ្វើដែរនៅឆ្នាំ៧៦ ។ ប៉ុន្តែការព្យាយាមអត់ទាំងនុ៎ងគឺមិនបណ្តាលឲ្យមានដំណោះស្រាយជាផ្លូវការសម្រាប់រយៈពេលខ្លីណាមួយនោះទេ ។ តាមការចងចាំរបស់ខ្ញុំ គឺថាមិនច្បាស់លាស់ទេត្រង់ចំណុចនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោក ចាន់ដា ។ លោកប្រធាន បន្ទាប់មកទៀតគឺថាសហព្រះរាជអាជ្ញានឹងសូមដាក់ជូនឯកសារមួយចំនួនទៅអង្គសវនាការ គឺថាដើម្បីធ្វើឲ្យមានការចំណេញពេលក្នុងការសាកសួរដល់សាក្សីម្នាក់នេះ ។ ប៉ុន្តែ នៅពេលបន្ទាប់មកទៀតនោះ គឺខាងសហព្រះរាជអាជ្ញានឹងចង់ធ្វើការដាក់ជូននូវឯកសារមួយចំនួនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ខ្ញុំចង់លើកនិយាយឡើងវិញពីចំណុចមួយ លោកបានបង្ហាញប្រាប់យើងឲ្យបានដឹងថា មានកិច្ចព្រមព្រៀងតាមមូលដ្ឋាន តាមតំបន់មួយចំនួន ហើយខ្ញុំមិនដឹងជាពាក្យជាផ្លូវការជាអីនោះទេ ប៉ុន្តែគឺថាកិច្ចព្រមព្រៀងនោះដើម្បីឲ្យមានការបញ្ជូនត្រឡប់មកវិញ នូវអ្នកដែលបានភៀសខ្លួនទៅជ្រកកោននៅប្រទេសវៀតណាម ។ ហើយឥឡូវនេះគឺយើងនិយាយអំពីជាតិពន្ធ ចាម តើនេះជាអ្វីដែលខ្ញុំយល់ដឹងត្រឹម

ត្រូវទេ? តើលោកអាចប្រាប់យើងបានទេ ថាលោកមានប្រភពច្បាស់លាស់ទេក្នុងការបង្ហាញអំពីសេចក្តីថ្លែងការណ៍មួយនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព ខ្ញុំមិនចាំព័ត៌មានពិស្តារនោះទេ ប៉ុន្តែខ្ញុំចាំថា ខ្ញុំបានលើកអំពីអង្គហេតុនេះ អំពីការបញ្ជូនឲ្យមកប្រទេសវិញដោយបង្ខំនូវជនជាតិខ្មែរពីប្រទេសវៀតណាមនៅក្នុងសៀវ-ភៅរបស់ខ្ញុំ ។ បើសិនជាលោកចៅក្រមអនុញ្ញាត ខ្ញុំនឹងអាចពិនិត្យមើលទៅលើឯកសារយោងដែលខ្ញុំបានប្រើក្នុងការសរសេរចំណុចនេះនៅក្នុងសៀវភៅរបស់ខ្ញុំ ។

[០៩:៣៤:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ្វីដែលយើងអាចធ្វើបាននៅក្នុងអំឡុងពេលនៃសវនាការនេះ គឺលោកអាចនឹងផ្តល់លេខយោង ឬក៏ឯកសារយោងមកឲ្យយើងនៅពេលក្រោយ ពីព្រោះអីពេលវេលាគឺមានតម្លៃណាស់សម្រាប់យើងនៅពេលនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

ខ្ញុំមិនដឹងថា អ្វីដែលខ្ញុំនឹងអាចលើកមកនេះអាចជួយដល់លោកចៅក្រមបានទេ ប៉ុន្តែឯកសារយោងនៅក្នុងសៀវភៅរបស់លោក ចាន់ដា នៅទំព័រ៨៥ ជាភាសាអង់គ្លេសនោះ ។ ហើយដែលមានលេខ ERN00192270 គឺប្រហែលជានៅពាក់កណ្តាលចុះក្រោមនៃទំព័រមានការលើកឡើងអំពីការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនខ្មែរដែលបានភៀសខ្លួនទៅប្រទេសវៀតណាមក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនោះ ហើយដែលមានកំណត់សម្គាល់ចុងទំព័រលេខ១៩ គឺនៅខាងក្រោយសៀវភៅជាភាសាអង់គ្លេសនៅទំព័រ៤២៣ ដែលមានលេខ ERN ជាភាសាអង់គ្លេស 00192608 ។

ខ្ញុំសូមទោសដែលខ្ញុំឡើងឈរម្តងទៀត ប៉ុន្តែ គឺមានឯកសារយោងបន្ថែមទៀតនៅក្នុងសៀវភៅដែលជាក់លាក់ទាក់ទងទៅនឹងការផ្លាស់ប្តូរសត្វពាហនៈ គឺមាននៅទំព័រ៨៥ ជាភាសាអង់គ្លេស ដែលមានលេខ ERN00192270 ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាមានបំណងចង់លើកឡើងពីបញ្ហាអ្វី?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំសូមទោសលោកប្រធាន សូមទោសដែលខ្ញុំបានធ្វើការអង្កេតនេះ គឺអ្វីដែលខ្ញុំក្រោកឈរឡើង គឺទាក់ទងទៅនឹងអ្វីដែលលោកចៅក្រម ឡាវ៉ែន៍ បានលើកស្នើទៅខាងសាក្សីទាក់ទងទៅនឹងប្រភពនៃការផ្លាស់ប្តូរគ្នាក្នុងការធ្វើមាតុភូមិនិវត្តន៍កម្ពុជាមកវិញ ។ ហើយខ្ញុំបានចង្អុលបង្ហាញនូវទំព័រ៨៥ នៃភាសាអង់គ្លេស គឺមានលេខយោងចុងទំព័រលេខ១៩ និង២០ ។

[០៩:៣៩:៤៨]

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ឡាវ៉ែន៍ មានអ្វីចង់បន្ថែមទៀតទេ?

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះជូនទៅដល់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឡើងសំណួរពាក់ព័ន្ធជាមួយនឹងអ្នកជំនាញរូបនេះ ។ ហើយដោយសារកាលមុនយើងមានការផ្លាស់ប្តូរកម្មវិធី អ៊ីចឹងគឺសូមពីក្រុមបួនមុន ដើម្បីឲ្យមានស្មើភាពគ្នារវាងក្រុមទាំងបួន ។

សូមអញ្ជើញមេធាវី ហុង គឹមសួន ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធាន ខ្ញុំបាទសូមគោរពលោកប្រធានក្រុម ប្រធានអង្គជំនុំជម្រះ លោកស្រី លោកចៅក្រម និងអង្គសវនាការជាទីគោរព ។ ខ្ញុំបាទមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីដែលមានលោក ព្យែរ អូលីវីយេស័រ ជាសមាជិករបស់ខ្ញុំបាទដែលគាត់អវត្តមាន ។ ខ្ញុំបាទមានសំណួរខ្លះៗសួរទៅលោក ណាយ៉ាន់ ចាន់ដា ដូចតទៅនេះ ។ ហើយក៏សូមអនុញ្ញាតលោកប្រធានផងដែរ ដោយនេះទាក់ទិនដំបូងគេ គឺខ្ញុំបាទចង់សួរអំពីការចងក្រងជាឯកសាររបស់លោក ណាយ៉ាន់ ចាន់ដា ។ ខ្ញុំមើលជាភាសាខ្មែរសរសេរថា “សត្រូវបងប្អូនឯង” ខ្ញុំចង់បានជាការពន្យល់គាត់បន្តិចថា មានន័យយ៉ាងដំម៉េចទៅ សត្រូវហើយបងប្អូនឯង ។ ក្នុងនេះខ្ញុំបាទចង់ដឹងថា ដោយសារយើងកំពុងសវនាការផ្តោតអារម្មណ៍ទៅលើជម្លោះប្រដាប់អាវុធរវាងវៀតណាមនិងកម្ពុជា ហើយក៏វាទាក់ទងជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាជននៅក្នុងប្រទេសផងដែរ ។

អ៊ីចឹងសូមឲ្យលោកមានប្រសាសន៍បន្តិចទាក់ទងនឹងពាក្យថា“សត្រូវបងប្អូនឯង”,សូមអញ្ជើញ ។

**ឆ៖** សូមអរគុណចំពោះសំណួរនេះ ខ្ញុំជ្រើសរើសយកចំណងជើងនេះ គឺដើម្បីកំណត់ថាកំណត់អំពីទំនាក់ទំនងរវាងបក្សកម្ពុជា និងបក្សវៀតណាម ។ ហើយក៏បង្ហាញអំពីទំនាក់ទំនងរវាងប្រទេសចិន

និងកម្ពុជាផងដែរ ។ ហើយទំនាក់ទំនងនេះមានលក្ខណៈជ្រាលជ្រៅណាស់នៅពេលមួយនោះ ហើយការឃោសនាបក្សនោះ គឺតែងនិយាយអំពីភាតរភាពរវាងគ្នានៅក្នុងបក្ស ។ ហើយទាំងវៀតណាម និងចិន គឺបានធ្វើការវាយលុកក្នុងសង្គ្រាមក្នុងឆ្នាំ១៩៧៩ ហើយវៀតណាមនិងខ្មែរធ្វើការវាយគ្នាទៅវិញទៅមក នៅតាមព្រំដែននៅក្នុងឆ្នាំ៧៨ និង៧៩ ។

[០៩:៤៣:២០]

កាលពីមុនក៏គេជាបងប្អូន ក្រោយមកជាសត្រូវ ។ ដូច្នេះហើយ គឺវាបង្ហាញអំពីទំនាក់ទំនងរវាងគ្នានឹងគ្នានេះ ។ ដូច្នេះទើបខ្ញុំជ្រើសរើសយកចំណងជើងនេះ ។

**ស៖** សូមអរគុណ ។ សំណួរទីពីរ ក៏ទាក់ទងនឹងចំណងជើងនៃសៀវភៅរបស់លោកដែរ ។ បើតាមខ្ញុំបាទស្តាប់លោកមានប្រសាសន៍អម្បាញ់មិញ គឺចាត់ទុកការរួមសមភាពគ្នារវាងបក្សកុម្មុយនីស្តចិន បក្សកុម្មុយនីស្តវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជា ទើបហៅថា “ជាបងប្អូន” ។ ក្នុងសៀវភៅរបស់លោកបានសរសេរជាច្រើន ខ្ញុំបាទមិនលើកឲ្យវែងឆ្ងាយទេ ទាក់ទងនឹងពាក្យថាជាបងប្អូននោះ ។ តែរឿងបង្កើតបក្សកុម្មុយនីស្ត ហើយរួមកម្លាំងគ្នាតែប៉ុណ្ណោះ ឬក៏ទាក់ទងនឹងប្រវត្តិសាស្ត្រ ជាតិសាសន៍ចិន ជាតិសាសន៍វៀតណាម ជាតិសាសន៍កម្ពុជា ហៅថា ដើមកំណើតជាបងប្អូនដែរឬក៏គ្រាន់តែជាសមមិត្តនឹងគ្នាក្នុងបក្សកុម្មុយនីស្តតែប៉ុណ្ណោះ?

[០៩:៤៤:៥៤]

**ឆ៖** ខ្ញុំជ្រើសរើសចំណងជើងដាក់លាក់ដោយវាទាក់ទងទៅនឹងបក្សកុម្មុយនីស្តវៀតណាម ចិន និងវៀតណាម គឺខ្ញុំសំដៅលើប្រជាជាតិនៃប្រទេសនេះ បក្សទាំងអស់នេះ ។ អ៊ីចឹង គឺវាបង្ហាញអំពីទំនាក់ទំនងរវាងប្រទេសទាំងអស់នេះ ហើយភាគច្រើនពួកគេៗមានភាពជិតស្និតនិងមានសន្តិភាព ។ ប៉ុន្តែមានពេលមួយនោះ ដែលទំនាក់ទំនងនោះត្រូវបានបែកបាក់ ។ ប៉ុន្តែ នេះមិនមែនអ្វីខ្ញុំគិតនៅក្នុងចិត្តនៅពេលដែលខ្ញុំជ្រើសរើសដាក់ចំណងជើងថា “ជាសត្រូវបងប្អូនឯង” នោះទេ ។

**ស៖** សំណួររបស់ខ្ញុំបន្តទៅទៀត ទាក់ទងជាមួយនឹងពេលវេលាកើតឡើងឲ្យមានជម្លោះ ឬមានសង្គ្រាមរវាងគ្នានិងគ្នា ជាពិសេសគឺរវាងបក្សកុម្មុយនីស្តវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ បើក្នុងសៀវភៅរបស់លោកនៅក្នុងទំព័រទី៥ ជាភាសាខ្មែរ ហើយនៅក្នុងនេះមានលេខ ERN ដែរ 00191310 នៅក្នុងឯកសារ D91/1 ។ នៅក្នុងកថាខណ្ឌទី២ ទាក់ទងនឹងឯកសាររបស់លោកនេះ សរសេរអំពីសង្គ្រាមឥណ្ឌូចិនលើកទីពីរស្ទើតែមិនទាន់ចប់ស្រួលបួលផង ។ សង្គ្រាមទីបី ក៏ប្រុងនឹងកើត

មានក្នុងពេលឆាប់ៗតែម្តង គឺសង្គ្រាមរវាងបងប្អូននិងបងប្អូន រវាងសមមិត្តនិងសមមិត្ត ។ ក្នុងន័យនេះមានពីរ អម្បាញ់មិញ ខ្ញុំសួរលោកអំពីពាក្យថា បងប្អូន ចុះពាក្យសមមិត្តនិងសមមិត្ត តើសំដៅលើផ្ទៃក្នុងកម្ពុជាប្រជាធិបតេយ្យ ឬសមមិត្តរវាងបក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្តវៀតណាម?

**ឆ៖** ខ្ញុំប្រើពាក្យសមមិត្តនេះគឺដើម្បីកំណត់ថា ពួកគេជាជនកុម្មុយនីស្ត ។

**ស៖** សូមអរគុណ ។ ទាក់ទងនឹងជម្លោះ ខ្ញុំឈានចូលមកដល់ ទាក់ទងនឹងបក្សកុម្មុយនីស្តវៀតណាមនិងកម្ពុជាដដែល ដែលនាំឲ្យមានការប៉ះទង្គិចគ្នាប្រដាប់អាវុធធ្ងន់ធ្ងរពីរលើកធំៗ ។ ក្នុងការស្រាវជ្រាវរបស់លោក ព្រោះលោកបានរស់នៅទីក្រុងព្រៃនគរ ឬទីក្រុងសៃហ្គន ដែលសព្វថ្ងៃហៅថាទីក្រុងហូជីមិញ មុនបក្សកុម្មុយនីស្តវៀតណាមវាយរំដោះយកវៀតណាមខាងត្បូងបាន ។ តើការស្រាវជ្រាវរបស់លោកនៅក្នុងឆ្នាំ១៩៧២និងឆ្នាំ១៩៧៣ ពីម្សិលមិញលោកបានលើកឡើងបន្តិច ខ្ញុំគ្រាន់តែលើកឡើងវិញបន្តិច ដើម្បីឲ្យភ្ជាប់គ្នាជាមួយនឹងសំណួរថ្ងៃនេះ ។ ជម្លោះរវាងកងទ័ពវៀតណាមដែលនៅក្នុងប្រទេសកម្ពុជា ហើយដែលម្សិលមិញលោកបានលើកអំពី ពេលនោះខាងសហរដ្ឋអាមេរិកមានទំនាក់ទំនងជាមួយនឹងវៀតណាម ឬបក្សកុម្មុយនីស្តវៀតណាម ដើម្បីចរចាជាមួយនឹងពួកខ្មែរក្រហមឲ្យមានសន្តិភាព ។ អ៊ីចឹង ពេលណាដែលខ្មែរក្រហមមិនយល់ព្រមជាមួយនឹងការចចារនោះ តើជម្លោះនៅក្នុងពេលដែលខ្មែរក្រហម ឬបក្សកុម្មុយនីស្តកម្ពុជាវាយដួលរបបលោក លន់ នល់ ហើយកើតសង្គ្រាម ឬកើតការប្រទូស្តរ៉ាយគ្នាជាមួយនឹងវៀតណាមហ្នឹង វាមានទំនាក់ទំនងតពីឆ្នាំ១៩៧២ ឬ១៩៧៣ ដែរឬទេ?

[០៩:៤៩:៥០]

**ឆ៖** ជាការពិត ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញរួចមកហើយ ដោយសារតែសង្គ្រាមឥណ្ឌូចិនលើកទី១ ដែលបក្សកុម្មុយនីស្តឥណ្ឌូចិនបែកបាក់ ហើយបង្កើតជាបក្សបី នៅពេលដែលសង្គ្រាមបានបញ្ចប់នៅក្នុងសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ គឺយើងឃើញមានបក្សកុម្មុយនីស្តផ្សេងៗ ហើយគឺមានការលើកឡើងអំពីបញ្ហាផ្សេងៗនៅក្នុងសន្និសីទ ។ ហើយគឺយើងឃើញមានការលើកឡើងអំពីការវាយនឹងពួកចក្រពត្តិ ហើយរដ្ឋាភិបាលវៀតណាម ពួកអាណានិគម ហើយគឺឲ្យមានការចូលទៅហាណូយដើម្បីនៅទីនោះ កម្មាភិបាលពីរពាន់នាក់ឲ្យទៅហាណូយហើយនៅទីនោះ ។ ហើយជនកុម្មុយនីស្តមិនមែនទាំងអស់ទេគឺវាមានមួយចំនួន ហើយមានសង្គ្រាមដែលមានលើកឡើងនៅក្នុងឯកសារខ្មែរក្រហម។

នៅក្នុងឆ្នាំ១៩៧៣ គឺកិច្ចចរចាសន្តិភាពបានបញ្ចប់រវាងវៀតណាមនិងសហរដ្ឋអាមេរិក ។ នៅពេលនោះរដ្ឋាភិបាលសហរដ្ឋអាមេរិកបានដាក់សម្ពាធទៅវៀតណាម ដើម្បីឲ្យទៅទាក់ទងនិងនាំយកខ្មែរ

ក្រហមមកធ្វើការចរចា ។ ហើយខ្ញុំបានចាំនូវឯកសារមួយនៅក្នុងកំណត់ហេតុ *មេម៉រ* របស់ ឃីស៊ីងជឹ លោក ឃីស៊ីងជឹ បានសារភាពថា គាត់មិនបានធ្វើការគិតដល់ឯករាជ្យភាពរបស់វៀតណាមនិងកម្ពុជានោះទេ ។ ហើយវៀតណាមបានប្រាប់លោក ឃី ស៊ីងជឹ ថា គឺគេមិនអាចនាំយកខ្មែរក្រហមមកធ្វើការចរចានោះទេ ។

ដូច្នេះ ឃី ស៊ីងជឹ គឺមានការសង្ស័យទៅលើបញ្ហានេះ នៅពេលដែលគាត់សរសេរ *មេម៉រ* នៅពេលនោះ គឺគាត់បានយល់ថា ខ្មែរក្រហមមិនចង់ចូលរួមនៅក្នុងកិច្ចចរចាសន្តិភាពនោះទេ ។ ដែលថានៅពេលការចរចានោះ ដើម្បីឲ្យមានដំណោះស្រាយរវាងខ្មែរក្រហម និង លន់ នល់ ។ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោក គឺថាវាមាន គឺវាមានកេរដំណែល និងផលចេញពីសង្គ្រាមនោះមែន ដែលមានបណ្តាលឲ្យមានជម្លោះនោះ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង តពីសំណួរហ្នឹងទៀត ខ្ញុំបាទសូមសួរលោកថា នៅពេលដែលខ្មែរក្រហមមិនព្រមជាមួយនឹងការសម្រុះសម្រួលរបស់សហរដ្ឋអាមេរិកជាមួយនឹងវៀតណាម ដែលចរចាជាមួយខ្មែរក្រហមហើយនោះ នៅក្នុងពេលនោះកងទ័ពបក្សកុម្មុយនីស្តវៀតណាម ដែលនៅក្នុងទឹកកម្ពុជាមានជម្លោះ ឬមានការបណ្តេញ មានន័យថា ខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយនឹងទ័ពវៀតណាមនៅក្នុងឆ្នាំនោះបណ្តេញចេញពីប្រទេសកម្ពុជាដែរឬទេ?

[០៩:៥៣:៣៤]

**ឆ៖** ខ្ញុំមិនដឹងទេ ហើយខ្ញុំមិនអាចប្រើពាក្យថា បណ្តេញចេញនោះទេ គឺខ្ញុំប្រើពាក្យថា "បង្ខំ"។ ខ្ញុំគិតថាវៀតណាម គឺមិនចង់នោះទេ ដោយសារតែពួកគេធ្វើការវ៉ៃទៅ លន់ នល់ នៅក្នុងឆ្នាំ១៩៧១ ។ ដូច្នេះគឺអាចមានការដកចេញដោយខ្លួនឯងចំពោះវៀតណាមនោះ ។

អ្នកដែលអាណិតអាសូរនិងស្មោះស្ម័គ្រទៅនឹងវៀតណាម គឺនៅក្នុងប្រទេសកម្ពុជា ហើយអ្នកទាំងអស់ដែលនៅប្រទេសកម្ពុជានោះត្រូវបានគេសម្លាប់ចោល ។ ហើយដូចដែលចៅក្រម ឡាវែន៍ បានសួរខ្ញុំកាលពីម្សិលមិញ អំពីភស្តុតាង អំពីការសម្លាប់ជនជាតិវៀតណាមក្នុងឆ្នាំ១៩៧២ និង៧៣ នោះគឺខ្ញុំរកឃើញឯកសារយោងមួយនៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ ដែលនិយាយអំពីសំឡេងចេញពីស-២១ ។ ហើយប្រសិនបើអនុញ្ញាតលោកប្រធាន ខ្ញុំសូមអានកថាខណ្ឌ មួយកថាខណ្ឌពីសៀវភៅនោះ ដែលវាពាក់ព័ន្ធទៅនឹងសំណួរមួយនេះ ។

លោក ដេវីដ ឆេនដ៍ល័រ បានសរសេរថា ជនជាប់ចោទ បានបង្កើតសញ្ញាណរបស់គាត់នៅក្នុង

ការយល់អំពីខ្មែរក្បត់នៅក្នុងឆ្នាំ១៩៧២និង៧៣ ។ នៅពេលដែលប្រតិបត្តិការសម្លាប់ត្រូវបានបង្កើតឡើងដោយពួកខ្មែរក្រហម ដើម្បីធ្វើវិសុទ្ធកម្មក្រុមដែលហៅថា ខ្មែរហាណូយ ខ្មែរដែលមកពីភាគខាងត្បូងនៃប្រទេសកម្ពុជាឆ្នាំ១៩៧០ បន្ទាប់ពីការនិរទេសខ្លួនឯងទៅប្រទេសវៀតណាមខាងជើង អស់រយៈពេលជាច្រើនឆ្នាំក្នុងរូបភាពជួយបដិវត្តន៍ ។ សមាជិកក្រុមនេះ រាប់រយនាក់ត្រូវបានចាប់ខ្លួនជាសម្ងាត់ និងយកទៅសម្លាប់ចោលក្នុងឆ្នាំ១៩៧៣ បន្ទាប់ពីវៀតណាមដកទ័ពរបស់ខ្លួនទាំងស្រុងចេញពីកម្ពុជា សមាជិកនៅសេសសល់ពីរបីនាក់ បានសម្រេចជោគជ័យក្នុងការគេចខ្លួនទៅប្រទេសវៀតណាម បន្ទាប់ពីការជាប់ឃុំឃាំង ហើយសមាជិកដទៃទៀតត្រូវបានចាប់ខ្លួនបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ។ សមាជិកភាគច្រើននៃក្រុមនេះត្រូវបានចាប់ខ្លួននៅភូមិភាគពិសេស ។ ភាពដាច់ខាត និងភាពគ្មានមេត្តា នៃយុទ្ធនាការធ្វើវិសុទ្ធកម្មនេះ មានការទាក់ទងជាមួយនឹងរបៀបគ្រប់គ្រងរដ្ឋបាលរបស់ ឌុច ដែលតាមពិតយុទ្ធនាការនេះបង្ហាញអំពីដំណើរដូចគ្នានឹងព្រឹត្តបត្រប្រព្រឹត្តទៅនៅមន្ទីរស-២១ ។ នេះជាសៀវភៅ ជាការដកស្រង់នៅទំព័រ២១ និង២២ នៃអត្ថបទសៀវភៅចំណងជើងថា "សំឡេងចេញពីស-២១" ។

**ស៖** សូមអរគុណ ។ បន្តទៅទៀត ខ្ញុំសួរលោកទាក់ទងពី ក្រោយពេលដែលមានជម្លោះ នៅក្នុងឆ្នាំ (សុំទោស) លោកបានបញ្ជាក់ហើយថា ជាការបង្ខំដោយខ្មែរក្រហមដេញកងទ័ពខាងវៀតណាមនៅក្នុងឆ្នាំ៧៣ហើយនោះ ។ ក្នុងអំឡុងនោះ ឬបើខ្ញុំមិនចាំច្បាស់ទេ ឬក៏មុនឆ្នាំ១៩៧០ ទៅទៀត ខ្ញុំមិនចាំទំព័រ ទាក់ទងជាមួយនឹងការព្រមព្រៀង ខ្ញុំមិនប្រាកដទេថាតើជាសន្ធិសញ្ញា ឬការព្រមព្រៀង ឬការសន្យាគ្នា ។ តើលោកបានដឹងទេថា រវាងសាធារណរដ្ឋវៀតណាម ខ្ញុំសំដៅទៅលើខាងវៀតណាមកុម្មុយនីស្ត ជាមួយនឹងខាងបក្សកុម្មុយនីស្តកម្ពុជា ឬជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជា ដែលកាលនោះដឹកនាំដោយសម្តេច នរោត្តម សីហនុ ។ តើមានការចុះសន្ធិសញ្ញា ឬមានការព្រមព្រៀងគ្នា ឬមានសន្យាគ្នាជាផ្លូវការណាមួយ ទាក់ទងជាមួយការធ្វើសង្គ្រាមរំដោះយកប្រទេសពីរបបលោក លន់ នល់ផង ការធ្វើសង្គ្រាមរំដោះយកវៀតណាមខាងត្បូងផងនោះ មានទេការព្រមព្រៀង ឬសន្ធិសញ្ញាគ្នាដែលថា បើកម្ពុជាឈ្នះ ឬក៏វៀតណាមឈ្នះហើយនោះ នឹងមានការបែងចែកទឹកដី ឬក៏កម្រិតព្រំប្រទល់ដីគោក និងដីសមុទ្រ តើលោកមានបានដឹងចំណុចនេះដែរឬទេ?

[០៩:៥៨:៤៥]

**ឆ៖** គឺខ្ញុំមិនបានដឹងអំពីសន្ធិសញ្ញាបែបនោះទេ ។ ហើយសន្ធិសញ្ញានោះ គឺវាត្រូវចុះហត្ថលេខារវាងរដ្ឋឯកភាពពីរគឺ ចលនារំដោះរបស់កម្ពុជា ហើយគឺវាមានការទំនាក់ទំនងគ្នាឆ្លើយឆ្លងគ្នារវាងភាគី

ទាំងពីរ ដែលសន្សារក្នុងការសហការ និងរំដោះប្រទេសរៀងៗខ្លួន ។ ខ្ញុំគឺមិនចាំអំពីៗបញ្ហាកោះ និងដែនដីផ្សេងៗ ដែលវាមានការលើកឡើងអំពីការដាក់ឧបសម្ព័ន្ធ និងគ្រប់គ្រងទៅលើកោះ ។ ខ្ញុំមិនបានឮអំពីបញ្ហានោះទេ ។

**ស៖** សូមអរគុណ ។ បន្ទាប់ពីខ្មែរក្រហមវាយរបបលោក លន់ នល់ ឈ្នះនៅថ្ងៃ១៧ មេសា ១៩៧៥ បើប្រៀបធៀបទៅនឹងខាងវៀតណាមរំដោះទីក្រុងព្រៃនគរ ឬវៀតណាមខាងត្បូងនោះ នៅថ្ងៃទី ៣០ ខែមេសា ១៩៧៥ ។ នៅក្នុងឯកសាររបស់លោក បានសរសេរទាក់ទងនឹងការចូលកាន់កាប់កោះត្រល់ កោះក្រចកសេះ ហើយនៅក្នុងសៀវភៅរបស់លោកបាននិយាយអំពីការបណ្ដេញចេញជនជាតិវៀតណាមប្រហែលជាប្រាំរយនាក់ ក្នុងទំព័រទី១៣ នៃសៀវភៅរបស់លោកជាភាសាខ្មែរ ។ ហើយមានលេខ ERN00191318 និយាយពីកងទ័ព ខ្មែរក្រហមបានឡើងទៅកោះនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ ១៩៧៥ ។ អ៊ីចឹងនៅក្នុងន័យនេះ ដែលខ្ញុំបាទសួរសំណួរមុនសំណួរនេះ ថាតើលោកបានដឹង ឬបានសម្គាល់ទាក់ទងនឹងការព្រមព្រាងទទួលស្គាល់កោះត្រល់ ឬក៏វៀតណាមហៅថា “កោះហ្វូកុក” នោះទាក់ទងនឹងកិច្ចព្រមព្រៀងនោះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងអំពីការព្រមព្រៀងគ្នាអ្វីនោះទេ ប៉ុន្តែ អ្វីដែលខ្ញុំចងចាំនោះគឺថា កាលពីខែមិថុនាឆ្នាំ៧៥ មានដំណើរទស្សនកិច្ចមួយរបស់លេខាបក្សកុម្មុយនីស្ដវៀតណាម លោក ឡេ យន់ ហើយនៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចហ្នឹង គឺមានការប្រកាសថាវៀតណាមនឹងប្រគល់កោះពូលូវ៉ៃ មកឲ្យប្រទេសកម្ពុជាវិញ ដែលមកគេបានត្រួតត្រាពីមុនមកនោះ នៅក្នុងអំពើធ្វើការវាយប្រហារបកតបវិញ ។ ហើយក្រៅពីនោះ គឺថាខ្ញុំមិនដឹង ឬក៏យល់ដឹងអំពីសេចក្ដីថ្លែងការណ៍ណាមួយទេទាក់ទងទៅនឹងកោះត្រល់ ឬក៏កោះក្រចកសេះ នោះ ។

**ស៖** សូមអរគុណ ។ ក្នុងនេះដែរ បានសរសេរសៀវភៅរបស់លោកដដែល ទាក់ទងជាមួយនឹងបានពីរអាទិត្យ ឬពីរសប្ដាហ៍ កងទ័ពវៀតណាមបានវាយព្រមានមកលើកងទ័ពកម្ពុជាប្រជាធិបតេយ្យវិញនិងចាប់បានឈ្លើយសឹកទាហានខ្មែរក្រហម ។ តើលោកបានជម្រាបទេថា ក្នុងពេលដែលវៀតណាមវាយយកកោះនោះមកវិញ ហើយចាប់បានឈ្លើយសឹកទាហានខ្មែរក្រហម មានការប្រគល់ ឬការប្ដូរផ្លាស់ឈ្លើយសឹកទៅវិញទៅមកដែរឬទេ?

**ឆ៖** ទេ, ខ្ញុំមិនជឿថា មានការផ្លាស់ប្ដូរ ឬក៏ប្ដូរអ្នកទោសបែបហ្នឹងទេ ហើយខ្ញុំនឹងមានការភ្ញាក់ផ្អើលណាស់ ប្រសិនបើមានការផ្លាស់ប្ដូរបែបនេះ ។

**សៈ** សូមអរគុណ ។ សំណួរខ្ញុំនេះ ទាក់ទងជាមួយនឹងសំណួររបស់លោកព្រះរាជអាជ្ញាអម្បាញ់មិញដែរ ប៉ុន្តែ គ្រាន់តែចង់ដឹងឡើងវិញថា ខ្ញុំមិនបានចាំពេលវេលា ព្រោះខ្ញុំអានទៅមុខទៅ ភ្លេចខាងក្រោយបន្តិច ទាក់ទងនឹងវៀតណាមបានស្នើសុំក្នុងពេលម្តងនោះ តើលោកចាំបានទេថា ប្តូរប្រជាពលរដ្ឋខ្មែរដែលភៀសខ្លួនទៅ រួមនិងសមមិត្តដែលគេចខ្លួន សមមិត្តខាងយោធា ឬក៏ខាងកងទ័ពខ្មែរក្រហមប្តូរជាមួយនឹងសត្វគោ ។ តើពេលនោះ ខាងកម្ពុជាប្រជាធិបតេយ្យ ឬខាងខ្មែរក្រហមបដិសេធតើក្រោយពេលនោះមានការប្តូរ ឬការបញ្ជូនជនភៀសខ្មែរ មកតាមភូមិភាគបូព៌ាចូលមកកាន់កម្ពុជាប្រជាធិបតេយ្យវិញដែរឬទេ?

[១០:០៤:២៥]

**ឆៈ** ព័ត៌មានដែលខ្ញុំទទួលបាន គឺទទួលបាននៅឆ្នាំ៨១ ពីមន្ត្រីរដ្ឋាភិបាលនៅខេត្តស្វាយរៀង គាត់បានប្រាប់ថា ខ្ញុំនៅដើមឆ្នាំ៧៧ រដ្ឋអំណាចថ្នាក់ខេត្តវៀតណាមបានអនុញ្ញាតឲ្យកម្ពុជាធ្វើការជ្រើសរើសអ្នកទោសភៀសខ្លួនចំនួន៤៩នាក់ ពីជំរំមួយនៅក្នុងទឹកដីវៀតណាម ពីជំរំម៉ុកហ្វា ដើម្បីធ្វើការផ្លាស់ប្តូរសត្វពាហនៈ គឺមនុស្សមួយនាក់ ដូរជាមួយនឹងសត្វគោមួយក្បាល ។

**សៈ** សូមអរគុណ ។ ពីម្សិលមិញ ខ្ញុំបានស្តាប់លោកមានប្រសាសន៍ទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធនេះ ថាកងទ័ពខ្មែរក្រហមបានវាយចូលទៅដល់ភូមិស្រុកមួយនៃខេត្តជាប់ព្រំប្រទល់កម្ពុជាប្រជាធិបតេយ្យនៃវៀតណាម ប្រហែលជាខេត្តតៃនិញ ។ ហើយកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាពលរដ្ឋវៀតណាម ។ ក្នុងនេះបានថែងអំពីការលុកលុយរបស់ទាហានខ្មែរក្រហមចូលទៅទឹកដីវៀតណាម នេះការបញ្ជាក់ម្សិលមិញ ។ តើធ្វើសង្គ្រាម ឬការវាយលុកទ្រង់ទ្រាយធំរបស់ខ្មែរក្រហមចូលទៅទឹកដីវៀតណាម មុនពេលវៀតណាមធ្វើសង្គ្រាម ឬក៏វាយលុកទ្រង់ទ្រាយធំចូលមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យមុន?

**ឆៈ** គំនិតផ្តួចផ្តើមនៅក្នុងការវាយប្រហារតាមភូមិនៅតាមព្រំដែន គឺចាប់ផ្តើមឡើងដោយខ្មែរក្រហម ហើយដូចដែលខ្ញុំបានបង្ហាញអ៊ីចឹង គឺនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ៧៧ មានការវាយប្រហារទ្រង់ទ្រាយធំមួយ ហើយនៅខែកញ្ញា ថ្ងៃទី២៤ ក៏មានការវាយប្រហារទ្រង់ទ្រាយធំមួយទៀតដែរ ។ ការវាយប្រហារទ្រង់ទ្រាយធំរបស់វៀតណាមបានធ្វើឡើង បន្ទាប់ពីមានការវាយប្រហាររបស់ខ្មែរក្រហម។

**សៈ** សូមអរគុណ ។ ពីម្សិលមិញ ទាក់ទងជាមួយនឹងការវាយប្រហារទ្រង់ទ្រាយធំនេះ ហើយត្រូវបានកងទ័ពវៀតណាមដកទៅវិញ ដោយក្នុងឯកសាររបស់លោកមានសរសេរអំពី សុន សេន, កែ

ពក, តាម៉ុក បានលើកទ័ព ឬក៏ដឹកនាំទ័ពទៅកាន់ព្រំប្រទល់កម្ពុជាប្រជាធិបតេយ្យភាគខាងកើតជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ហើយដែលក្នុងឯកសារលោកបានសរសេរអំពីខ្មែរក្រហមអបអរសាទរថាជាជ័យជម្នះ គួរតែកត់ត្រាជា "អក្សរមាស" នៅក្នុងសៀវភៅ ។ ប៉ុន្តែក្នុងនេះ ខ្ញុំមើលទៅគ្រាន់តែឃើញថា ជាមធ្យោបាយរបស់វៀតណាមមិនចង់ឲ្យមានសង្គ្រាម និងជាមធ្យោបាយដកថយទៅវិញដើម្បីឲ្យខ្មែរក្រហមដេញចូលទៅក្នុងប្រទេសរបស់វៀតណាម និងសង្គ្រប់ទាហានខ្មែរក្រហមវិញ ។

សំណួរខ្ញុំចង់សួរថា ការបង្កឲ្យមានភាពទំនាស់គ្នានេះ ទ្រង់ទ្រាយតូចតាចៗនេះ បើខ្ញុំសួរមិញទាក់ទងពីឆ្នាំ១៩៧២-៧៣ ។ អ៊ីចឹង មុននឹងកកើតជាសង្គ្រាម ឬជាការលុកលុយ ឬជម្លោះប្រដាប់អាវុធទ្រង់ទ្រាយធំនោះ វាកកើតពីឆ្នាំដែលរំដោះប្រទេស មានន័យថាខ្មែរក្រហមរំដោះប្រទេសកម្ពុជា ឬវៀតណាមខាងជើង រំដោះវៀតណាមខាងត្បូងបាន គេហៅថាជម្លោះតូចតាចៗនោះ ។ តើវាទាក់ទងគ្នាដោយសារតែពីជម្លោះតូចតាចនោះ ហើយឈានទៅរកជម្លោះនៃព្រំប្រទល់ទឹកដីទាំងពីរ ឬក៏ដោយសារតែជម្លោះបក្សកុម្មុយនីស្តនិងបក្សកុម្មុយនីស្តមិនស្របគ្នា?

[១០:០៩:០៩]

**ឆ៖** ខ្ញុំចង់ធ្វើការបញ្ជាក់នូវចំណុចមួយ នៅពេលដែលមានការប្រហារជីវិតអ្នកដែលគាំទ្រវៀតណាមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងឆ្នាំ៧២នោះ គឺមានសម្ព័ន្ធយុទ្ធសាស្ត្ររវាងបក្សកុម្មុយនីស្តកម្ពុជានិងវៀតណាមនៅក្នុងឆ្នាំ៧៤ ។ នៅពេលដែលមានការបញ្ជាក់យ៉ាងច្បាស់ថា សហរដ្ឋអាមេរិកនឹងធ្វើការដកថយ ហើយខ្មែរក្រហមនឹងអាចឡើងកាន់អំណាចនៅក្នុងប្រទេសកម្ពុជា នៅពេលនុ៎ងគឺវៀតណាមមានឆន្ទៈនឹងជួយខ្មែរក្រហម ។ ហើយនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ជោគជ័យជម្នះរបស់ខ្មែរក្រហមនោះ គឺអាចធ្វើឡើងបានដោយសារមានជំនួយដ៏ទ្រង់ទ្រាយធំរបស់វៀតណាមទាំងអាវុធ ទាំងការបណ្តុះបណ្តាល កាលពីអំឡុងឆ្នាំ៧៤ ឯណោះ ។ នោះគឺជាពេលវេលាដែរ ប្រទេសចិនមិនអាចផ្តល់ជំនួយ ហើយដោយសារតែពួកគេគ្មានមធ្យោបាយផ្ទាល់ខ្លួន ហើយការផ្គត់ផ្គង់របស់ខ្លួនត្រូវធ្វើឡើងតាមរយៈវៀតណាម តាមរយៈព្រំដែនវៀតណាម និងចិននោះ ។

ដូច្នេះ ជាលទ្ធផលបក្សកុម្មុយនីស្តវៀតណាម បានផ្តល់ជំនួយដ៏ច្រើនដល់ខ្មែរក្រហមសម្រាប់ជោគជ័យចុងក្រោយរបស់ខ្លួននៅក្នុងឆ្នាំ៧៥ ។ នោះគឺជាការបង្ហាញឲ្យឃើញនូវទំនាស់នៅក្នុងទំនាក់ទំនងរវាងភាគីទាំងពីរនេះ ។ តាមការគិតរបស់ខ្ញុំ គឺថាវៀតណាមមានសេចក្តីសង្ឃឹមថា នៅពេលដែលគេផ្តល់ជំនួយដល់ខ្មែរក្រហម គឺថាពួកគេនឹងអាចឈ្នះទឹកចិត្តទៅលើពួកគេ ដើម្បីឲ្យពួកគេធ្វើការគិត

ស្របនឹងគំនិតរបស់ខ្លួន ។ ប៉ុន្តែ ការគិតបែបនោះ គឺជាការគិតខុសទៅវិញទេ ពីព្រោះនៅពេលដែលខ្មែរក្រហមបានមានជ័យជម្នះភ្លាម ពួកគេបានធ្វើការប្រកាសថាពួកគេទទួលបានជ័យជម្នះដោយខ្លួនឯងដោយមិនមានជំនួយពីប្រទេសណាមួយនោះទេ ។ នេះគឺជាសេចក្ដីថ្លែងការណ៍ដែលពួកគេធ្វើការចាក់ផ្សាយតាមវិទ្យុនៅទីក្រុងភ្នំពេញ ។ ហើយបង្ហាញថា នេះគឺជាជោគជ័យរបស់ខ្មែរតែមួយគត់ ដោយមិនមានជំនួយពីប្រទេសណាទាំងអស់ ។

ដូច្នេះ ពេលនុ៎ង គឺវៀតណាមយល់ថាពួកគេនឹងមិនបានទទួលជោគជ័យអ្វី និងមិនបានទទួលលទ្ធផលអ្វីទេពីខ្មែរក្រហមនោះ ។

[១០:១១:៥៦]

**ស៖** សូមអរគុណ ។ អម្បាញ់មិញខ្ញុំបាទបានសួរលោកទាក់ទងជាមួយនឹងជម្លោះរវាងខ្មែរក្រហមពីឆ្នាំ៧២ ឬ ៧៣ ជាមួយនឹងវៀតណាមរហូតបង្ខំវៀតណាមចេញ ។ តើហេតុផលអ្វីដែលវៀតណាមត្រូវជួយគាំទ្រដល់ពួកខ្មែរក្រហមនៅក្នុងឆ្នាំ៧៤ ទៀត? លោកយោងកន្លែងនេះ មានអ្វីខ្លះជាបញ្ជាក់បាន?

**ឆ៖** ដូចដែលខ្ញុំបានអង្គុលបង្ហាញអ៊ីចឹង គឺថាវៀតណាមមានការចាប់អារម្មណ៍មួយ ដែលជាការចាប់អារម្មណ៍ខុស ថាពួកគេនឹងមានមិត្តភក្តិច្រើននៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ហើយពួកគេមានសេចក្ដីសង្ឃឹមថា ក្នុងការជួរដល់ខ្មែរក្រហមដោយផ្ដល់ជំនួយសំខាន់ៗនោះ ពួកគេនឹងអាចបញ្ចេញអំពីសេចក្ដីថ្លែងអំណរគុណរបស់ខ្លួន នឹងក្លាយទៅជាមិត្តភក្តិ មិត្តភាព បង្ហាញមិត្តភាពរបស់ខ្លួន នៅក្នុងជួរបក្ស ។ ខ្ញុំបានអាននូវឯកសារថ្មីៗនេះ ដោយបញ្ញវន្តរបស់ រុស្ស៊ី ម្នាក់ និយាយអំពីទំនាក់ទំនងរវាងកម្ពុជាវៀតណាម អាស្រ័យទៅលើកាលនុប្បវត្តិរបស់រុស្ស៊ី ដែលគេមានហើយទើបតែបញ្ចេញជាសាធារណៈ នៅពេលថ្មីៗនេះ ។ បញ្ញាជនរូបនេះ បាននិយាយថា នួន ជា គឺជាមនុស្សដែលបានការចាត់តាំងពី ប៉ុល ពត ឲ្យបញ្ជូនទៅសុំជំនួយពីវៀតណាម និងគឺជាមនុស្សដែលទាក់ទងជាមួយនឹងវៀតណាមនៅក្នុងជួរបក្ស ។ ហើយ នួន ជា ដែលត្រូវបានបញ្ជូនឲ្យទៅសុំជំនួយពីវៀតណាម មុនពេលការផ្ដួលរំលំភ្នំពេញនៅឆ្នាំ៧៥ នោះ ។ ហើយក្រោយគេ គឺបានធ្វើដូច្នេះតទៅទៀត ។ វៀតណាមគិតថា បានគិតរហូតដល់ក្នុងឆ្នាំ៧៨ ថា នួន ជា គឺជាមនុស្សដែលជាមិត្តភក្តិរបស់វៀតណាម ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរលោកបន្តទៅទៀត ទាក់ទងជាមួយនឹងការចរចារ ឬក៏ការព្រមព្រៀងគ្នាអម្បាញ់មិញ ខ្ញុំបាទសួរលោកទាក់ទងជាមួយនឹងជម្លោះទៅតាមបណ្ដោយព្រំដែន ។ ហើយ

រហូតដល់ឈានដល់មានការវាយ ឬក៏លើកទ័ពឆ្លងកាត់ព្រំដែនចូលទៅប្រទេសវៀតណាម ដោយខ្មែរក្រហម ហើយមានការវាយប្រហារពីសំណាក់វៀតណាមមកកម្ពុជាប្រជាធិបតេយ្យវិញផងដែរ ។

នៅក្នុងឯកសាររបស់លោកនិយាយអំពីវៀតណាម ដែលវាយទ្រង់ទ្រាយធំលើកទីមួយនេះ ចូលមកកម្ពុជាប្រជាធិបតេយ្យក្នុងគោលបំណងពីរ ។ ទីមួយ គឺចង់បង្ហាញឲ្យខាងខ្មែរក្រហមស្គាល់ថា វៀតណាមមិនទន់ខ្សោយនេះមានន័យថា អ៊ីចឹងមិនអន់ មិនអត់ធ្មត់បាននោះទេ ។ ទីពីរ គឺចង់រុញច្រានឲ្យខាងទ័ពខ្មែរក្រហមហ្នឹងចេញតែពីទឹកដីរបស់ខ្លួនតែប៉ុណ្ណោះ ។ ប៉ុន្តែ នៅក្នុងនេះបាននិយាយថា ខាងកងទ័ពវៀតណាមបានលើកទ័ពវាយដេញខ្មែរក្រហមរហូតមកដល់ខេត្តកំពង់ចាមដោយគ្មានការទប់ទល់អ្វីបន្តិចសោះផងក្នុងឆ្នាំ១៩៧៧ ។

[១០:១៥:៣០]

អ៊ីចឹងនៅក្នុងនេះ ខ្ញុំបាទចង់សួរលោកថា តើលោកមានបានកត់សម្គាល់ ឬបានទទួលជាព័ត៌មានថានាំឲ្យខ្មែរក្រហមឈឺចាប់ ឬមានកំហឹងខ្លាំងនោះ? តើកងទ័ពវៀតណាមពេលនោះ ដែលទ្រង់ទ្រាយធំវៃពេលនោះ មានការដុតបំផ្លាញ ឬកម្ទេចភូមិករ ឬសម្លាប់ប្រជាពលរដ្ឋ ឬដែលខ្មែរក្រហមហៅថា “ឆក់ប្លន់ទ្រព្យសម្បត្តិនោះ” ដែរឬទេ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនមានការចងចាំឲ្យបានច្បាស់លាស់ទេ អំពីព្រឹត្តិការណ៍នេះ ។ ក៏ប៉ុន្តែ ខ្ញុំយល់ថា ការវាយប្រហារនោះ គឺគ្រាន់តែជាការបង្ហាញអំពីអំណាច និងកម្លាំងរបស់ខ្លួនក្នុងការបញ្ជូនរថក្រោះមក ហើយនិងធ្វើការវាយលុកបានច្រើនកន្លែងនោះ ។ ខ្ញុំមិនមានចំណេះដឹងពិតប្រាកដអំពីចំណុចនោះទេ នេះគ្រាន់តែជាការកត់សម្គាល់ទូទៅរបស់ខ្ញុំ ។ គឺជាការ គ្រាន់ជាការបង្ហាញនូវអំណាចនៅសាច់ដុំរបស់វៀតណាមតែប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំសួរបន្តទៅទៀត ទាក់ទងជាមួយនឹង ក្រោយពេលដែលវៀតណាមប្រគល់កោះពូលូវ៉ៃមកឲ្យខ្មែរក្រហម ឬក៏កម្ពុជាប្រជាធិបតេយ្យវិញ ហើយសង្គ្រាមចេះតែមានបន្តទៅទៀត នេះខ្ញុំសួររៀងមកក្រោយបន្តិច ព្រោះនៅក្នុងការប្រគល់កោះពូលូវ៉ៃមកវិញនោះ គឺខាងឯកសារលោកនិយាយអំពី នួន ជា បានអបអរសាទរជាមួយនឹងការប្រគល់កោះនោះមកវិញ ។

ប៉ុន្តែ ទាក់ទងជាមួយនឹង នៅតែមានសង្គ្រាមនេះដដែល ដែលនាំឲ្យមានការច្បាំងគ្នារហូតដល់សង្គ្រាម ឬក៏ការវាយជាទ្រង់ទ្រាយធំរបស់វៀតណាមលើកទីពីរចូលមកទឹកដីកម្ពុជា តម្រង់មកទីក្រុងភ្នំពេញនឹងឈានទៅដល់ការបណ្ដេញរបបខ្មែរក្រហមឲ្យចេញអំពីអំណាចទៅទៀតនោះ ។

តើនៅក្នុងការស្រាវជ្រាវ ឬការសំអាងរបស់លោកនៅពេលនេះ វានៅតែទាក់ទងជាមួយនឹងការដណ្តើមជម្លោះ (*សុំទោស*) ជម្លោះព្រំប្រទល់ដីគោកនិងសមុទ្រ ។ មានន័យថា ជម្លោះទឹកដីដដែល ឬមួយជាការព្រមានរបស់វៀតណាមមកលើពួកកម្ពុជាប្រជាធិបតេយ្យ ។

[១០:១៨:១៤]

**ឆ៖** ខ្ញុំជឿថា នៅចុងឆ្នាំ៧៧ វៀតណាមបានសន្និដ្ឋានថា គឺនេះមិនមែនជាសំណួរនៃការយល់ច្រឡំទេ ក្នុងការដោះស្រាយទៅលើជម្លោះព្រំដែនទាំងផ្លូវគោក ឬក៏ផ្លូវទឹកនោះ ។ ប៉ុន្តែ នេះគឺជាចំណុចជាមូលដ្ឋានដែលថា និយាយអំពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះប្រទេសវៀតណាម ដែលនេះគឺជាបញ្ហាដែលត្រូវតែដោះស្រាយដោយធ្វើការផ្លាស់ប្តូរគោលនយោបាយនៅទីក្រុងភ្នំពេញ ។ ហើយប្រសិនបើជាមិនអាចធ្វើបានដូច្នេះទេ ឬគឺត្រូវមានការផ្លាស់ប្តូរថ្នាក់ដឹកនាំនៅទីក្រុងភ្នំពេញ ។ បើសិនជាមានការផ្លាស់ប្តូរផ្ទៃក្នុងនៅក្នុងបក្សដែលបក្សកុម្មុយនីស្តវៀតណាមចូលចិត្ត ដោយមិនចាំបាច់ឲ្យមានការធ្វើការផ្សព្វផ្សាយជាសាធារណៈនោះ ប៉ុន្តែ ចំណុចនេះមិនអាចធ្វើទៅបានទេ ។ ដូច្នេះហើយ វៀតណាមត្រូវតែធ្វើការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ដើម្បីរក្សាបានស្ថិរភាពនៅក្នុងប្រទេសរបស់ខ្លួន ។ នោះគឺមិនត្រឹមតែជាបញ្ហាទាក់ទងទៅនឹងជម្លោះព្រំដែននោះទេ ប៉ុន្តែ ទាក់ទងទៅនឹងបញ្ហានយោបាយផងដែរ ។

[១០:១៩:៣៩]

**ស៖** សូមអរគុណ ។ ខ្ញុំសួរលោកបន្តិចទៅទៀត ទាក់ទងតែពីរឬក៏បីសំណួរទេ ។ នៅក្នុងជម្លោះប្រដាប់អាវុធ នេះខ្ញុំនិយាយពីចន្លោះឆ្នាំ១៩៧៥មកទល់ឆ្នាំ១៩៧៩ ។ មានន័យថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនិងវៀតណាមហើយតើមានជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យជាមួយនិងប្រទេសថៃដែរឬទេ? តើលោកបានដឹង ឬក៏បានសិក្សាលើចំណុចនេះដែរឬទេ?

**ឆ៖** ដូចដែលខ្ញុំលើកឡើងកាលពីម្សិលមិញ គឺមានការប៉ះទង្គិចរវាងកងទ័ពរបស់ប្រទេសថៃនិងកងទ័ពរបស់ខ្មែរក្រហម ប៉ុន្តែការប៉ះទង្គិចនោះ គឺទាក់ទងទៅនឹងបញ្ហាបោះបង្គោលព្រំដែន ដែលវាទាក់ទងទៅនឹងទីតាំងនៃបង្គោលព្រំដែន ដែលបោះដោយបារាំងនៅដើមសតវត្សរ៍ ហើយវាមាននៅទីកន្លែងផ្សេងៗ ។ ហើយទីកន្លែងដែលមិនបានបោះត្រឹមត្រូវ ឬក៏មានលក្ខណៈស្រពេចស្រពិលគឺមានការប៉ះទង្គិចកើតឡើង ប៉ុន្តែមិនមានលក្ខណៈទ្រង់ទ្រាយធំទេ តាមន័យនយោបាយ ។ ដោយសារតែវាជាបញ្ហា

ជម្លោះលើទឹកដីតែប៉ុណ្ណោះ មិនមែនជាបញ្ហាជម្លោះលើផ្នែកនយោបាយនោះទេ ។

[១០:២១:៣០]

**ស៖** សូមអរគុណ ។ នេះជាសំណួរភ្ជាប់បន្តិចទេ តើនៅក្នុងនោះមិនមាន ក្នុងឯកសារលោកមិនមាននិយាយទេ ប៉ុន្តែវាទាក់ទងតែជម្លោះតែប៉ុណ្ណោះ ហើយដែលខ្ញុំបានមើលឃើញឯកសារផ្សេងគ្រាន់តែសួរសូមអញ្ជាតលោកប្រធានសួរបន្តិចថា លោកមានបានកត់ត្រាបានទេថា ការទាស់គ្នាជាមួយកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមមានបញ្ជូនជនភៀសខ្លួនខ្មែរ ដោយសារថៃ រដ្ឋាភិបាលថៃមានទំនាស់ឬក៏ខឹង ឬក៏មានចុះសន្ធិសញ្ញាក៏ខ្ញុំមិនច្បាស់ដែរ ។ កន្លែងនេះថា ដោយសារនៅចុងឆ្នាំ១៩៧៥ មានបញ្ជូនប្រជាជនខ្មែរចំនួនម្ភៃប្រាំមួយនាក់មកតាមស្រុកអារញ្ញប៉ាថេត ទាក់ទងគ្នានៅប៉ោយប៉ែតចូលមកកម្ពុជាប្រជាធិបតេយ្យវិញ ។ អ៊ីចឹងជាការសម្របសម្រួលគ្នារវាងកម្ពុជាប្រជាធិបតេយ្យនិងថៃ បានបញ្ជូនជនភៀសខ្លួនមកវិញ ។ ជនភៀសខ្លួនទាំងនោះរស់នៅភូមិបាត់ត្រង់ ភូមិថ្មី ឃុំសំរោង ស្រុកសិរីសោភ័ណខេត្តបាត់ដំបង កាលនោះ ។ អ៊ីចឹងវាទាក់ទងនឹងការព្រមព្រៀងគ្នាដែរឬទេ? នេះគ្រាន់តែជាចម្ងល់មួយតូចដែលខ្ញុំចង់សួរភ្ជាប់តែប៉ុណ្ណោះ ។

**ឆ៖** គឺខ្ញុំអត់ដឹងអំពីកិច្ចព្រមព្រៀងបែបនោះទេ ។ ដូចដែលខ្ញុំលើកឡើងហើយ វាយូរហើយដូច្នេះហើយខ្ញុំអត់ចាំទេ ។

**ស៖** សូមអរគុណ ។ ជាចុងក្រោយ ខ្ញុំគ្រាន់តែសួរសំណួរជាបញ្ជាក់មកវិញថាប្រវត្តិសាស្ត្រកម្ពុជានិងវៀតណាម នៅក្នុងសៀវភៅរបស់លោក ក៏ដូចលោកមានប្រសាសន៍ពីថ្ងៃម្សិលមិញមកថាបញ្ជាក់អំពីការលើកឡើង កន្លែងនេះខ្ញុំមិនច្បាស់ទេ ។ ចង់សុំលោកបញ្ជាក់ឡើងវិញបន្តិចថា លោកបានមានប្រសាសន៍ចំណុចមួយដែលខ្ញុំបានកត់ត្រាទុកថា "មិនត្រឹមតែបក្សកុម្មុយនីស្តវៀតណាមទេ គឺជនជាតិវៀតណាម មានប្រវត្តិឈ្លានពានលេបទឹកដី" តើនេះជាចំណុចដែលលោកដកស្រង់សម្តីកម្ពុជាប្រជាធិបតេយ្យហៅថា ខ្មែរក្រហម ឬក៏ជារឿងប្រវត្តិសាស្ត្រដែលឈានទៅរកជម្លោះរវាងវៀតណាមនិងកម្ពុជា?

**ឆ៖** នៅក្នុងសៀវភៅខ្មៅ ខ្មែរក្រហមបានអះអាងដូច្នោះថា "សារជាតិរបស់វៀតណាម គឺពាក្យដែលបានប្រើប្រាស់ បានន័យថា គ្រប់វៀតណាមទាំងអស់ តាំងពីសម័យចក្រពត្តិ ឬក៏សម័យហូជីមិញក៏ដោយ គឺជនជាតិវៀតណាមគឺមានគំនិតក្នុងការពង្រីកទឹកដី និងឈ្លានពានទឹកដីកម្ពុជា" នេះគឺជាសេចក្តីសន្និដ្ឋានរបស់ខ្មែរក្រហម ។ ហើយវៀតណាម និងប្រជាជនវៀតណាមនោះ គឺជាអ្នកដែល

មានលក្ខណៈសារជាតិពង្វាតទឹកដី ។

[១០:២៤:៥០]

**លោក ហុង គីមសួន៖**

**ស៖** សូមអរគុណលោក ណាយ៉ាន់ ចាន់ដា ហើយខ្ញុំបាទសូមអរគុណលោកប្រធាននឹងបន្តទៅខាងសហមេធាវីដើមបណ្ដឹងបន្តទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបី។ បើមានសំណួរអីចង់សួរដល់អ្នកជំនាញរូបនេះ សូមអញ្ជើញ ។ មេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីបាទ បើមានសំណួរអីចង់សួរដល់អ្នកជំនាញរូបនេះសូមអញ្ជើញ មេធាវីឲ្យតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ។

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

លោកប្រធាន ក្រុមបីគឺអត់មានសំណួរទេ ចង់សួរទៅកាន់សាក្សីជំនាញនោះទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត សូមអញ្ជើញមេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ ។ ប្រសិនបើមានសំណួរត្រូវសួរដល់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា នេះ សូមអញ្ជើញ ។

[១០:២៥:៥៨]

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទក្នុងតំណាងឲ្យមេធាវីក្រុមពីរ គឺថាអត់មានសំណួរអីទេ ឃើញថាការសួរនេះគ្រប់គ្រាន់អស់ហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ តើមានសំណួរអ្វីចង់សួរដល់អ្នកជំនាញរូបនេះទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** សូមអរគុណលោកប្រធាន ។ អរុណសួស្ដីលោក ចាន់ដា ឈ្មោះរបស់ខ្ញុំគឺ អាឡាំង វ៉ែនណឺ ខ្ញុំជាសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ ហើយខ្ញុំតំណាងដើមរដ្ឋប្បវេណីជាមួយនិងសហសេវិករបស់ខ្ញុំ ទ្រី ស្រ៊ីនណា ។ ខ្ញុំមានដូចដែលខ្ញុំបានលើកឡើងម្សិលមិញ គឺខ្ញុំមានមួយសំណួរ ។ លោក

បាននិយាយម្សិលមិញថា ប្រតិបត្តិការកងទ័ពរបស់សហរដ្ឋអាមេរិក គឺមានកើតឡើងពីរដង ។ ដូច្នេះ តើឲ្យលោកបញ្ជាក់ថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកគឺបានបញ្ចប់នៅក្នុងខែសីហា ឆ្នាំ ១៩៧៣ តើត្រឹមត្រូវដែរឬទេ?

**លោក ណាយ៉ាន់ ចាន់ដា៖**

**ឆ៖** នេះគឺជាអ្វីដែលខ្ញុំចងចាំ ។ ប៉ុន្តែ បន្ទាប់គឺមានការទម្លាក់គ្រាប់បែកក្នុងឆ្នាំ៧៥ នៅពេល ដែល ម៉ាកវ៉េ មានការគេចខ្លួន ម៉ាកវ៉េ មានការចាប់ខ្លួន (*សូមកែតម្រូវ*) ។

**ស៖** អ៊ីចឹងបានន័យថា វាមិនបានបញ្ចប់ក្នុងខែសីហា ឆ្នាំ១៩៧៣ នោះទេ ។ គឺខ្ញុំសូមអរគុណ គឺខ្ញុំអស់សំណួរហើយ គឺសូមកែតម្រូវគឺនាវា ម៉ៃយ៉ាហ្គេ បានត្រូវបានរឹបអូសនឹងចាប់យក ។

[១០:២៧:៥០]

**ប្រធានអង្គជំនុំ៖**

ជាបន្ទាប់ទៅនេះ សូមប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានសំណួរពាក់ព័ន្ធទៅនឹងអ្នក ជំនាញ ណាយ៉ាន់ ចាន់ដា នេះ ។ ប្រសិនបើមានសូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំមិនមានសំណួរច្រើនទេ ដោយសារថា រឿងជម្លោះប្រដាប់ អាវុធរវាងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម វាជារឿង កំពូលរវាងរដ្ឋនិងរដ្ឋ ។ វាមិនមែនជារឿងរបស់ស-២១ទេ ហើយយើងខ្ញុំគ្រាន់តែសុំឲ្យលោកខាងជំនាញ បញ្ជាក់បន្តិចទេ តែមួយម៉ាត់ទេ បញ្ជាក់ថា តើវៀតណាមគេដឹងទេនៅពេលដែលគេបញ្ជូនដូរមនុស្សនេះ? ឧបមាថា នៅបូព៌ា នៅខាងស្វាយរៀង លោកបញ្ជាក់អំមិញហើយថា ដូរគោ ។ មនុស្សម្នាក់ដូរគោ មួយក្បាល នៅខាងព្រៃវែងដូចជាស្រុកព្រះស្តេច មនុស្សម្នាក់គេដូរអំបិលមួយតៅ ។ វៀតណាមគេយក អំបិលមួយតៅទៅ គេឲ្យមនុស្សម្នាក់ឡប់មកខាងកម្ពុជាប្រជាធិបតេយ្យវិញ ។ អ៊ីចឹងគេដូរម្តងម្ភៃនាក់ សាមសិបនាក់ តើវៀតណាមគេដឹង លោកបញ្ជាក់ សូមបញ្ជាក់ត្រង់ហ្នឹង? តើវៀណាមគេដឹងថា ការ ដែលគេដូរមនុស្សយកមកនេះ? អាមនុស្សគេយកមកហ្នឹងគេយកមកសម្លាប់ចោលវៀតណាមគេដឹងទេ សូមលោកបញ្ជាក់ត្រង់ហ្នឹង?

សូមអរគុណ ។

[១០:២៩:៤៣]

**លោក ណាយ៉ាន់ ចាន់ដា៖**

**ឆ៖** គឺខ្ញុំអត់ដឹងអំពីរឿងរ៉ាវដែលទាក់ទងអំបិលមួយតៅនោះទេ ប៉ុន្តែ វាច្បាស់ហើយវាបង្ហាញច្បាស់លាស់ហើយថា វៀតណាមគឺធ្វើមាតុភូមិនិវត្តន៍ ហើយដោយបានដឹងទាំងស្រុកទៅលើបញ្ហានោះ។ អ៊ីចឹង គឺដឹងទៅលើអ្នកដែលរង់ចាំធ្វើមាតុភូមិនិវត្តន៍ អ៊ីចឹងបានវៀតណាមធ្វើការមាតុភូមិនិវត្តន៍ ហើយនេះ គឺជាអ្វីដែលខ្ញុំបានដឹង ហើយខ្ញុំបានដឹងអំពីការផ្លាស់ប្ដូរពីមន្ត្រី ការដោះដូរនោះពីមន្ត្រីមួយរូបនៅក្នុងឆ្នាំ១៩៨១ ។

**ស៖** សូមអនុញ្ញាត សូមលោកបញ្ជាក់ ព្រោះសំណួររបស់ខ្ញុំ ខ្ញុំសួរថាតើវៀតណាម ឲ្យលោកបញ្ជាក់ថាតើវៀតណាមគេដឹងទេ កាលដែលដូរមនុស្សយកមកន៎ែ? លោកគេងណោះ គេបានគោទៅ គេវ៉ៃស៊ីទៅ បានអំបិលទៅ គេយកទៅស្លស៊ីទៅ ប៉ុន្តែឯន៎ែ បានមនុស្សយកមក គេយកមកវ៉ៃចោល ។

តើវៀតណាមគេដឹងទេ? ដែលដូរយកមនុស្សយកមកឲ្យគេវ៉ៃចោលន៎ែ តើវៀតណាមគេដឹងទេ? ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ។ សូមអរគុណ ។

**ឆ៖** ដូចដែលខ្ញុំបានរៀបរាប់ហើយ គឺខ្ញុំអត់ដឹងផ្ទាល់ទាក់ទងទៅនឹងការដោះដូរនេះទេ គឺខ្ញុំទទួលព័ត៌មានពីមន្ត្រីកម្ពុជា ហើយខ្ញុំអត់ដឹងថា តើវៀតណាមទៅលើបញ្ហានោះ ហើយមានអ្វីកើតឡើងចំពោះអ្នកដែលត្រូវបានដោះដូរ ហើយបញ្ជូនមកវិញ គឺខ្ញុំអត់បានដឹងទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណលោកប្រធាន។ អរុណសួស្ដីលោក ចាន់ដា! សូមថ្លែងអំណរគុណចំពោះការផ្ដល់សក្ខីកម្មរបស់លោក ។ លោកប្រធាននៅក្នុងពេលនេះ គឺខ្ញុំចង់ឲ្យជនជាប់ចោទ ធ្វើការផ្ដល់យោបល់មួយចំនួន មុនពេលដែលខ្ញុំតាំងសំណួរទៅកាន់អ្នកជំនាញ ។ ដូច្នេះ ខ្ញុំធ្វើការប្រតិកម្មនូវអ្វីដែលបានលើកឡើងដោយអ្នកជំនាញ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

គឺខ្ញុំសូមឲ្យជនជាប់ចោទ ធ្វើការឡើងផ្ដល់ប្រតិកម្មចំពោះយោបល់របស់អ្នកជំនាញ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក កាំង ហ្កេកអ៊ាវ ។

[១០:៣៣:០៣]

**ជនជាប់ចោទ៖**

សូមគោរព អរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំមានមតិចាប់អារម្មណ៍អំពីស្នាដៃរបស់លោក ជំនាញរូបនេះ គឺលោក ណាយ៉ាន់ ចាន់ដា ។ តាមការសង្កេតរបស់ខ្ញុំ លក្ខណៈល្អទីមួយ ស្នាដៃរបស់លោក ណាយ៉ាន់ ចាន់ដា គឺជាស្នាដៃមួយដែលមានលក្ខណៈសម្បូរបែប ។ ពោរពេញទៅដោយព្រឹត្តិការណ៍ ដែលអ្នកជំនាញ ណាយ៉ាន់ ចាន់ដា លោកបានឮ ។ លោកបានឃើញ លោកបានអានលោកបានដឹង ។ សរុបមកវិញ គឺលក្ខណៈទីមួយ ដែលសម្បូរបែបហ្នឹង គឺសម្បូរទៅដោយព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលលោកយកមកចងក្រង ។

លក្ខណៈទីពីរនៃស្នាដៃរបស់លោកៗបានបង្ហាញនូវគោលគំនិតដ៏ធំបំផុតមួយ ។ គោលគំនិតដ៏ធំបំផុតនេះ តាមខ្ញុំចាំ បើសិនជាខ្ញុំមិនច្រឡំទេ គឺជាគោលគំនិតដែលលោកជំនាញ លោកបានឮពីមាត់របស់ ផាំ វ៉ាន់ដុង ។ សូមបញ្ជាក់ថា ផាំ វ៉ាន់ដុង គាត់ជានាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ តាមការសង្ខេបរបស់លោកជំនាញម្សិលមិញ លោកថា គោលគំនិតដែល ផាំ វ៉ាន់ដុង និយាយមានបី៖

គោលគំនិតទីមួយ គឺថាជំហានដំបូង បក្សកុម្មុយនីស្តវៀតណាមគឺ ឡេ យន់ គេចង់អប់រំ ប៉ុល ពត ឲ្យងាកទៅតាមគេ ។ បើសិនជាគេធ្វើមិនបានទេ គេឲ្យខ្មែរជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានេះ ទម្លាក់ ប៉ុល ពត ។ ទីបី បើសិនជាមិនកើតតទៅទៀត គេនឹងវ៉ៃពីក្រៅ ។ នេះជាគោលគំនិតដែលលោកជំនាញលោកមានប្រសាសន៍ម្សិលមិញ បើតាមខ្ញុំស្ដាប់បាន ហើយបើខ្ញុំមិនច្រឡំទេ ។ គោលគំនិតនេះ បើតាមខ្ញុំយល់ នេះចូលក្នុងកថាខណ្ឌទី៣ ដែលខ្ញុំសូមវិភាគព័ត៌មាននេះហើយ ។ វាជាកិច្ចអនុវត្តនៃទ្រឹស្ដី ហូជីមិញអំពីសហគមន៍ឥណ្ឌូចិន ។ ហូជីមិញ គាត់លោកលើកទ្រឹស្ដីថា បុព្វហេតុតែមួយគឺតស៊ូវ៉ៃបារាំងដូច្នេះត្រូវតែមានបក្សតែមួយដឹកនាំ គឺបក្សកុម្មុយនីស្តឥណ្ឌូចិន ។ បក្សតែមួយ កងទ័ពតែមួយ រដ្ឋា-ភិបាលតែមួយ ប្រទេសតែមួយ គឺសហព័ន្ធឥណ្ឌូចិន ។ នេះហើយ គឺជាទ្រឹស្ដី ហូជីមិញ ដែលយើងខ្ញុំបានជម្រាបអង្គសវនាការម្សិលមិញ ។ ជាប្រភពនៃទំនាស់ស្លាប់រស់ រ៉ាំរ៉ៃរវាង ឡេ យន់ និងប៉ុល ពត ។ សូមបញ្ជាក់ថា ឡេ យន់ គឺជាអគ្គលេខាធិការបក្សពលករវៀតណាម ដល់ក្រោយមកគេប្រែឈ្មោះថា

បក្សកុម្មុយនីស្តវៀតណាម ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន គឺវាមានបញ្ហាទាក់ទងទៅនឹងបកប្រែ គឺខ្ញុំសូមឲ្យអានឈ្មោះរបស់អគ្គលេខាធិការបក្សពលករវៀតណាម និយាយឡើងវិញឲ្យបានច្បាស់លាស់ ។ ដូច្នេះគឺសូមឲ្យលោក ឌុច ធ្វើការប្រកបគឺឈ្មោះអគ្គលេខាធិការនៃបក្សពលករវៀតណាម ។

ដូច្នេះ យើងនិយាយអំពី ឡឺឌុយយុង គឺមិនមែន ឡេ យន់ គឺឡឺឌុយយុង ។

**ជនជាប់ចោទ៖**

ដូច្នេះ សូមអរគុណ ដែលខំបញ្ជាក់នេះ ដើម្បីកុំឲ្យច្រឡំពាក្យខ្មែរមួយម៉ាត់ ដែលប្រើសម្រាប់មើលងាយជនជាតិវៀតណាមថា "យួន"នោះ ។ គឺយើងខ្ញុំអត់មានមើលងាយជនជាតិវៀតណាមទេ ។ ខ្ញុំនិយាយអំពី-- ខ្ញុំសូមបន្តទៅទៀត ទំនាស់រវាង ឡេ យន់ ហើយនឹងប៉ុល ពត ជាទំនាស់ស្លាប់រស់ជាទំនាស់រ៉ាំរ៉ៃ គឺមានន័យថាយូរអង្វែងៗ ។ តាំងពីឆ្នាំ១៩៥៤ ឡេ យន់ ក៏នៅតែតាំងខ្លួនគាត់ថាជាបីតាឥណ្ឌូចិនដដែលនុ៎ង មានហ្សឺណែវ ក៏ដោយ ។

នេះហើយដែលខ្ញុំបានជម្រាបអង្គសវនាការម្សិលមិញ ថាទំនាស់រវាង ឡេ យន់ និង ប៉ុល ពត ម្នាក់ៗរករឿងកាច់គ្នាទៅវិញទៅមកជាប់ជានិច្ច។ ហើយលោកជំនាញក៏លើកបញ្ហាមួយច្រើនដែរ ហើយលោកជំនាញគាត់នៅបញ្ជាក់ថា រឿងទាំងអស់នេះទោះបីជាការកាប់ចាក់គ្នាខាងអាវុធក៏ដោយ ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌម្នាក់ៗញ៉ាំងឲ្យ-- ឡេ យន់ ញ៉ាំងឲ្យ ប៉ុល ពត គោរពតាមខ្លួន ។

[១០:៤៣:២៣]

សូមអរគុណហើយ កាលដែលខ្ញុំបានឮទស្សនៈបី(ខ)របស់ ផាំ វ៉ាន់ដុង អំពីស្ដីលោកជំនាញដែលមកពីប្រភពខាង ផាំ វ៉ាន់ដុង ។ ដូច្នេះ ទំនាស់ទាំងអស់នេះ រហូតដល់ទំនាស់ប្រដាប់អាវុធជាចំហប្រកាសជាផ្លូវការលើសកលលោកនៅថ្ងៃទី៣១ ធ្នូ ១៩៧៨ ក៏ដោយ ។ ៣១ ធ្នូ ១៩៧៨ គេប្រកាសច្បាំងគ្នាជាចំហហើយ ។ ខ្ញុំសូមបញ្ជាក់ថា ប៉ុល ពត ហើយនិង ឡេ យន់ គេទាស់គ្នាជាបុគ្គលគេពីរនាក់ ។ ម្នាក់ៗមានបក្សរៀងខ្លួន មានកងទ័ពរៀងខ្លួន ដូច្នេះវាអន្តរាយ វាហួរឈាមមនុស្សរាស្ត្រតូចតាច ។

តុលាការជាទីគោរព! ខ្ញុំនិយាយនេះមិនមែនអះអាងថា ប៉ុល ពត អ្នកស្នេហាជាតិដ៏មហាអស្ចារ្យទេ ។ ប៉ុល ពត ជាឧក្រិដ្ឋកៗ បិតាឧក្រិដ្ឋកធំបំផុតរបស់កម្ពុជាហើយ ។ មាគ៌ាដែលគាត់ចេញ នៅក្នុងទង់បដិវត្តន៍ឆ្នាំ១៩៧៣ ដែលគាត់ចែងថា មាគ៌ាវណ្ណៈណា កម្មាភិបាលវណ្ណៈនោះ ។ មានន័យថា បក្ស

កុម្មុយនីស្តកម្ពុជាជាបក្សវណ្ណៈអធន ។ អ្នកឯងជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាត្រូវតែកសាងខ្លួន ទៅតាមវណ្ណៈអធន ។ បើអ្នកឯងមិនកសាងខ្លួនទេ អ្នកឯងត្រូវជ្រុះចេញពីបក្ស ឬក៏អ្នកឯងត្រូវកម្ទេច ។

ខ្ញុំក៏បានបញ្ជាក់ជូនលោកចៅក្រមស៊ើបអង្កេតហើយកាលពីថ្ងៃទី២១ តុលា ២០០៨ នៅក្នុងឯកសារលេខ D90/II/1 ត្រង់ទំព័រ ERN00023079 នៅក្នុងឯកសារនេះខ្ញុំបានបញ្ជាក់ជូនតុលាការថា ទោះបីមានរូបភាពដែល ប៉ុល ពត ចង់បន្តិខ្លួនយ៉ាងណាក៏ដោយ 90/II/1 ។ សូមបញ្ជាក់ថា ក្នុងឯកសារនេះខ្ញុំបញ្ជាក់ថា ខ្ញុំអត់ទទួលស្គាល់ ប៉ុល ពត ថាអ្នកស្នេហាជាតិ ហើយអត់មានបាតដៃប្រលាក់ឈាមទេ ។ ប៉ុល ពត ប្រើពាក្យថា ចង់ឈ្នះយួនត្រូវបក្សស្អាត កងទ័ពស្អាត ប្រជាជនស្អាត ។

ដូច្នេះ ខ្ញុំនៅតែរក្សាគោលគំនិតទីមួយថា វាមានទំនាស់រវាងមាគ៌ាសហព័ន្ធឥណ្ឌូចិន ហើយនិង ប៉ុល ពត ។ ស្ថិតក្នុងទំនាស់ នេះ ប៉ុល ពត ជាឃាតក ។ ក្នុងនេះខ្មែរជាងមួយលាននាក់ស្លាប់ដោយសារស្នាដៃ ប៉ុល ពត ។ ក្នុងនេះស-២១ បាតដៃខ្ញុំប្រលាក់ឈាមមនុស្ស ១២,៣៨០ នាក់យ៉ាងតិច ។ ខ្ញុំអត់រត់គេចពីស្មារតីទទួលខុសត្រូវទេ ។ ខ្ញុំគ្រាន់តែនិយាយឲ្យឃើញថា ទំនាស់រវាង ប៉ុល ពត ហើយនិង ឡេយន់ វាក៏រ៉ៃ។ ឈាមខ្មែរ ឈាមវៀតណាម ហូរដោយសារអាពីរនាក់ហ្នឹងវាទាស់គ្នា ។

សុំចុងបញ្ចប់នេះ សូមនិយាយពីការចាប់ អារម្មណ៍របស់ខ្ញុំបន្តិចចំពោះពាក្យដែលលោកជំនាញដែលលោកសរសេរចំណងជើងសៀវភៅលោកថា “បងប្អូនឯងទាស់គ្នា” បើលោកនិយាយអំពីកូរ៉េ ខ្ញុំគាំទ្រ ។ គេមានប្រវត្តិសាស្ត្ររួមគ្នា គេមានផែនដីទឹកដីរួមគ្នា គេមានភាសារួមគ្នា ឯចំណែកយើងខ្ញុំហើយនិងវៀតណាម មិនដែលមានទឹកដីរួមគ្នាទេ សូមបញ្ជាក់ ។ ខ្ញុំបន់ឲ្យកូរ៉េ ហើយនិងចិនជួបផុតសំណាងល្អដូចអាល្លឺម៉ង់អ៊ីចឹង គេជាបងប្អូននឹងគ្នា ។

ខ្ញុំចុងបញ្ចប់នេះសូមគោរពដល់កិច្ចការជាស្នាដៃរបស់លោកជំនាញដោយស្មោះ ដែលលោកបានយកប្រសាសន៍របស់លោក ផាំ វ៉ាន់ដុង មកសរសេរចុះក្នុងសៀវភៅនេះ ។ បើសិនជាយើង បើសិនជាខ្ញុំនិយាយភាសាតាម ប៉ុល ពត មិនមានតម្លៃទេ ដល់លោកជំនាញលោកយកប្រសាសន៍ ផាំ វ៉ាន់ដុង មកនិយាយមានតម្លៃណាស់ ។ សូមអរគុណដែលបានលោកជំនាញ លោកស្តាប់ពាក្យខ្ញុំ ហើយសូមអធ្យាស្រ័យ បើកាលណាខ្ញុំមានយោបល់ហើយ វាខុសឆ្គងត្រង់ចំណុចណាសូមលោកជំនាញលោកមេត្តាអធ្យាស្រ័យ ។ សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមនេះដោយគោរព។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាកផង ហើយ ឌីវីឌី សម្រាប់ថតសំឡេងក៏អស់ដែរ ។ អ៊ីចឹង អង្គជំនុំ

ជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយនិងដប់នាទី អញ្ជើញចូលមកវិញដើម្បីបន្តដំណើរការសវនាការបន្តទៀត ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់អ្នកជំនាញដើម្បីបានកន្លែង ទទួលកន្លែងសម្រាកសមរម្យក្នុងអំឡុងពេលសម្រាកនេះ ។

*[សវនាការសម្រាកពីម៉ោង ១១:៥៥នាទី ដល់ម៉ោង ១១:១៨នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ សូមអញ្ជើញនាងមេធាវី ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន! មុននឹងចាប់ផ្តើមហ្នឹង នាងខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីសាកសួរទៅ ជាការសុំបំភ្លឺទៅលើចំណុចមួយដែលពាក់ព័ន្ធជាមួយនឹងការបំភ្លឺរបស់ជនជាប់ចោទ គាត់លើកឡើងមុនពេលបញ្ចប់ មុនពេលយើងឈប់សម្រាកអម្បាញ់មិញហ្នឹង ។ តើនាងខ្ញុំសុំការអនុញ្ញាតពីលោកប្រធាន តើខ្ញុំអាចសូមឲ្យខាងជនជាប់ចោទជួយបំភ្លឺទៅលើចំណុចមួយបានដែរឬទេ? លោកប្រធាន ។ ដើម្បីជៀសវាងកុំឲ្យមានការពេលដែលនីតិវិធីបន្តទៅទៀតទៅ បើសិនជាខ្ញុំលើកឡើងទៅខ្ញុំសួរបកចុះបកឡើងនាំឲ្យនីតិវិធីលើកក្រោយមានការសួរច្របល់បកចុះបកឡើង អ៊ីចឹងនាំឲ្យមានការប៉ះពាល់ដល់នីតិវិធីយើងលើកក្រោយទៀត លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជម្រះអនុញ្ញាត ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណលោកប្រធាន ។ មុននឹងមានការឈប់សម្រាកហ្នឹង ខ្ញុំបានឮលោក ឌុច គាត់បានលើកឡើងទាក់ទងទៅនឹងចំណុចមួយ ដែលពាក់ព័ន្ធទៅនឹងបញ្ហាទំនាស់រវាង ទំនាស់បុគ្គលរវាងលោក ប៉ុល ពត ជាមួយនិង ឡេ យន់ ។ ពេលហ្នឹង លោកបានលើកឡើងទាក់ទងទៅនឹងចំណុចហ្នឹង តើខ្ញុំគ្រាន់តែចង់ដឹងថា តើមុននឹងឈានទៅដល់មានការទំនាស់គ្នារវាងបុគ្គលរហូតឈានទៅដល់ថ្នាក់ទំនាស់ចេញជារូបរាងតាមផ្លូវ--

អូខេ ។ មុននឹងឈានទៅដល់ទំនាស់ដែលចេញលក្ខណៈជាផ្លូវការ ដោយមានការប្រយុទ្ធគ្នាជាលក្ខណៈផ្លូវទ័ពនោះ ខ្ញុំគ្រាន់តែចង់ដឹងថា តើលោក ប៉ុល ពត និង ឡេយន់ ក៏ដូចជាបក្សកុម្មុយនីស្តរបស់វៀតណាម និងលោក ប៉ុល ពត ហ្នឹង តែខ្ញុំចង់ដឹងអំពីទំនាក់ទំនងរវាងពួកគាត់ទាំងពីរ តើយ៉ាងម៉េចដែរ? តើលោកអាចសុំបំភ្លឺទៅលើបញ្ហាទំនាក់ទំនងហ្នឹងបន្តិច មុននឹងឈានទៅដល់មានការជម្លោះជាបុគ្គលក៏ដូចជាជម្លោះផ្លូវការ ។ សូមអរគុណ ។

[១១:២១:១៨]

**ជនជាប់ចោទ៖**

**ឆ៖** សូមគោរពលោកប្រធានជាទីគោរព ។ បញ្ហានេះវាជាបញ្ហាប្រវត្តិសាស្ត្រវែងឆ្ងាយ នៅឆ្នាំ១៩៣០ ហូជីមិញ គាត់កសាងបក្សកុម្មុយនីស្តឥណ្ឌូចិន នៅស្រុកបារាំងនោះ ហើយគាត់មករៀបចំមូលដ្ឋានបង្អែកនៅគ័ងតុង ។ ឆ្នាំ១៩៤៥ គាត់កសាងសាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំនុំងហើយដែលគាត់បញ្ជូនកម្មាភិបាលវៀតណាមម្នាក់ ឈ្មោះ ង្វៀង ខាន់សឺន មកកសាងកម្លាំងបដិវត្តន៍ខ្មែរនៅកម្ពុជា ។ ខ្ញុំអធិប្បាយនេះ ទៅតាមឯកសារមួយដែលរៀបរៀងដោយអ្នកនិពន្ធបារាំងម្នាក់មានចំណងជើងថា *"ឌីកូលូញ៉ាលីសស្យ៉ុស អូកុយនីស្ត"* ដែលគណៈបក្សសាធារណរដ្ឋរបស់ តានល់ គាត់ទុកជាឯកសារស្នូលនៃគណៈបក្សគាត់ ។ នេះខ្ញុំយកឯកសារនុំង ។ ហើយដល់ឯកសារដែលបក្សកុម្មុយនីស្តកម្ពុជាគេបង្រៀន ដូចខ្ញុំបានជម្រាបមិញហើយ បុព្វហេតុតែមួយគឺតស៊ូវាយបារាំង ។ ដូច្នេះ ត្រូវមានបក្សតែមួយដឹកនាំ ត្រូវមានកងទ័ពតែមួយ មានប្រទេសតែមួយ គឺសហព័ន្ធឥណ្ឌូចិន ។ នេះជាប្រវត្តិសាស្ត្រវាហូរហែមក ។

ដល់ពេលឆ្នាំ១៩៥៣ ប៉ុល ពត គាត់មកចូលនៅក្នុងបក្សនេះជាមួយនឹងគេនឹងឯង ។ ដល់ឆ្នាំ១៩៥៦ ក្រោយបោះឆ្នោត ប៉ុល ពត គាត់ចាប់ផ្តើមកសាងកម្លាំងមួយដែលមានលក្ខណៈឯករាជ្យមិនស្ថិតនៅក្រោមឆ័ត្ររបស់សហព័ន្ធឥណ្ឌូចិន ដែល ហូជីមិញ គាត់រៀបឡើងទេ ។ លោក ណាយ៉ាន់ ចាន់ដាក៏លោកមានប្រសាសន៍បញ្ហាហ្នឹងដែរ ។ ប៉ុល ពត កសាងកម្លាំងហូរហែមក ឆ្នាំ១៩៥៦ គាត់កសាងកម្លាំងមួយរបស់គាត់សម្រាប់ត្រៀមទៅធ្វើសង្គ្រាមប្រដាប់អាវុធ គេហៅថា កងការពារសម្ងាត់ ។ ឆ្នាំ១៩៥៨ គាត់ចាប់ផ្តើមរៀបចំកសាងកងឈ្លបជាសម្ងាត់ហើយ ។ ឆ្នាំ១៩៦៨ ថ្ងៃ១៨ មករា មិនមែន១៧ទេ ប្រវត្តិសាស្ត្រមែនទែន គឺថ្ងៃ១៨ មករា ។ កងឈ្លបរបស់ ប៉ុល ពត ដឹកនាំៗដោយបង ញឹម ទៅវាយប៉ុស្តិ៍បាយដំរ៉ាម យកបានកាំភ្លើងជីវពលជាងដប់ដើមរត់ឡើងភ្នំវាយចាប ។

ដូច្នេះ ប៉ុល ពត ក៏ឧទ្ទេសនាមការកកើតកងទ័ពរបស់ខ្លួននៅថ្ងៃហ្នឹង គឺ១៨ ដល់ លន់ នល់ គាត់ធ្វើរដ្ឋប្រហារនៅថ្ងៃ១៨ មីនា ប៉ុល ពត ក៏កែប្រែឈ្មោះមកដាក់ថ្ងៃ១៧ ឲ្យវាស្របគ្នា១៧ មេសា ទៅ ។

ដូច្នេះ នៅពេលដែល ប៉ុល ពត គាត់កាន់កាប់ជាលេខាបន្តពីខ្មោចតា ទូ ។ តាទូ ត្រូវគេចាប់ជាសម្ងាត់ ពួកលន់នល់ គាត់ចាប់ តាទូ ជាសម្ងាត់នៅថ្ងៃ២០ កក្កដា ១៩៦២ ដល់ខែកុម្ភៈ ១៩៦៣ ខ្ញុំភ្លេចថ្ងៃទៅហើយ មានសន្និបាទមួយតូចរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែ កាលហ្នឹងមិនទាន់ឈ្មោះបក្សកុម្មុយនីស្តកម្ពុជាទេ នៅជាបក្សពលករកម្ពុជាចាត់តាំង ប៉ុល ពត ជាលេខាជំនួស តាទូ ។ ឯចំណែក ពូ នួន នៅតែជាអនុលេខាដដែល ។ ពេលហ្នឹងហើយដែលមាគ៌ាវាចាប់ផ្តើមដើរទៅតាមទិសមួយដែលមិនស្របជាមួយនឹងទិសរបស់ ហូជីមិញ គឺទិសសហព័ន្ធឥណ្ឌូចិន ។ បក្សតែមួយ កងទ័ពតែមួយ រដ្ឋា-ភិបាលតែមួយ ប្រទេសតែមួយ គឺសហព័ន្ធឥណ្ឌូចិន គឺមិនស្របគ្នាទេ ខុសគ្នា ។

[១១:២៨:០៦]

ឆ្នាំ១៩៦០ ចាប់ផ្តើមបក្សកុម្មុយនីស្តកម្ពុជាកកើត ។ លោកជំនាញលោកមានប្រសាសន៍ថា ប្រជុំគ្នាម្ភៃនាក់ ខ្ញុំជម្រាបដោយស្មោះត្រង់ទៅម្ភៃនាក់ហ្នឹង ប្រហែលជាពាក្យដែល ប៉ុល ពត និយាយលម្អទេ តាមខ្ញុំលួចឲ្យគេសួរ ជូ ជេត ហៅស៊ី នៅពេលដែល ជូ ជេត ហៅស៊ី គាត់ទៅជាប់នៅស-២១ មិនដល់ម្ភៃនាក់ទេ ។ ចំនួនម្ភៃនាក់ហ្នឹង ប្រហែលជានិយាយលម្អទេ ។ នៅក្នុងពេលកកើតបក្សដំបូងនោះ វាមានឯកសារពីរជាគ្រឹះ ។ ឯកសារទីមួយ គេហៅថា "មាគ៌ានយោបាយជាយុទ្ធសាស្ត្រនៃការតស៊ូបដិវត្តន៍នៅកម្ពុជា និងយុទ្ធវិធីប្រមូលកម្លាំងរណៈសិរ្សធំទូលាយ ដើម្បីវាយឈ្នះខ្មាំងក្នុងរយៈកាលបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ" នេះឯកសារទីមួយ ។ ឯកសារទីពីរ គឺលក្ខន្តិកៈបក្សពលករកម្ពុជា ។ លក្ខន្តិកៈដំបូង គឺអនុម័តនៅថ្ងៃនុំងឯង ហើយជ្រើសរើសមជ្ឈិមបក្សនៅពេលនុំង ។ នេះខ្ញុំងាកនិយាយទៅខាងដើម ។ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាដែលចាប់ផ្តើមបដិសន្ធិឡើងនោះ ឈ្មោះថា "បក្សពលករកម្ពុជា" វាចាប់កំណើតបែបនេះ ហើយវាមានមាគ៌ាវាមួយដែលមិនដូចគ្នានឹងមាគ៌ាបក្សកុម្មុយនីស្តឥណ្ឌូចិនរបស់ហូជីមិញ ហើយជាស្រេច ។

ដូច្នេះ ទំនាស់មនោគមវិជ្ជា វាជ្រាលជ្រៅ ។ សូមបញ្ជាក់ថា នៅពេលនេះនៅលើសាកលលោក ម៉ៅ សេទុង គាត់បដិសេធនៃ *(ស្តាប់មិនបាន)* ។ នៅចិនបដិសេធបក្សកុម្មុយនីស្តសូវៀត ដែលចង់គ្រប់គ្រងគាត់មិនឲ្យគាត់មានស្វ័យភាព មិនឲ្យគាត់មានឯករាជ្យ ហើយជាពិសេសអ្នកតស៊ូទាំងអស់សុទ្ធតែទទួលស្គាល់នូវពាក្យស្លោកកុម្មុយនីស្តមួយដែលគេថា "វណ្ណៈអធនសាកលលោករួមសាមគ្គីគ្នាឡើង គ្មាន

បក្សណាធំ គ្មានបក្សណាតូច” នេះអន្តរជាតិនិយមវណ្ណៈអធន ។ ចិនប្រឆាំងសូវៀត ដូច្នេះ ប៉ុល ពត ក៏គាត់ប្រឆាំងទៅនឹង ឡេយន់ ដែរ ។ ឆ្នាំ១៩៦៩ ហូជីមិញ គាត់ស្លាប់បាត់ទៅហើយ ឡេយន់ គេបន្ត ។ នេះហើយ ដែលពេល ឡេយន់ គេបន្តនេះទ្រឹស្តីដែលលោកជំនាញលោកមានប្រសាសន៍មិញថា ចេញពីមាត់របស់នេះ ផាំ វ៉ាន់ដុង ។

ដូច្នេះ យើងមើលលើផ្លូវនយោបាយវាហាក់ដូចជាស្រាលទេ ក៏ប៉ុន្តែ យើងមើលទំនាស់បក្សពីរមាគ៌ាពីរខុសគ្នា ។ មួយចង់ក្រសោបខ្មែរ លាវ វៀតណាម ឡាវ វៀតណាមឲ្យទៅជាប្រជាជនតែមួយ ឯចំណែកមួយទៀតចង់នៅស្មើភាពរៀងខ្លួន ។ ជ្រាលជ្រៅណាស់ ទំនាស់នេះជ្រាលជ្រៅណាស់ បុគ្គលពីរនាក់នេះទំនាស់គ្នាមែន ទ្រឹស្តីតែវាជាទំនាស់ជ្រាលជ្រៅ ទំនាស់ស្លាប់រស់ ហ្នឹងហើយដែលខ្ញុំជម្រាបជូនអង្គប្រជុំថាជាទំនាស់ស្លាប់រស់ ។ បើមាគ៌ាមួយវាស្ថិតថេរ មាគ៌ាមួយទៀតគឺត្រូវស្លាប់ បើមាគ៌ាឯករាជ្យម្ចាស់ការវាមានអត្ថិភាពនៅកម្ពុជា មាគ៌ាសហព័ន្ធឥណ្ឌូចិនវាស្លាប់នៅកម្ពុជា ហ្នឹងដែលខ្ញុំនិយាយថា ទំនាស់ស្លាប់រស់ ។

[១១:២៨:២១]

ដូច្នេះ សូមបញ្ជាក់លោកប៉ុណ្ណឹង ។ ទំនាស់វារូបភាពទំនាស់បុគ្គលមែន តែជាទំនាស់មាគ៌ាពីរមិនដូចគ្នា ។ បុគ្គលមួយមានបក្ស បុគ្គលមួយទៀតក៏មានបក្ស បុគ្គលមួយមានកងទ័ព បុគ្គលមួយទៀតក៏មានកងទ័ព នេះទំនាស់ហ្នឹង ។ ដូច្នេះ អាក្រោយ១៩៧៥ ដែលបក្សទាំងពីរមានប្រទេសកាន់កាប់ មានរដ្ឋអំណាចកាន់កាប់ កងទ័ពនៅក្នុងដៃវាទាំងសងខាងវាបុកគ្នា ។ ដូច្នេះ អាណាបង្ករឿងយ៉ាងម៉េចៗ ស្ថិតនៅក្នុងក្របខ័ណ្ឌហ្នឹង ក្របខ័ណ្ឌទំនាស់មាគ៌ាហ្នឹង ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមចប់ ។

**កញ្ញា ទី ស្រីនណា៖**

សូមអរគុណចំពោះការឆ្លើយបំភ្លឺរបស់លោក ។

**ប្រធានអង្គជំនុំ៖**

កិច្ចបន្តនេះ សូមប្រគល់វេទិកានេះទៅលោក ហ្វ្រង់ស្វ័រ រូ ដែលជាមេធាវីការពារក្តី ។ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណលោក ចាន់ដា ដែលលោកអនុញ្ញាតឲ្យខ្ញុំសួរសំណួរមួយចំនួន ឬក៏អនុញ្ញាតឲ្យខ្ញុំស្តាប់នូវសេចក្តីសង្កេតនិងសក្ខីកម្មរបស់លោកបន្ទាប់ពីនេះទៅ ។ ខ្ញុំជឿថា

មេធាវីការពារក្តីត្រូវតែពន្យល់ជូនលោក គឺហើយនិងអ្វីដែលលោកនឹងពន្យល់ជូនយើងខ្ញុំនៅក្នុងពេលនេះ ហើយការិយាល័យរបស់សហព្រះរាជអាជ្ញា គឺបានព្យាយាមបង្ហាញ និងធ្វើការសុំសេចក្តីសម្រេចពីអង្គសវនាការ ។

ហើយខ្ញុំនឹងសូមអានកថាខណ្ឌ១៦ នៃសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ។ លោកចាន់ដា ខ្ញុំសូមធ្វើការពន្យល់ថា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា គឺជាឯកសារដែលសហព្រះរាជអាជ្ញាបានបង្កើតនៅពេលបញ្ចប់ដំណាក់កាលស៊ើបអង្កេត ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ដូច្នេះ ដីកានេះគឺជាសេចក្តីបញ្ចប់ដែលធ្វើឡើងក្រោយពីការស៊ើបអង្កេត នៅក្នុងដីកានេះកថាខណ្ឌ២១៦ គឺបង្ហាញដូចខាងក្រោម៖

ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដែលបានលើកឡើងនៅក្នុងដីកាស្ថាពរនេះ គឺស្តីអំពីឯកសារផ្សេងៗដែលថា ឯកសារនេះបានបង្ហាញជម្លោះប្រដាប់អាវុធអន្តរជាតិកើតឡើងក្នុងអំឡុងពេលកងកម្លាំងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យចាប់ពីខែមេសា ឆ្នាំ១៩៧៥ នឹងបន្តរហូតដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។ ដូច្នេះ ខ្ញុំលើកឡើងដូច្នេះ ដើម្បីឲ្យលោកយល់ឲ្យបានច្បាស់ទៅលើបញ្ហានេះ ។

សំណួររបស់ខ្ញុំដែលមិនត្រឹមតែសំណួរបញ្ហានយោបាយទេ តែវាជាសំណួរផ្លូវច្បាប់ផង ហើយវាអាចមានផលលំបាក និងលទ្ធផលទៅបញ្ហានេះ ។ នៅពេលដែលជម្លោះប្រដាប់អាវុធកើតឡើងចាប់ពីខែមេសា ឆ្នាំ១៩៧៥ គឺវាមានន័យថា អ្នកទោសវៀតណាមទាំងអស់ដែលត្រូវបានបញ្ជូនទៅស-២១ ចាប់ពីថ្ងៃមក គឺជាអ្នករងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាម ។ ដូច្នេះ នេះជាអ្វីដែលវាពាក់ព័ន្ធទៅនឹងសំណួររបស់ខ្ញុំ ។ ដោយសារតែ ឌុច គឺគាត់មិនចាប់អារម្មណ៍ទៅលើជម្លោះប្រដាប់អាវុធនោះទេ។ ហើយ ឌុច បានលើកឡើងហើយថា នៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ គឺមានជម្លោះជាចំហរវាងកម្ពុជានិងវៀតណាម ។

ដូច្នេះហើយ គឺខ្ញុំសូមលើកឡើងថា ក្នុងអំឡុងឆ្នាំ១៩៧៨ អ្នកទោសវៀតណាម គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាម ហើយក្រោមការទទួលខុសត្រូវជាមេធាវីរបស់ខ្ញុំ គឺខ្ញុំទទួលយកអង្គហេតុនេះ ។ តើលោកថា ការជម្លោះប្រដាប់អាវុធ គឺមិនពាក់ព័ន្ធទៅនឹងលទ្ធភាពរបស់ ឌុច ទេ ឬក៏យ៉ាងម៉េច? ហើយខ្ញុំសូមទាញចំណាប់អារម្មណ៍អង្គសវនាការអំពីការទទួលខុសត្រូវដែលសហព្រះរាជអាជ្ញាចង់ឲ្យប្រព័ន្ធតុលាការយុត្តិធម៌ធ្វើការពិចារណា ។ ហើយមកដល់ពេលនេះ គឺយើងបានឮជាដរាបអំពីជម្លោះប្រដាប់អាវុធអន្តរជាតិចាប់ផ្តើមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ក្រោយពីការផ្តាច់ទំនាក់ទំនងការទូត ហើយសហព្រះរាជអាជ្ញា គឺសូមឲ្យអង្គសវនាការធ្វើការចេញសេចក្តីសម្រេចទៅលើកាលបរិច្ឆេទនោះ ។

ដូច្នេះ គឺខ្ញុំសូមអភ័យទោសចំពោះការពន្យល់ដ៏វែងដូច្នេះ ។ ដូច្នេះ ខ្ញុំលើកឡើងនៅទីនេះថា សហព្រះរាជអាជ្ញា គឺព្យាយាមអញ្ជើញលោក ហើយចង់ជួបលោកដើម្បីឱ្យលោកបញ្ជាក់ទៅលើចំណុចអង្គហេតុសាមញ្ញមួយនេះតែប៉ុណ្ណោះ គឺជម្លោះប្រដាប់អាវុធអន្តរជាតិដែលកើតឡើងរវាងកម្ពុជានិងវៀតណាមចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ ។ ហើយខ្ញុំសង្កេតថា លោកមិនបានបញ្ជាក់ទៅលើអង្គហេតុដូច្នេះនេះទេ ។ ហើយសង្កេតថា លោកបានលើកឡើងផ្ទុយទៅលើចំណុចនេះ ។ ហើយខ្ញុំបានធ្វើការកត់ត្រាពីអ្វីដែលលោកបានលើកឡើង គឺលោកបានលើកឡើងថា មានការវាយរប៉េះរប៉ោះមួយចំនួន ហើយមានការប៉ះទង្គិចរវាងកងទ័ពទាំងសងខាង ។ ហើយព្រឹកមិញលោកនិយាយថា នៅចុងឆ្នាំ១៩៧៩ លោកយល់ឃើញថា វៀតណាម គឺបានបញ្ចប់ ប៉ុន្តែ វាមិនមែនការចេញពីការស្វែងយល់រវាងគ្នានិងគ្នានោះទេ ។

កាលពីម្សិលមិញលោកបាននិយាយថា មកដល់ឆ្នាំ១៩៧៧ រដ្ឋាភិបាលវៀតណាមបានព្យាយាមក្នុងការរារាំងជម្លោះប្រដាប់អាវុធពីការកើតឡើងនេះ ។ តើដូច្នេះដែរឬទេ លោក ណាយ៉ាន់ ចាន់ដា?

[0៩:00:00]

**ឆ៖** គឺត្រឹមត្រូវ ។ វៀតណាមសង្ឃឹមទុកថា ជម្លោះនោះនឹងអាចដោះស្រាយបានតាមរយៈការចរចាតាមការទូត ឬក៏ការផ្លាស់ប្តូររវាងការយល់ឃោគគ្នានៅក្នុងបក្សកុម្មុយនីស្តទាំងពីរ នេះគឺជាការយល់របស់ខ្ញុំថា ហេតុអ្វីបានជាមានការប៉ុនប៉ងក្នុងការលាក់បាំងបញ្ហាសង្គ្រាមនេះ ។ ហើយនេះគឺជាការចង្អុលបង្ហាញរបស់អ្នកសារព័ត៌មានអន្តរជាតិទាក់ទងទៅនឹងការយល់ឃើញទៅលើជម្លោះនេះ ។ ហើយដែលថា វាជាជាងការធ្វើឱ្យជម្លោះនេះបើកជាចំហ ហើយខ្ញុំមិនដឹងថា តើយើងកំណត់និយមន័យសង្គ្រាមនោះយ៉ាងម៉េចទេ? ហើយសង្គ្រាមត្រូវតែប្រកាសឡើងជាសាធារណៈ ឬក៏យ៉ាងម៉េច? ហើយថា តើសង្គ្រាមអាចកើតឡើងដែរឬទេ បើសិនជាមិនប្រកាស? ប្រសិនបើសង្គ្រាមធ្វើឡើងដោយមិនចាំបាច់ប្រកាសនោះគឺថា សង្គ្រាមនេះវាកើតរវាងកម្ពុជានិងវៀតណាម គឺកើតក្នុងឆ្នាំ១៩៧៥ ។ ហើយប្រសិនបើមានការត្រូវតែធ្វើការប្រកាសអំពីសង្គ្រាម ខ្ញុំគិតថា សង្គ្រាមវាត្រូវកើតឡើងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោក ចាន់ដា សូមអរគុណដែលលោកបានធ្វើការផ្តល់ជូននូវចម្លើយផ្សេងៗ ដើម្បីយើងស្វែងរកយុត្តិធម៌ ។ ខ្ញុំអត់មានសំណួរបន្ថែមទៀតទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា តទៅទៀតទេ?

ដោយដំណើរការនីតិវិធីនៃដំណើរការសួរដេញដោលលើអ្នកជំនាញ ណាយ៉ាន់ ចាន់ដា ពាក់ព័ន្ធជាមួយនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ឃើញថា បានដល់ទីបញ្ចប់ហើយ ហើយអង្គជម្រះសូមថ្លែងអំណរគុណដល់លោក ណាយ៉ាន់ ចាន់ដា ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ឆ្លៀតឱកាសមកផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះនៃអ.វ.ត.កនេះ ។ អង្គជម្រះសូមជម្រាបទៅភាគីផងដែរថា ដោយសារគម្រោងផែនការនៃដំណើរការសវនាការរបស់យើងបានកំណត់ថា ប៉ាន់ស្មានទៅថា អាចធ្វើសវនាការលើអ្នកជំនាញ ណាយ៉ាន់ ចាន់ដា រហូតដល់ពីរថ្ងៃ ប៉ុន្តែឥឡូវនេះយើងធ្វើត្រឹមតែមួយថ្ងៃកន្លះប៉ុណ្ណោះ ។ អ៊ីចឹងសូមជម្រាបដល់ភាគីថា នៅរសៀលនេះ យើងនឹងធ្វើសវនាការបន្តលើការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ក្រេក អេតឆេសាន់ ជាបន្តទៀត ។ អ៊ីចឹងសូមភាគីទាំងអស់ជ្រាប ហើយអង្គជម្រះដោយសូមប្រកាស ដោយសារដល់ពេលអាហារថ្ងៃត្រង់ហើយ គឺសូមប្រកាសសម្រាកសម្រាប់ធ្វើសវនាការថ្ងៃនេះត្រឹមនេះ ហើយលើកទៅបន្តនៅរសៀលវេលាម៉ោងមួយកន្លះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។ ហើយភាគីផ្សេងទៀតដូច្នោះដែរ ហើយដោយឡែកក្រឡាបញ្ជីសូមធ្វើការទាក់ទងជាមួយនឹងបណ្ឌិត ក្រេក អេតឆេសាន់ ដើម្បីអញ្ជើញគាត់មកធ្វើសក្ខីកម្មនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ ។ ហើយមន្ត្រីតុលាការក៏សូមសម្របសម្រួលដល់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ដើម្បីឲ្យគាត់មានលទ្ធភាពបានវិលត្រឡប់ទៅរកកន្លែងស្នាក់នៅរបស់គាត់វិញ ។

*[សវនាការសម្រាកពីម៉ោង ១១:៤១នាទី ដល់ម៉ោង ១៣:៣២នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការដេញដោលលើអង្គហេតុអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស-២១ តទៅទៀត ដោយសួរដេញដោលលើអ្នកជំនាញ ក្រេក អេត

ឆេសាន់ ដែលយើងបានធ្វើដំណើរការសួរដេញដោលសប្តាហ៍កន្លងមក ប៉ុន្តែមិនទាន់ចប់ ។ មន្ត្រីតុលាការ សូមអញ្ជើញបណ្ឌិត ក្រេក អេតឆេសាន់ ចូលមកកាន់សាលសវនាការ ។

លោកបណ្ឌិត ក្រេក អេតឆេសាន់ ថ្ងៃនេះអង្គជំនុំជម្រះអញ្ជើញលោកមកដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញជាបន្ត ដោយកាលកិច្ចពិភាក្សាដេញដោលកាលពីសប្តាហ៍មុន យើងធ្វើមិនទាន់ ដោយមានកាលៈទេសៈពិសេសនៃការដំណើរការសវនាការលើអ្នកជំនាញមួយរូបទៀត ណាយ៉ាន់ ចាន់ដា ដែលគាត់មានភារៈមមាញឹក ដែលមានឱកាសត្រឹមតែពីម្សិលមិញនិងថ្ងៃនេះ ឥឡូវយើងបានធ្វើចប់ហើយ។

អ៊ីចឹងគឺ ជាកិច្ចបន្តនេះ គឺសូមប្រគល់វេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីធ្វើការសួរដេញដោលលើអ្នកជំនាញរូបនេះជាបន្ត ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនៅសំណួរប្រហែលជាមួយ ឬក៏ពីរទៀតតែប៉ុណ្ណោះ ។ សូមសួស្តីលោក ក្រេក អេតឆេសាន់ អ៊ីចឹងយើងអាចតនូវអ្វីដែលយើងបានទុកចោលកាលពីអាទិត្យមុន ។ ខ្ញុំនឹងលើកឡើងដេញដោលជាមួយនឹងលោកនៅក្នុងឯកសារលេខ៧៥ នៅក្នុងឧបសម្ព័ន្ធរបស់លោក គឺទាក់ទងទៅនឹងកិច្ចប្រជុំ *កាមរ៉ាត តាល់* នៅកងពល១៧០ ចុះខែកញ្ញា ឆ្នាំ១៩៧៦ ដែលមានលេខ ERN002233 00002235 ជាភាសាខ្មែរ និង00182791 រហូតដល់ 92 ជាភាសាអង់គ្លេស និង 001407 រហូតដល់ 000014-22440709 លោកបានឆ្លើយតបទៅនឹងខ្សែទំនាក់ទំនងនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ហើយនេះគឺជាការបង្ហាញនៅក្នុងឯកសារហ្នឹង ។

ហើយខ្ញុំចង់ធ្វើការបន្តដេញដោលទៅលើឯកសារនេះទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយជាពិសេសនោះគឺគោលនយោបាយក្នុងការកម្ទេចខ្មាំង ។

[១៣:៣៧:៤៩]

មុនពេលខ្ញុំធ្វើការសួរលោក ប្រហែលជាយើងអាចចាំថា ចាំនូវអ្វីដែលក្រឡាបញ្ជីបានអានកាលពីអាទិត្យមុន ។ ហើយខ្ញុំសូមសួរលោកប្រធាន ថាតើយើងអនុញ្ញាតឲ្យខ្ញុំគួរតែអានជាភាសាអង់គ្លេសឡើងវិញដែរឬទេ? ឬក៏លោកប្រធានចង់ឲ្យធ្វើការអានជាភាសាខ្មែរទៅលើអត្ថបទនោះសាជាថ្មី ។ ប្រហែលជាមានប្រាំបីឃ្លា ប្រាំបីបន្ទាត់ ដើម្បីឲ្យសាក្សីគាត់ធ្វើការបញ្ជាក់ទៅលើប្រាំបីបន្ទាត់នោះ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីមានឯកសារនុ៎ងទេ? រកឃើញនៅ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំមានឯកសារនេះនៅក្នុងអេក្រង់របស់សហព្រះរាជអាជ្ញា ។ ហើយប្រសិនបើអង្គសវនាការបង្គាប់នោះ គឺអាចធ្វើការផ្លាស់ប្តូរចរន្តអេក្រង់ ពីខាងសោតទស្សន៍ ហើយធ្វើការបញ្ចាំងនៅអេក្រង់របស់កុំព្យូទ័រខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសគឺរៀបចំភ្ជាប់ប្រព័ន្ធមកជាមួយនឹងរបស់ខាងសហព្រះរាជអាជ្ញា ។

បង្គាប់ឲ្យខាងបច្ចេកទេសរៀបចំភ្ជាប់ប្រព័ន្ធនេះ មកជាមួយនឹងខាងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។ អាចធ្វើបានទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំគិតថា យើងគួរតែរង់ចាំការភ្ជាប់ទៅលើកុំព្យូទ័រ បានន័យថា ឲ្យកុំព្យូទ័ររបស់ខ្ញុំគឺផ្តាច់ជាមុនសិនបន្ទាប់មក គឺថានឹងមានការភ្ជាប់ទៅលើកុំព្យូទ័រនេះឡើងវិញ ។ ដូច្នេះជាបឋម គឺខ្ញុំសូមធ្វើការផ្តាច់ចរន្តកុំព្យូទ័រនេះសិន បន្ទាប់មកនឹងមានការភ្ជាប់ពីខាងសោតទស្សន៍ ។

ដូច្នេះ នៅពេលនេះយើងអាចមើលឃើញហើយនៅលើអេក្រង់នេះ ខ្ញុំមិនស្នើឲ្យក្រឡាបញ្ជីអានគ្រប់ទៅលើចំណុចនៅក្នុងប្រអប់នេះទេ ។ ប្រហែលក្រឡាបញ្ជីអាចបង្គាប់ឲ្យអានកថាខណ្ឌបន្ទាប់ពីឈ្មោះ។ លោកប្រធាននឹងពិនិត្យឃើញ គឺមានសញ្ញាបាតដៃនៅជិតកថាខណ្ឌដែលខ្ញុំស្នើសុំឲ្យធ្វើការអាន។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននូវកថាខណ្ឌដែលសហព្រះរាជអាជ្ញាបានស្នើសុំនេះ ចាប់ពីឈ្មោះស្នើនេះ រហូតដល់ក្រោម នៅក្នុងរង្វង់បន្ទាត់ក្រហម ។

[១៣:៤២:២៨]

**លោកស្រី សែ កុលវុឌ្ឍី៖**

ឈ្មោះស្នើនេះ គឺស-២១ និងកងពល១៧០ ប្រជុំគ្នាសម្រេច ក្រៅពីដប់មួយនាក់ ដែលប្រជុំសម្រេចពីថ្ងៃ១៥ ខែ៩ ។

១) ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពល ឃើញសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ពួកខ្សែស្រឡាយ អាចក្រី ត្រូវយកអង្គប្រជុំយល់ស្របសម្រេចយកឈ្មោះទាំងម្តែ--

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែសូមអធ្យាស្រ័យ សូមឲ្យក្រឡាបញ្ជីអានម្ដងទៀត ព្រោះលឿនពេកទាន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺថា--

**ប្រធានអង្គជំនុំ៖**

សូមក្រឡាបញ្ជីអានម្ដងទៀត ដោយសារមានបញ្ហាការបកប្រែ ហើយបើអានឲ្យយឺតជាងនេះ ដើម្បីឲ្យអ្នកបកប្រែហ្នឹងអាចបកទាន់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ឈ្មោះស្នើនេះ គឺស-២១ និងកងពល១៧០ ប្រជុំគ្នាសម្រេច ក្រៅពីដប់មួយនាក់ ដែលប្រជុំសម្រេចពីថ្ងៃ១៥ ខែ៩ ។

១) ឈរលើហេតុផលបញ្ជាក់របស់ ស-២១ និងកងពល ឃើញសកម្មភាពជាក់ស្ដែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ពួកខ្សែស្រឡាយ អាចក្រី ត្រូវយកអង្គប្រជុំយល់ស្របសម្រេចយកឈ្មោះទាំងម្ភៃប្រាំបួននាក់នេះទៀត ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ ។ គឺលោកប្រធានសូមបង្គាប់ឲ្យក្រឡាបញ្ជីអាននូវប្រអប់ពណ៌ក្រហម ដែលមាននៅខាងក្រោមនេះ ។ ហើយខ្ញុំនឹងយកសញ្ញាដៃនោះ នឹងដាក់ចូលប្រអប់ណាដែលខ្ញុំស្នើសុំឲ្យអាន ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននូវប្រអប់ខាងក្រោម ចាប់ពីលេខមួយ ។

[១៣:៤៥:០០]

**លោកស្រី សែ កុលវុឌ្ឍី៖**

១) ត្រូវធ្វើតាមពិសោធន៍របស់យើងដែលបានធ្លាប់យកពួកនេះជាបន្តបន្ទាប់ ធ្វើម៉េចកុំឲ្យអង្គភាពជ្រួលច្របល់ ។ ក្ដាប់អង្គភាពឲ្យជាប់ក្នុងដៃ និងរក្សាការសម្ងាត់ឲ្យបានល្អ ។ ជាក់ស្ដែងពិគ្រោះពិភាក្សាវិធីដំណើរការជាមួយស-២១ ដើម្បីយក និងចាត់តាំងគ្រប់គ្រងអង្គភាពក្នុងពេលដកពួកវាចេញ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអនុញ្ញាតលោកប្រធាន ឲ្យបង្គាប់ក្រឡាបញ្ជីធ្វើការអានអត្ថបទនៅចុងក្រោយ ដែលមានសរសេរនៅក្នុងប្រអប់ពណ៌ក្រហម ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី អាននូវអត្ថបទចុងក្រោយមួយទៀតចាប់ពីលេខមួយបន្ទាប់ពីលេខមួយ ក្នុងបន្ទាត់**រង្វង់ក្រហមនេះ ។**

**លោកស្រី សៃ កុលវុឌ្ឍី៖**

១) ខាងកងពល២៨០ ត្រូវស-២១ និងកងពលសហការគ្នាចាប់យកពីកន្លែងដាក់ឡានតែម្តង ។

២) ខាងកងពល១៧០ ត្រូវស-២១ និងកងពលពិគ្រោះគ្នាយកវិធានការល្បិតជាក់ស្តែង ដើម្បីយកពួកទាំងសៃសិបនាក់ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោកប្រធាន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

វាបង្ហាញឲ្យឃើញថា អ្នកបកប្រែភាសាបារាំងគឺមានភាពលំបាកក្នុងការបកប្រែអ្វីដែលគាត់បកតមក បានន័យថា វាមានចំណុចមួយចំនួនដែលបានបាត់ ។ ដូច្នេះ អត្ថបទនេះគួរតែអានឡើងវិញ ហើយធ្វើការបកប្រែឡើងវិញ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកចៅក្រមបើសិនជាយើងអាចធ្វើទៅបាននោះ យើងគួរតែមានឯកសារជាភាសាបារាំង ហើយធ្វើការអានដើម្បីធ្វើការកត់ត្រានៅក្នុងប្រតិចារឹក ។

[១៣:៤៧:៥២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តី ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធានជាទីគោរព! ជាការពិតការបកប្រែជាភាសាបារាំងដែលយើងទទួលបានគឺវាមិនស៊ីគ្នាបេះបិទទៅនឹងការបកប្រែដែលយើងទើបតែបានស្តាប់អម្បាញ់មិញនោះទេ ។

ដូច្នេះ ខ្ញុំមិនមានបំណងណាមួយដែលបានបកប្រែជាភាសាបារាំងហើយ ឲ្យអានឡើងវិញនោះទេ ។ ប៉ុន្តែ អ្វីដែលខ្ញុំស្នើសុំនិងចង់បាននៅទីនេះគឺគួរតែយើងអានជាភាសាខ្មែរ ហើយធ្វើការបកប្រែផ្ទាល់មាត់ទៅលើកថាខណ្ឌចុងក្រោយទាំងពីរ ។ ខ្ញុំចង់ឲ្យអានកថាខណ្ឌទីមួយ នៅក្នុងចំណុចទីមួយនោះ សូមឲ្យអានឡើងវិញដោយមានភាពមិនស៊ីគ្នាទៅនឹងការបកប្រែជាលក្ខណៈប្រដេញនេះ ។ ហើយអ្វីដែលខ្ញុំមាន ឯកសារដែលខ្ញុំមានគឺការបកប្រែឯកសារជាភាសាបារាំង ។ ដូច្នេះហើយ គឺខ្ញុំស្នើសុំលោកប្រធានឲ្យធ្វើការស្នើសុំឲ្យអានកថាខណ្ឌទីមួយ អម្បាញ់មិញនេះ គឺឡើងអានបញ្ជាក់ឡើងវិញទៅលើបញ្ហានេះ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

បញ្ហាលំបាកមួយនោះ បញ្ហាលំបាកចំពោះអ្នកបកប្រែនោះ គឺដោយសារតែវាជាការបកៗតគ្នាហើយត្រូវការបកភ្លាមៗ ។ ហើយប្រសិនបើមានឯកសារបកប្រែជាភាសាបារាំងនៅចំពោះមុខហើយនោះ គឺវាដូចទៅនឹងឯកសារដែលអ្នកបកប្រែមាននៅចំពោះមុខខ្លួន ។ ហើយខ្ញុំក៏មិនជំទាស់ទៅនឹងការស្នើឡើងដោយមេធាវីការពារក្តីនោះ ។ ហើយប្រសិនបើមេធាវីការពារក្តីសុំឲ្យអានចំណុចទីមួយឡើងវិញនោះ គឺខ្ញុំយល់ព្រមទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអាននូវចំណុចទីមួយម្តងទៀត ។ ចាប់ផ្តើមអាន ។

[១៣:៥០:៣៤]

**លោកស្រី សែ កុលវុឌ្ឍី៖**

ឈ្មោះស្នើនេះ គឺស-២១ និងកលពល១៧០ ប្រជុំគ្នាសម្រេចក្រៅពីដប់មួយនាក់ ដែលប្រជុំសម្រេចពីថ្ងៃ១៥ ខែ៩ ។

១) ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពល ឃើញសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ។ ពួកខ្សែស្រឡាយ អាចក្រី ត្រូវយកអង្គប្រជុំយល់ស្របសម្រេចយកឈ្មោះទាំងម្ភៃប្រាំបួននាក់នេះទៀត ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

មានបញ្ហាក្នុងការបកប្រែ វាជាបញ្ហាសំខាន់ អ្វីដែលខ្ញុំឮជាភាសាបារាំងនៅពេលនេះគឺថា ដើម្បីសម្រេច តើនឹងធ្វើអ្វីទៅលើឈ្មោះអស់ទាំងនុង់? ប៉ុន្តែ អត្ថបទដែលខ្ញុំមាននៅចំពោះមុខខ្ញុំនេះ និយាយថាអ្នកចូលរួមនៅក្នុងអង្គប្រជុំបានសម្រេចទៅលើការចាប់ឈ្មោះរបស់អ្នកម្ភៃប្រាំបួននាក់នោះ ។

ដូច្នេះ ចំណុចទាំងពីរនេះគឺមិនស៊ីគ្នាទេ ។ ទីមួយមានន័យថា ការចាប់នឹងបានឯកភាពហើយ ប៉ុន្តែពីរគឺថាតើគេនឹងធ្វើសេចក្តីសម្រេចយ៉ាងម៉េចទៅលើអ្នកអស់ទាំងនុង់?

ដូច្នេះ ខ្ញុំចង់ដឹងថាតើភាសាខ្មែរនឹងវាមានន័យយ៉ាងម៉េច? ខ្ញុំបានឮការបកប្រែប្រដេញដែលបង្ហាញថា ដើម្បីសម្រេចថាត្រូវធ្វើដូចម្តេចចំពោះអ្នកទាំងម្ភៃប្រាំបួននាក់នោះ ដែលការបកប្រែនេះ វាមិនស៊ីគ្នាទៅនឹងឯកសារបារាំងដែលខ្ញុំមាននៅក្នុងដៃរបស់ខ្ញុំនេះទេ ។ ហើយវាក៏មិនស៊ីគ្នាទៅនឹងការបកប្រែជាភាសាអង់គ្លេសដែលខាងសហព្រះរាជអាជ្ញាមានដែរ ។ នេះគ្រាន់តែជាការកត់សម្គាល់របស់ខ្ញុំ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ក្នុងពេលដែលពិនិត្យមើលទៅលើឯកសារដើម យើងត្រូវតែចាត់ទុកឯកសារដើមគឺជាឯកសារដែលមានតម្លៃជាងគេ ។ ខ្ញុំបានឯកភាពជាមួយនឹងលោក ហ្វ្រង់ស្វ័រ រូ គឺមានភាពផ្សេងគ្នាបន្តិចនៅក្នុងការបកប្រែ ហើយនៅក្នុងអ្វីដែលយើងមានជាភាសាអង់គ្លេសនេះ គឺវាស៊ីគ្នាទៅការបកប្រែជាភាសាបារាំង ។ ឯកសារដែលខ្ញុំមានដែលមាននៅក្នុងសំណុំរឿង ជំនួសពាក្យស-២១ និងពាក្យកងពលដែលបានអាននោះ គឺខ្ញុំមានពាក្យស-២១ និងកងពល២៨០ វិញ ។ ប៉ុន្តែ សំណើររបស់ខ្ញុំគឺថាអត្ថបទជាភាសាខ្មែរគឺជាអត្ថបទគោល ហើយការបកប្រែនៅពេលនេះ យើងនឹងអាចពិភាក្សានៅពេលក្រោយបើសិនជាយើងមានការលំបាកនៅក្នុងការបកប្រែ យើងអាចត្រូវយកចំណុចនេះមកពិចារណា ទាក់ទងទៅនឹងសំណួររបស់អ្នកជំនាញដែលខ្ញុំនឹងសួរគាត់នៅពេលនេះ ។

[១៣:៥៤:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ ជាចម្ងល់ទេ ព្រោះខ្ញុំបាទមើលជាអក្សរខ្មែរនៅក្នុងការអានអម្បាញ់មិញហាក់ដូចជាអត់ដកឃ្លា ស្តាប់ន័យអត់បាន ។ ត្រង់នេះខ្ញុំបាទសូមបញ្ជាក់ឡើងវិញបន្តិច ដែលក្រឡា

បញ្ជីគាត់អានមិញ ខ្ញុំអានបន្តិចឡើងវិញ ដើម្បីដល់កន្លែងណាដកឃ្លាឲ្យយល់ទាំងអស់គ្នា ព្រោះខ្ញុំស្តាប់ហាក់ដូចជាមិនយល់ ។

១) ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកលពល ឃើញសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់ ពួកខ្សែស្រឡាយអាចក្រីត្រូវយក ។ ចំណុចត្រង់នេះឯងដែលដកឃ្លាបន្តិច មានន័យមិនដឹង ប៉ុន្តែខ្ញុំបាទអាន ។ ដកឃ្លា អង្គប្រជុំយល់ស្រប សម្រេចយកឈ្មោះទាំងម្ភៃប្រាំបួននាក់នេះទៀត ។ នេះតាមការយល់របស់ខ្ញុំគឺថា ដូចជាដាច់វគ្គគ្នា មិនច្រឡំទេ តែខាងលោកមេធាវីការពារគាត់លើកឡើងហាក់ដូចជា ពួកខ្សែស្រឡាយអាចក្រីត្រូវយក អង្គប្រជុំយល់ស្របទៅវិញ ។ នេះខ្ញុំបាទគ្រាន់តែបញ្ជាក់ទេ ហើយការយល់របស់ខ្ញុំបាទ តើត្រឹមត្រូវឬទេ?

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទ ចង់មានយោបល់អីពាក់ព័ន្ធជាមួយនឹងខ្លឹមសារនៃអត្ថបទនេះ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំចូលប្រជុំក្នុងឯកសារនេះ ។ ខ្ញុំដឹងរឿងល្អិតជាងគេ ហើយច្បាស់ជាងគេ ។ ខ្ញុំចង់បំភ្លឺអង្គប្រជុំនៅពេលនេះ ឲ្យយល់ដល់បញ្ហា ។ តាមកាលដែលខ្ញុំចាំ ហើយខ្ញុំដែលបានធ្វើ ។ ដំបូង ខ្ញុំសូមនិយាយអំពីគោលការណ៍ដែលមាននៅក្នុងឯកសារបក្សកុម្មុយនីស្តកម្ពុជាសិន ។ ការសម្រេចកម្ទេចកងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច នេះមានចែងនៅក្នុងឯកសារថ្ងៃ៣០ ខែមីនា ១៩៧៦ ។ ក្នុងកងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច ។ ឯចំណែក ស-២១ វាជាអ្វី? ស-២១ វាជាអង្គភាពមួយដែលអចិន្ត្រៃយ៍គ្រប់គ្រងផ្ទាល់ ឈរលើលក្ខន្តិកៈបក្សមាត្រា៨ ។

ដូច្នេះ ស-២១ វាបានឯកសារ វារាយការណ៍ឲ្យមេវា ។ មេវាគឺអ្នកណា? ឈរលើឯកសារថ្ងៃ០៩ តុលា ១៩៧៥ មេវាគឺ សុន សេន ។ វារាយការណ៍ទៅ ។ ដូច្នេះ សុន សេន បានអាឯកសារហ្នឹង កោះហៅប្រជុំ អាអង្គប្រជុំនេះ គេហៅថាអង្គប្រជុំគណៈកម្មាធិការសេនាធិការបើកទូលាយ ។ អ្នកតំណាងសេនាធិការមានពីរនាក់ គឺបង៨៩ គឺ សុន សេន ហើយនិងបង៨១ គឺ ទុំ ។ ហើយបន្ទាប់មកមានមិត្តសោម, មាន ណាត នេះអង្គប្រជុំពេលនុង ។ ដល់ប្រជុំបានមួយព្រឹកបង សុន សេន គាត់ចេញទៅ នៅសល់បង៨១ ដឹកនាំការប្រជុំ ។ មានបង៨១, មានមិត្តសោម, មាន ណាត, មានមិត្តសុខ, ហើយនិងអនុលេខាគាត់ មិត្តតាត ហើយនិងមិត្តតាល់ ២៩០ នៅប្រជុំ ។

បើលោកប្រធានអនុញ្ញាតឲ្យគេថយក្រោយបន្តិច អង្គភាពនេះឃើញ ឃើញបង៨១ ចាប់ផ្ដើមប្រជុំ ដឹកនាំអង្គប្រជុំ ។ អត្ថបទនេះថយក្រោយទៀត ថយទៅទៀត មួយទំព័រទៀត បាទ ឈប់ៗៗៗ អំ! លឿនណាស់ ទៅលើវិញៗ នេះៗ បង៨៩ ចេញហើយ ។ ឥឡូវប្រជុំបន្ត បង៨១ បើកការប្រជុំ ។ ពេលនឹងនៅសល់តែបង៨១ ធ្វើប្រធាន មានមិត្តសោម, មាន១៧០ គឺមិត្តសុខ ហើយនិងមិត្តតាត ហើយមាន២៩០ ។ កិច្ចប្រជុំដំណើរការដូចពីព្រឹក ។ បង៨១ គាត់ហៅឈ្មោះ គាត់សួរយោបល់មិត្ត ។ មើលមិត្តសុខ អានេះ!

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យជនជាប់ចោទ គាត់និយាយយឺតបន្តិច អ្នកបកប្រែបកអត់ទាន់ទេ ។

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! ម្ដងទៀត សូមនិយាយម្ដងទៀត សូមនិយាយម្ដងទៀត ហើយសូមនិយាយយឺតបន្តិច ព្រោះដូចជាបញ្ហាបកប្រែ ។ សូមឲ្យច្បាស់ ព្រោះបញ្ហាដូចជាមានបញ្ហាត្រង់នេះតាំងពីថ្ងៃមុនមក អ៊ីចឹងសូមឲ្យច្បាស់តែថ្ងៃនេះតែម្ដងទៅ កុំវាមានភាពមិនច្បាស់លាស់ ។

[១៤:00:0៥]

**ជនជាប់ចោទ៖**

ប្រជុំបន្ត បង៨១ បើកការប្រជុំ បើកវារៈប្រជុំ ពិនិត្យឈ្មោះ ត្រូវយកពីកងពល២៩០ ស្មើនឹងពួកខ្មែរតំបន់២៤ និងខ្មែរចក្រី ។ នេះចំណងជើងដែលបង៨១ គាត់ឧទ្ទេសនាម ។ ដូច្នេះបង៨៩ អញ្ជើញចេញទៅបាត់ហើយ នៅតែបង៨១ទេ គាត់ដឹកនាំការប្រជុំ ។

សូមអញ្ជើញបន្តទៅទៀត ។ ដល់ការប្រជុំដែលបង៨១ គាត់ដឹងនាំធ្វើដូចពីព្រឹកអ៊ីចឹង ។ ធ្វើដូចពីព្រឹក គាត់ហៅ ឈ្មោះនេះ ម៉េច មិត្តសុខ? មិត្តសុខ លេខាកងពល១៧០ ។ ឆ្នាំនេះម៉េចមិត្តសុខ? មិត្តសុខថា យកបង ។ គាត់តទៅទៀត ចុះឈ្មោះនេះ ម៉េចទៅមិត្តសុខ? មិត្តសុខថា អ្ហែ! ខ្មែរគេទេបង ។ អីអ៊ីចឹងមិនបាច់ទេ ទុកសិន ។

សរុបទៅអង្គប្រជុំសូមឯកភាពយល់ស្របយកឈ្មោះប្អូន ខាងលើរបស់កងពល២៩០ ។

អានេះសម្ដីរបស់បង៨១ទៀតហើយ ដែលគាត់សរុប។ ហើយបង៨១ គាត់ហៅសួរ គាត់ហៅខ្ញុំសួរ ម៉េចមិត្ត ឌុច? ខ្ញុំទៅមានមតិម៉េច បើខ្ញុំអត់នៅក្នុងគណៈកម្មាធិការបើកទូលាយសេនាធិការនោះផង ។ ឈ្មោះខ្ញុំអត់នៅនុំងទេ អត់នៅក្នុងគណៈកម្មាធិការបើកទូលាយនិងសេនាធិការទេ ។ ខ្ញុំថាអត់

មានទេបង ។ មិត្តសោម គាត់រុញខ្ញុំទៀត “មិត្តឌុច មានមតិនឹងគេទៅ” ខ្ញុំថា “អត់ទេ” ។

ដូច្នេះ បង៨១ មានប្រសាសន៍តទៅទៀត ក្រោយប្រជុំមិត្តសុខ, តាត កងពល១៧០ បានឯកភាពគ្នាត្រូវស្នើយកឈ្មោះម្ភៃប្រាំបួននាក់ទៀតគឺ នេះមតិបង៨១ ។ យកឈ្មោះខ្ញុំមកបញ្ចូលក្នុង*ការ៉េ* នេះមិនល្អទេ បើទាញភ្ជាប់អ៊ីចឹងមិនស្អាតទេ ខុសរឿងដែលកើតឡើងនៅពេលនោះ ។ រឿងដែលកើតឡើងនៅពេលនោះ គឺជាអង្គប្រជុំគណៈកម្មាធិការសេនាធិការបើកទូលាយ ។ ឯចំណែកខ្ញុំវាពិតថាមានឧក្រិដ្ឋកម្មក្នុងឈ្មោះទាំងសែសិបនាក់នេះហើយ ។ ឧក្រិដ្ឋកម្មរបស់ខ្ញុំនៅត្រង់ណា? នៅត្រង់ខ្ញុំរ៉ៃគេសួរចម្លើយ ខ្ញុំឲ្យគេរ៉ៃមនុស្សសួរចម្លើយ បានចម្លើយខ្ញុំរាយការណ៍ទៅបង៨៩ ជាមេខ្ញុំ តាមគោលការណ៍ដែលមានចែងក្នុងប្រជុំអចិន្ត្រៃយ៍ថ្ងៃ៩ ខែតុលា ឆ្នាំ១៩៧៥ ។ ខ្ញុំរាយការណ៍អ៊ីចឹងតាមខ្សែសង្វាក់របស់ខ្ញុំ តាមមាគ៌ាចាត់តាំងរបស់បក្ស ។

ដល់ឧក្រិដ្ឋកម្មរបស់ខ្ញុំ គឺខ្ញុំរុញឈ្មោះហ្នឹងទៅឲ្យគេសម្រេច ឥឡូវគេសម្រេចនេះ រឿងគេទេ គណៈកម្មាធិការបើកទូលាយ ដែលមានបង៨១ ជាប្រធាន ។ ហ្នឹង សរុបមកគឺអ៊ីចឹង ។

ដូច្នេះសេចក្តីសម្រេចនេះវាគេ តែឈ្មោះហ្នឹង គឺខ្ញុំពិតជាឲ្យ ពិតជាជាប់ដល់ឧក្រិដ្ឋកម្មរបស់ខ្ញុំនេះច្បាស់លាស់ ។

ឯចំណែក ចាត់តាំងពីឃ្លានេះមកសុទ្ធតែជាឃ្លាបង៨១ទាំងអស់ ។ ការបកប្រែវាខុសត្រូវបន្តិចបន្តួចវាជារឿងធម្មតាទេ ក៏ប៉ុន្តែក្រោយពេលប្រជុំសមមិត្តសុខ សមមិត្តតាត កងពល១៧០ បានឯកភាពគ្នាត្រូវស្នើយកឈ្មោះម្ភៃប្រាំបួននាក់ទៀត ។ ខ្ញុំណាទៅមានមតិប៉ុននុ៎ង មិនមែនមតិរបស់ខ្ញុំទេ ។ ដូច្នេះយកឈ្មោះខ្ញុំមកបញ្ចូលក្នុងឃ្លាខាងក្រោមនេះខុស ។ នេះជារឿងពិតដែលខ្ញុំបានអនុវត្ត នៅពេលនុ៎ង ។ បង៨៩ អញ្ជើញទៅបាត់ហើយ។ ដល់សរុបចុងបញ្ចប់ ខ្ញុំបានរាយការណ៍ជូនថៅក្រមស៊ើបអង្កេតហើយ ខ្ញុំគេហៅទៅរង់ចាំរៀបចំអាចុងក្រោយនេះ ។ យកពីកន្លែងណា ទៅយកពីកន្លែងនោះដាក់ឡានបន្ទាន់អីៗ គឺខ្ញុំទៅចាំអាត្រង់ហ្នឹង រួចមកដល់ខ្ញុំចាត់តែឲ្យមិត្តហ៊ី ទៅជួបទៅ ។ ចាត់ចែងតាមកិច្ចដំណើរនេះនេះមែន ។

ខ្ញុំសូមបំភ្លឺប៉ុណ្ណឹង រឿងដែលខ្ញុំបានអនុវត្តនៅពេលនុ៎ង គឺអ៊ីចឹង ។ ដូច្នេះចំណែកលោក ក្រេក អេតឆេសាន់ អ្នកជំនាញ លោកមានប្រសាសន៍ពីថ្ងៃមុនតែមួយមាត់ទេ កុំភ្លេច៨៩ នៅហ្នឹង ។ អ៊ីចឹងអត់មានអ្នកណាសម្រេចអីលើស៨៩ បានទេ ។ ឥឡូវ៨៩ ចេញទៅផ្ទេរអំណាចទៅឲ្យ៨១ នេះគឺច្បាស់ ។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។ សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំមានមតិបំភ្លឺក្នុងការណ៍នេះ ។

[១៤:០៤:៣៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកអាចធ្វើការអានអត្ថបទជាភាសាខ្មែរ ដែលជាភាសាដើម ហើយអត្ថបទនេះគឺជាអត្ថបទដែលមានការត្រឹមត្រូវបំផុត ។ អ្វីដែលលោកបាននិយាយ អ្វីដែលគិត អ្វីដែលបានកើតឡើងនៅពេលនោះ ។ ប៉ុន្តែ តើលោកអាចអាននូវលើអត្ថបទនេះ ថាតើអត្ថបទនេះនិយាយថាសេចក្តីសម្រេចក្នុងការបញ្ចូលចំនួនមនុស្សមួយចំនួននៅក្នុងបញ្ជីឈ្មោះនៃអ្នកដែលនឹងត្រូវបានគេសម្រិតសម្រាំងនោះ ។ តើលោកអានថា សេចក្តីនេះគឺអាស្រ័យទៅលើមតិ ឬក៏គំនិតរបស់ស-២១ ឬក៏ហេតុផលដែលស-២១ ជាអ្នកលើកឡើង? អ៊ីចឹងខ្ញុំចង់ឲ្យលើកបញ្ជាក់ថា លោកបានឃើញអ្វីទៅដែលគេបញ្ជាក់យ៉ាងច្បាស់ដូច្នេះនៅក្នុងឯកសារនេះ ។

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព! ឈ្មោះទាំងអស់នេះៗគឺជាឈ្មោះនៅក្នុងបញ្ជី ដែលស-២១ រាយការណ៍ជូនទៅ សុន សេន ប៉ុន្មានថ្ងៃមុនរួចទៅហើយ ។ ដូច្នេះមតិការងាររបស់ស-២១ វានៅបញ្ជីនុ៎ង ។ ឯចំណែក ឈ្មោះទាំងសែសិបនាក់នៅក្នុងសម័យ *(ឮមិនច្បាស់)* ពីម្តៃប្រាំបួននាក់ គឺដកស្រង់ចេញពីបញ្ជីដែលខ្ញុំរាយការណ៍ជូន សុន សេន នុ៎ងឯង ។ បញ្ជីនេះអត់មាននៅក្នុងឯកសារនេះទេ ។

[១៤:០៧:០៣]

**លោក ហុង គឹមសួន៖**

សូមអនុញ្ញាតលោកប្រធាន សូមបន្តិច ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីចំណុចនេះ នៅក្នុងឯកសារជាភាសាខ្មែរ ដូចដែលធ្វើការបង្ហាញនៅពេលនេះ នៅលើអេក្រង់ នេះ តើឯកសារហ្នឹងមានបញ្ជាក់ដែរឬអត់ដែលថាសេចក្តីសម្រេចហ្នឹងត្រូវបានធ្វើឡើងដោយអាស្រ័យទៅលើមូលហេតុដែលបានលើកឡើងដោយស-២១ ឬក៏មិនដូច្នេះទេ? នេះគឺជាសំណួរដែលខ្ញុំចង់សួរទៅអ្នក ។

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំអត់មានមតិទេ ក៏ប៉ុន្តែស-២១ វាជូនបញ្ជីនេះទៅមិនរួចទៅហើយ ។ ដូច្នេះពេលអង្គុយនិយាយគ្នា ខ្ញុំអត់មានមតិ ។

**ស៖** ខ្ញុំមិនសួរលោកនូវអ្វីដែលលោកចងចាំចំពោះការប្រជុំនោះទេ ប៉ុន្តែ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើឯកសារនៅពេលនេះ គឺឯកសារដែលកំពុងតែបញ្ចាំងនៅលើអេក្រង់នេះ ។ តើលោកអាចបញ្ជាក់ប្រាប់ទេថា នៅក្នុងឯកសារនេះ តើមានការបញ្ជាក់ថា សេចក្តីសម្រេចចិត្តមួយចំនួនហ្នឹងត្រូវធ្វើឡើងដោយពឹងផ្អែកទៅលើហេតុផលដែលស-២១ បានលើកឡើង ។ តើឯកសារនេះមានបញ្ជាក់អំពីចំណុចនេះដែរឬអត់?

**ឆ៖** ក្នុងបញ្ជីនេះ ដែលគេចាត់យកម្តែ-- ក្នុងបញ្ជីនេះៗ គេមានឈ្មោះមនុស្សម្តែប្រាំបួននាក់ ក៏ប៉ុន្តែឥឡូវយើងបន្តទៅទៀត ។ ឥឡូវសូមមើលបន្តទៅទៀត នេះសេចក្តីសរុបរបស់បង៨១ ។ សូមត្រឡប់ទៅអត្ថបទអម្បាញ់មិញហ្នឹង ខ្ញុំមិនទាន់បានជម្រាបលោកចៅក្រមចប់ផង ។ បានៗ, ឈ្មោះស្នើនេះ គឺស-២១ និងកងពល១៧០ ប្រជុំគ្នាសម្រេច ក្រៅពីដប់មួយនាក់ ដែលប្រជុំសម្រេចពីថ្ងៃ១៥ ខែកញ្ញា ។ ពីថ្ងៃ១៥ កញ្ញា គេប្រជុំគ្នាសម្រេចម្តងហើយ តាមបញ្ជី ។ ឥឡូវនេះ គេប្រជុំគ្នាម្តងទៀត ឈរលើៗបញ្ជីដែលខ្ញុំជូនទៅ ។ ដូច្នេះ នេះជាសេចក្តីសរុបរបស់បង៨១ ឈ្មោះខ្ញុំនេះ ឈ្មោះស-២១ នេះៗគាត់រំឭកដល់ការទទួលខុសត្រូវរបស់ស-២១ ដែលបញ្ជូនបញ្ជីទៅ ។ ខ្ញុំអត់មានបាននិយាយទេ នេះជាពាក្យសរុបរបស់បង៨១ ។ នេះជាមតិសរុបរបស់បង៨១ ពីព្រោះខ្ញុំមានមុខនៅទីនោះ បញ្ជីរបស់ខ្ញុំក៏នៅទីនោះ ថ្វីត្បិតតែខ្ញុំមិននិយាយក៏ដោយក៏មានមុខនៅទីនោះ ហើយបញ្ជីខ្ញុំក៏នៅទីនោះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

*(គ្មានការបកប្រែ)*

[១៤:១១:៥៤]

**ប្រធានអង្គជំនុំ៖**

លោក ហុង គឹមសួន ចង់មាននិយាយរឿងអី?

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន អំមិញហ្នឹងខាងយើងខ្ញុំនេះ ឆ្ងល់ពីអក្សរកាត់ ចង់ឲ្យខាងលោក ឌុច ហ្នឹង គាត់មានប្រសាសន៍ឲ្យចំឈ្មោះជាតួអក្សរវិញ បើតួលេខអ៊ីចឹងយើងខ្ញុំនៅមានការភាន់ច្រឡំបាទ ។

៨៩ ហ្នឹងអ្នកណា? ៨១ អ្នកណា?

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទអាចបញ្ជាក់បានទេ ឲ្យច្បាស់លាស់ទាំងអស់គ្នា ព្រោះជាពាក្យសម្ងាត់ ឈ្មោះសម្ងាត់ឲ្យច្បាស់លាស់រវាង៨១ និង៨៩ ។ ៨១ អ្នកណាគេ? ហើយ ៨៩ ហ្នឹងអ្នកណាគេ?

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! គណៈអចិន្ត្រៃយ៍សេនាធិការ១មានបង៨៩ ជាលេខា ។ មានបង៨៩ ឈ្មោះបដិវត្ត ខៀវ ឈ្មោះដើម សុន សេន ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមបក្ស ។ ឯកចំណែក បង៨១ ឈ្មោះ ទុំ ឈ្មោះបដិវត្ត ឈ្មោះដើម សៀត ឆែ សមាជិកមជ្ឈិមត្រៀម ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមត្រៀម (សូមទោស) ជាសមាជិកមជ្ឈិមត្រៀម ជាអនុលេខាគណៈកម្មាធិការអចិន្ត្រៃយ៍សេនាធិការ ។ ឯចំណែក ក្នុងអង្គប្រជុំនេះមិនមានសមាជិកសេនាធិការចូលរួមទេ មានតែសមាជិកជំនួយការសេនា-ធិការមកចូលរួមពីរនាក់ ។ គឺ សោម ឈ្មោះដើម ពេជ ឆន ហើយនិង ណាត ឈ្មោះដើម អ៊ុន លន ។ ណាត ហ្នឹងអតីតលេខា ស-២១ ។ ដូច្នេះ សូមឆ្លើយទៅនឹងសំណួរលោក ហុង គឹមសួន ប៉ុណ្ណេះ ។ សូមចប់ ។

[១៤:១៥:១០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ បេ៊ត៖**

លោកប្រធាន គឺយើងហាក់ដូចជាមិនចូលទៅដល់បញ្ហា ដែលយើងចោទនៅទីនេះទេ ។ ហើយដោយគោរពលោក លោកស្រីចៅក្រម ជនជាប់ចោទ គឺមិនមែនជាអ្នកជំនាញនោះទេ ។ យើងមានការបកប្រែ មានអ្នកជំនាញដែលយើងត្រូវបកប្រែជាភាសាខ្មែរ និងអង់គ្លេស ហើយភាសាដើម ដែលថាយើងយកជាការបាននោះគឺភាសាខ្មែរ ។ ហើយវាមិនអ្វីជាការភ្ញាក់ផ្អើលចំពោះអង្គសវនាការ ដែលសហព្រះរាជអាជ្ញានឹងមានសំណួរជាច្រើន សម្រាប់ជនជាប់ចោទលើបញ្ហាឯកសារនេះ ។ ហើយសំណួរទាំងអស់នោះនឹងសួរនៅពេលណាមួយសមស្រប ។ ហើយនៅពេលនេះ យើងមានលោក អេតឆេសាន់ជាសាក្សីជំនាញដែលនឹងពិភាក្សាដេញដោលទៅលើបញ្ហាទំនាក់ទំនងនិងគោលនយោបាយ ។ ហើយ

លោកប្រធាន នឹងអនុញ្ញាតឲ្យខ្ញុំធ្វើការបន្តទៅលើសំណួរដែលខ្ញុំត្រៀម និងធ្វើការតាំងទៅកាន់សាក្សីជំនាញនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា បន្តការសួរដេញដោលតទៀត ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។ ហើយខាងសោតទស្សន៍អាចធ្វើការផ្លាស់ប្តូររូបភាព ទៅជារូបភាពដើមវិញបាន ។ សូមអរគុណ ។

**ស៖** លោក អេតឆេសាន់ យើងបានឮការអាននូវអត្ថបទនេះមួយចំនួន ហើយខ្ញុំនឹងមិនអានឡើងវិញនោះទេ ។ នៅពេលដែលយើងនិយាយអំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងការកម្ទេចខ្មាំង ថាតើឯកសារមួយនេះ ហើយនិងអត្ថបទដែលយើងបានគូសបញ្ជាក់អម្បាញ់មិញនេះ គឺជួយដល់លោកក្នុងការទាញការសន្និដ្ឋានណាមួយទាក់ទងទៅនឹងគោលគំនិតដើម ដែលថាគំនិតដើមនោះចេញពីណា ដែលនាំទៅដល់ការចាប់ខ្លួនបុគ្គលនៅក្នុងជួរយោធានោះ? ខ្ញុំសង្ឃឹមថា លោកនឹងស្តាប់ទាន់ទៅនឹងនូវសំណួររបស់ខ្ញុំ ។

[១៤:១៨:០៣]

**ឆ៖** លោកសហព្រះរាជអាជ្ញា គឺខ្ញុំចាប់សំណួរនោះបាន ។ ចំពោះខ្ញុំ នៅពេលដែលមើលទៅលើបរិបទ នៅក្នុងលក្ខណៈទ្រង់ទ្រាយធំនៃឯកសារនេះ ដែលវាពាក់ព័ន្ធទៅនឹងការងាររបស់ចាន់ចក្រី ហើយចំណុចមួយនៅក្នុងនោះ គឺវាបានបង្ហាញអំពីដំណើរការ នៃការសម្រិតសម្រាំងលើយោធាកម្ពុជាប្រជាធិបតេយ្យ ។ ចំណុចនោះគឺថា នៅក្នុងមុខងាររបស់គាត់ជាលេខា ស-២១ ជនជាប់ចោទនឹងធ្វើការពិនិត្យសិក្សាទៅលើចម្លើយសារភាព ហើយបន្ទាប់មករៀបចំបញ្ជីឈ្មោះបុគ្គល ដែលត្រូវយកទៅសម្រិតសម្រាំង បន្ទាប់មកជនជាប់ចោទនឹងបញ្ជូនបញ្ជីឈ្មោះទាំងអស់នោះទៅថ្នាក់លើ ដែលថ្នាក់លើនឹងធ្វើការយល់ព្រម ឬក៏ក្នុងករណីមួយចំនួនបញ្ជូនត្រឡប់មកវិញ ឬព្យួរទុក ។ ហើយករណីមួយចំនួន គឺមិនបានយល់ស្របទៅលើការសម្រិតសម្រាំងទៅលើបុគ្គលទាំងអស់នោះ ឬក៏ណាមួយ ។ ហើយនៅក្នុងករណីទាំងអស់នេះ តាមសេចក្តីបង្គាប់របស់ថ្នាក់លើជនជាប់ចោទនឹងទៅធ្វើការជួបប្រជុំនៅក្នុងអគ្គសេនាធិការដែលមានគំរូ និងការពិភាក្សាទៅលើការសម្រិតសម្រាំងផ្សេងៗ ។ ហើយដែលនៅទីនោះ មេបញ្ជាការនឹងបញ្ជាឲ្យធ្វើការសហការជាមួយនឹងស-២១ ក្នុងធ្វើការចាប់ខ្លួន ដែលវាជាផ្នែកមួយនៃដំណើរការ

សម្រិតសម្រាំង ។

**ស៖** សូមអរគុណ ។ ទាក់ទងទៅនឹងអ្វីដែលយើងហៅថា ការប្រឹក្សារវាងស-២១ និងកងពល គឺយើងបានឃើញនៅក្នុងឯកសារនេះ ។ ថាតើលោកយល់ចំពោះបញ្ហានេះយ៉ាងម៉េច ក្នុងលក្ខណៈទូទៅ ទាក់ទងទៅនឹងការសម្រិតសម្រាំងនៅក្នុងជួរយោធា? ជាពិសេសនោះថាតើវាបានបញ្ជាក់ និងប្រាប់លោកជាក់លាក់អំពីតួនាទីរបស់ស-២១ ជាក់ស្តែងដែរឬទេ?

**ឆ៖** ខ្ញុំហាក់ដូចជាមិនតាមទាន់ទៅនឹងសំណួររបស់លោក ។

**ស៖** ខ្ញុំនឹងរៀបចំសំណួរខ្ញុំក្នុងរបៀបមួយទៀត ។ នៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់លោក ថាតើមានការប្រឹក្សាស្រដៀងៗគ្នានេះដែរឬទេ រវាងមន្ទីរសន្តិសុខផ្សេងៗ និងកងពលនៅក្នុងក្របខ័ណ្ឌនេះ ដូចដែលបានបង្ហាញនៅក្នុងឯកសារមួយនេះ ។

**ឆ៖** ខ្ញុំអត់បានដឹងទេចំពោះបញ្ហាហ្នឹង ថាតើមន្ទីរសន្តិសុខផ្សេងៗ នឹងធ្វើការចូលរួមនៅក្នុងដំណើរការមួយនេះ ដែលនៅក្នុងដំណើរការនេះមានការពិភាក្សា ជាមួយនឹងអង្គការថ្នាក់លើខ្ពស់បំផុតនៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងជួរកងទ័ពបដិវត្តន៍ ជាពិសេសចំពោះអគ្គសេនាធិការ គឺខ្ញុំអត់បានដឹងទៅលើបញ្ហាហ្នឹងទេ ។

[១៤:២២:00]

**ស៖** សូមអរគុណ ។ នៅពេលនេះ គឺខ្ញុំសូមចូលទៅដល់ឯកសារមួយចំនួនទៀត ។ ឯកសារបួនដែលលោកបានលើកឡើង នៅក្នុងរបាយការណ៍លាយលក្ខណ៍អក្សររបស់លោក គឺយើងឃើញមានឧទាហរណ៍ប្រាំបួនដែលនៅសល់ ហើយសហព្រះរាជអាជ្ញា បានដាក់ជូនអង្គសវនាការកាលពីអាទិត្យមុន ។ ខ្ញុំនិយាយអំពីលិខិតដែលបានបញ្ជូនមកពី ស៊ូ ម៉េត ដែលជាលេខាកងពល៥០២ ។ លិខិតបញ្ជូនមកពី ស៊ូ ម៉េត ជូន ឌុច នៅពេលនេះ លោកប្រធាន សហព្រះរាជអាជ្ញាមានបំណងស្របទៅនឹងសេចក្តីសម្រេចរបស់លោក កាលពីអាទិត្យមុនទាក់ទងទៅនឹងការអានឯកសារ សហព្រះរាជអាជ្ញាមានបំណងក្នុងការអានសេចក្តីសង្ខេប លើឯកសារចំនួន៩ ទាក់ទងទៅនឹងការទាក់ទងរវាង ស៊ូ ម៉េត មក ឌុច ។ ហើយខ្ញុំដឹងថាកាលពីអាទិត្យមុន គឺមានការរៀបចំឯកសារថតចម្លងនៅលើតារាងនោះ ដែលយើងបានរៀបចំឡើង ។ ហើយឯកសារនោះ គឺយើងរៀបចំនៅដំណាក់កាលចុងក្រោយ ដូច្នេះ មានតែភាសាអង់គ្លេសតែប៉ុណ្ណោះ ។ ដូច្នេះ ប្រសិនបើអង្គសវនាការនឹងអនុញ្ញាត ខ្ញុំនឹងអានអត្ថបទនេះចេញពីតារាងទាំងអស់នេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំយល់ឃើញថា ឯកសារមួយចំនួនត្រូវបានបញ្ចូលនៅក្នុងរបាយ-ការណ៍របស់លោក ក្រេក អេតឆេសាន់ រួចហើយ គឺរបាយការណ៍ខែកក្កដា ឆ្នាំ២០០៧ ។ ហើយមេធាវីបានបញ្ជាក់ហើយ គឺយើងខ្ញុំមិនមានបញ្ហាទាក់ទងទៅនឹងឯកសារដែលបានបញ្ចូលនៅក្នុងរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ ខែកក្កដា ឆ្នាំ២០០៧ នោះទេ ។ ប៉ុន្តែ មេធាវីការពារក្តីសូមធ្វើការរំឭកថា ចាប់ពីខែកក្កដា ឆ្នាំ២០០៧ លោក អេតឆេសាន់ គឺលោកបានជាប់ពាក់ព័ន្ធដោយផ្ទាល់ធ្វើការងារជាមួយនឹងសហព្រះរាជអាជ្ញា នៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ដូច្នេះ មេធាវីការពារក្តីស្នើសុំថា ចម្លើយសក្ខីកម្មរបស់លោក អេតឆេសាន់ គឺមិនគួរផ្តោត ឬក៏សង្កត់ទៅលើដំណាក់កាលក្រោយខែកក្កដា ឆ្នាំ២០០៧នោះទេ ។ ដូច្នេះ យើងគួរតែធ្វើការពិនិត្យទៅលើរបាយការណ៍របស់គាត់នៅខែកក្កដា ឆ្នាំ ២០០៧ រួមទាំងឧបសម្ព័ន្ធ ។ ដូច្នេះ គឺខ្ញុំ គឺឃើញថាប្រសិនបើយើងមិនធ្វើផ្តោតទៅលើរបាយការណ៍របស់គាត់ គឺគាត់នឹងមិនមានជំហរយុត្តិធម៌ ឬក៏ត្រឹមត្រូវអត្តនោម័តិរបស់គាត់នោះទេ ។ ដូច្នេះ គឺយើងគួរតែយល់ស្របគ្នាទៅលើអ្វីដែលយើងបានលើកឡើង ។ មេធាវីការពារក្តីនឹងមិនលើកបញ្ហាអ្វីនោះទេ និងក៏មិនលើកជំទាស់ទៅលើបញ្ហានៃឯកសារដែរ ដរាបណាយើងផ្តោតនិងដេញដោលទៅលើឯកសាររបាយការណ៍របស់លោក ក្រេក អេតឆេសាន់ ខែកក្កដា ឆ្នាំ២០០៧ ។ អរគុណ ។

[១៤:២៥:៥៦]

**លោក អាឡិចសាន់ឌឺ ប៉េត៖**

លោកប្រធាន យើងនៅទីនេះ ដើម្បីធ្វើការស្វែងរកការពិត ។ យើងឃើញមានលិខិតចំនួន៩ ដែលបញ្ជូនមកពី ស៊ូ ម៉េត ទៅកាន់ ឌុច ហើយតាមសហព្រះរាជអាជ្ញាដែលបានដឹង គឺលិខិតទាំងអស់នេះមាននៅក្នុងសំណុំរឿងរួចហើយ ។ ហើយលិខិតទាំង៩នេះ គឺវាទាក់ទៅនឹងរយ:ពេល៦ខែ គឺចាប់ពីថ្ងៃ០១ ខែមេសា ឆ្នាំ១៩៧៧ ដល់ ថ្ងៃ០៤ ខែតុលា ឆ្នាំ១៩៧៧ ។ ហើយខ្ញុំគិតថា ជនជាប់ចោទនេះ បានបង្ហាញរួចហើយនៅក្នុងតារាងនិងដ្យាក្រាម ដែលបង្ហាញអំពីការសម្រិតសម្រាំងនៅក្នុងកងពល៥០២ ។ យ៉ាងហោចណាស់មានមូលហេតុចំនួនបី ហេតុអ្វីបានជាលិខិតទាំងអស់នេះវាពាក់ព័ន្ធ ហើយគួរតែដេញដោលនៅចំពោះមុខអង្គសវនាការ ។

ហេតុផលទីមួយ ដូចដែលលោក អេតឆេសាន់ បានលើកឡើងនៅក្នុងកថាខណ្ឌ១,២,៣ នៃរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់លោក គឺវាបានបង្កើតអំពីគោលការណ៍ទូទៅថា លេខារបស់

កងពលមានអំណាចក្នុងការបញ្ជូនអ្នកទោសពីអង្គភាពរបស់ខ្លួនទៅស-២១ ។

ចំណុចទីពីរ របាយការណ៍នេះ បានបង្ហាញអំពីភាពញឹកញាប់ ដែលលេខារបស់កងពលមួយធ្វើការទាក់ទងជាមួយនឹងជនជាប់ចោទលើបញ្ហាសន្តិសុខ ។

ហើយចំណុចទីបី លោកប្រធាន គឺវាបានបញ្ជាក់តាមខ្លឹមសារ គឺមានការសហការណ៍គ្នា ក្នុងលក្ខណៈជ្រាលជ្រៅរវាងជនជាប់ចោទ និងលេខារបស់កងពលក្នុងការស្រាវជ្រាវ និងការចាប់ខ្លួនខ្មាំងនិងជនក្បត់ ។ ដោយសារតែចំណុចទីបីនេះហើយគឺសហព្រះរាជអាជ្ញាសូមលើកឡើងថា វាជាភស្តុតាងមួយដែលរឹងមាំក្នុងការបញ្ជាក់ថា គំនិតផ្តួចផ្តើមក្នុងការចាប់សមាជិកយោធា គឺកើតចេញពីជនជាប់ចោទដោយខ្លួនឯង ដោយគាត់ធ្វើការសហការរួមគ្នាជាមួយនឹងលេខារបស់យោធា ។ ដែលចំណុចនេះហើយ វាអាចជាចំណុចមួយសំខាន់នៅក្នុងរឿងក្តី ។ ជាការពិត វាផ្ទុយនឹងជំហររបស់ជនជាប់ចោទប្រសិនបើគាត់មិនលើកឡើងថា នៅពេលដែលចាប់ខ្លួនរបស់ជនរងគ្រោះ គឺជាការបញ្ជារបស់មេរបស់គាត់ ប៉ុន្តែគឺចំណុចនេះហើយ គឺដែលជនជាប់ចោទមិនអាចអំពីថាលិខិតនោះ វាមិនពាក់ព័ន្ធ ។

[១៤:២៩:០៣]

សហព្រះរាជអាជ្ញា គឺយល់ថា វាមានមូលដ្ឋានផ្លូវច្បាប់ គឺវាមិនមានមូលដ្ឋានផ្លូវច្បាប់ ចំពោះមេធាវីការក្តី ដែលជំទាស់ទៅលើលិខិតទាំងប្រាំបួននេះ ។ ហើយជាការពិត លោក រូ មិនបានលើកឡើងវិធានផ្ទៃក្នុងដែលពាក់ព័ន្ធ ដែលថា ឯកសារទាំងអស់នេះគួរតែដកចេញ និងមិនពិភាក្សាដេញដោល នៅពេលដែលយើងមានសាក្សីនៅទីនេះរួចហើយ ហើយដែលសាក្សីនេះគាត់អាចផ្តល់សក្ខីកម្ម ។ ប្រសិនបើមេធាវីការពារក្តីចង់លើកបញ្ហានេះ ដែលទាក់ទងទៅនឹងការិយាល័យ ដែលអ្នកជំនាញនេះធ្វើការ គឺគាត់អាចធ្វើបាន ។ ប៉ុន្តែ លិខិតនេះ គឺវាមិនបានលុបបំបាត់ទៅលើអង្គហេតុ ហើយវាស្របទៅនឹងសេចក្តីសម្រេចរបស់អង្គសវនាការទាក់ទងទៅនឹងវិធាន៨៣ ក្នុងការសួរទៅកាន់អ្នកជំនាញ។ ហើយនៅក្នុងករណីនេះហើយ សហព្រះរាជអាជ្ញាសូមលើកឡើងថា គឺភាគីគោរពទៅតាមសេចក្តីសម្រេចរបស់អង្គសវនាការ ដែលថាឯកសារបើសិនមិនពាក់ព័ន្ធ ឬក៏មិនជាប់ទាក់ទង ឬក៏វាជាន់គ្នានោះ យើងនឹងមិនធ្វើការពិភាក្សាទេ ។ មេធាវីការពារក្តីបានអះអាងសិទ្ធិមួយចំនួនក្នុងការមិនសួរអ្នកជំនាញអំពីភស្តុតាងដែលលេចចេញក្នុងពេលស៊ើបអង្កេត ។

ខ្ញុំសុំធ្វើការអភ័ទោសចំពោះបញ្ហានេះ នេះគឺជាភាពមិនច្បាស់លាស់ ។ ដូចដែលខ្ញុំបានរៀបរាប់ហើយ យើងមានអ្នកជំនាញដែលមានគុណសម្បត្តិគ្រប់គ្រាន់ដែលគាត់នឹងបង្ហាញជំនាញរបស់គាត់ដែល

បានសរសេរនៅក្នុងឯកសារ និងរបាយការណ៍របស់គាត់ដែលបានបញ្ចូលទៅក្នុងសំណុំរឿង ។ ហើយថាតើគាត់គួរតែសួរថាមិនឲ្យពិនិត្យមើលឯកសារនោះឬយ៉ាងម៉េច? ហើយយើងគួរតែធ្វើការចាត់ទុកឯកសារផ្សេងមិនមាន នេះគឺជាចំណុចមួយមិនមានចំណុចមួយពាក់ព័ន្ធតែម្តង ។ ហើយវាផ្ទុយទៅនឹងអ្វីដែលតុលាការនេះចង់បានការពិនិត្យគឺក្នុងការលាតត្រដាងនូវការពិត ។

ឥឡូវនេះ គឺថាយើងមានចំណុចដែលចេះតែអភិវឌ្ឍន៍ទៅមុខ ហើយវាគឺជាបញ្ហា ។ ហាក់បីដូចជាមានការបង្ហាញនូវភាពផ្តាច់គ្នាទាំងស្រុងពីការទទួលសារភាព ទទួលស្គាល់ជាទូទៅរបស់ជនចោទនេះជាចំណុចម្ខាង ហើយផ្នែកម្ខាងទៀត គឺយុត្តិសាស្ត្រនៃការការពាររបស់មេធាវីការពារក្នុងការលើកឡើងការជំទាស់ជាបន្តបន្ទាប់នៅពេលដែលមានព័ត៌មានដែលដាក់បន្ទុក ឬក៏សាក្សីដាក់បន្ទុកណាមួយជាក់លាក់ ត្រូវបានបង្ហាញនោះ ។ បង្ហាញអំពីអ្វីដែលជនចោទបាននិយាយ ឬក៏បានធ្វើនោះ ។ ប្រសិនបើជាមេធាវីការពារក្តីចង់ទទួលបានចំណុចសម្រាប់ការអនុវត្តន៍នៅក្នុងការពារកូនក្តីរបស់ខ្លួន និងសម្រាប់កិច្ចសហប្រតិបត្តិការ ឬក៏ភាពសោកស្តាយដែលខ្លួនបានធ្វើនោះ ។ ហេតុអ្វីបានជាមេធាវីការពារចេះតែទៅលើជំទាស់ឯកសារដែលមានសុពលភាពនេះ ។ លោកប្រធាន ខ្ញុំសុំទោសដែលខ្ញុំស៊ីពេលច្រើននៅក្នុងការលើកឡើងអំពីចំណុចនេះ ក៏ប៉ុន្តែ នេះគឺជាគោលការណ៍ទូទៅដែលខ្ញុំចង់លើកឡើង ។ ហើយគោលការណ៍ទូទៅនោះ គឺថានៅពេលដែលពាក់ព័ន្ធណាមួយនោះ គឺថាយើងត្រូវយកមកធ្វើ ដើម្បីធ្វើការវិភាគវាយតម្លៃ ហើយនិងមានឱកាសដើម្បីផ្តល់មតិទៅលើឯកសារនោះ ។ ហើយជាពិសេសនៅក្នុងករណីដែលគាត់ជាសាក្សីអ្នកជំនាញ ដើម្បីធ្វើការពន្យល់ ឬក៏វិភាគទៅលើឯកសារនោះ ហើយខាងមេធាវីការពារក្តីក៏មានឱកាសដើម្បីពិចារណាវាយតម្លៃទៅលើឯកសារនោះដែរ ។ ដូច្នេះហើយយើងនឹងអាចបន្តពេលដើម្បីស្វែងរកការពិតបាន ។ ខាងសហព្រះរាជអាជ្ញាសូមស្នើទៅលោកចៅក្រមថា ការជំទាស់ដែលលើកឡើងដោយមេធាវីការពារក្តីនោះ គឺមិនមានមូលដ្ឋានទេ ។ ហើយខ្ញុំចង់លោកប្រធានអនុញ្ញាតធ្វើការសួរសំណួរបន្តទៅទៀត ពីព្រោះឯកសារទាំងអស់នេះមិនមានចំនួនច្រើនទេ បើសរុបមានតែប្រាំបួនឯកសារតែប៉ុណ្ណោះ ហើយការស្នើឡើងរបស់សហព្រះរាជអាជ្ញា គឺជាចំណុចមួយដែលយើងត្រូវលើកឡើង ដើម្បីឲ្យសាធារណជនបានដឹងឮ និងដើម្បីឲ្យអង្គជំនុំជម្រះបានដឹងឮផងដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីការពារតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានបំណងចង់កត់សម្គាល់

ពាក់ព័ន្ធជាមួយនឹងការជំទាស់របស់មេធាវីការពារ ដែលជំទាស់ទៅនឹងការលើកឡើងនៃឯកសារចំនួនប្រាំបួនរបស់សហព្រះរាជអាជ្ញាមកដេញដោលនៅពេលនេះ ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងមិនស៊ីពេលយូរទេ ។ លោក ហ្វ្រង់ស្វ័រ រូ បានធ្វើការព្រមព្រៀងគ្នា ប្រហែលជារវាងខ្លួនគាត់ ឬក៏ជាមួយនឹងនៅក្នុងក្រុមរបស់គាត់ ប៉ុន្តែនៅក្នុងក្រុមយើងទេ គាត់បានធ្វើការព្រមព្រៀងអ្វីជាមួយលោកប្រធាន ឬក៏ជាមួយនឹងខាងសហព្រះរាជអាជ្ញាទេ ។

លោកប្រធានជាទីគោរព! លោកហ្វ្រង់ស្វ័រ រូ បានបង្ហាញពីតួនាទីរបស់គាត់ បានបំពេញពីជំហររបស់គាត់កាលពីសប្តាហ៍មុន ហើយយើងមិនបានឯកភាពទេ ហើយលោកប្រធានក៏មិនបានឯកភាពដែរ ។ ប្រសិនបើលោក អាឡិចប៊ែត គាត់មានឯកសារពាក់ព័ន្ធដែលមានសុពលភាព ហើយចង់សួរសំណួរទាក់ទងទៅលើឯកសារនោះ មានន័យថា គាត់ត្រូវតែមានសិទ្ធដើម្បីសួរ នេះទាក់ទងទៅនឹងសេចក្តីសម្រេចលោក ។ មានន័យថា ត្រូវដាក់ជូនឯកសារ ហើយនឹងសួរសំណួរដែលគាត់ចង់សួរប្រសិនបើជាសំណួរអស់ទាំងនេះ ជាសំណួរពាក់ព័ន្ធ ហើយនេះគឺជាចំណុចពិតប្រាកដ ជាក់ស្តែងដែលលោកបានមានប្រសាសន៍កាលពីថ្ងៃអង្គារ៍មុន នៅពេលដែលលោក ហ្វ្រង់ស្វ័រ រូ ដែលគាត់បានបញ្ជាដាក់កម្រិតទៅលើការសួរសំណួររបស់លោក លោកស្រីចៅក្រម ។ ហើយនេះគឺជាអ្វីដែលលោកចៅក្រមបាននិយាយ កាលពីថ្ងៃទី១៩ ខែឧសភា ទាក់ទងទៅនឹងទីទំព័រ៣១ ប្រតិចារឹកជាភាសាអង់គ្លេស ។ អង្គជំនុំជម្រះ គឺមិនជាប់កាតព្វកិច្ចទៅនឹងភាគីពាក់ព័ន្ធណាមួយទេ ទាក់ទងទៅនឹងការសួរទៅលើអ្នកជំនាញ ។ ហេតុផលនេះ គឺថាភាគីពាក់ព័ន្ធ និងអង្គសវនាការអាចសួរនូវសំណួរណាដែលជាសំណួរពាក់ព័ន្ធ ហើយលោកក៏និយាយបានទៀតថា នៅពេលដែលឆ្លើយនឹងសំណួរបែបនោះ គឺសាក្សីអ្នកជំនាញគឺថាគាត់មិនចាំបាច់ភ្ជាប់កាតព្វកិច្ចទៅនឹងសេចក្តីថ្លែងការណ៍ ឬក៏ឯកសារដែលគាត់មានពីមុនមកមុនទេ ។

ខ្ញុំសូមហៅថានេះគឺជាជំហរ ដែលយើងខ្ញុំបានលើកឡើង ។ បើសិនជាមានឯកសារណាពាក់ព័ន្ធដែលខាងសហព្រះរាជអាជ្ញាចង់លើកឡើង គឺថា គាត់ត្រូវគួរតែមានសិទ្ធិ ដើម្បីដាក់ឯកសារនេះនៅចំពោះមុខអង្គសវនាការ ហើយនឹងសួរសំណួរ បើសិនជាសំណួរនោះជាសំណួរពាក់ព័ន្ធ ។ ហើយគឺថាមិនមានកិច្ចព្រមព្រៀងអ្វីផ្សេងទៀតទេ រវាងភាគីពាក់ព័ន្ធនានានៅក្នុងអង្គសាលសវនាការនេះ ។ ខ្ញុំសូមអរគុណ លោកចៅក្រម ។

[១៤:៣៦:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ មេធាវីអ្នកតំណាងឲ្យដើមបណ្តឹងក្រុមពីរ ។

**លោកស្រី ស៊ីលឃឺស្ទូត ហ្សីនស្ទ៊ី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់រំឭកដល់ភាគីពាក់ព័ន្ធទាំងអស់គ្នាឲ្យបានដឹងថា កិច្ចព្រមព្រៀងគ្នា ដែលខាងមេធាវីការពារក្តីបានលើកឡើងនោះ ។ យើងបានយោងទៅលើឧបសម្ព័ន្ធនៃរបាយ-ការណ៍របស់អ្នកជំនាញលោកដុកទ័រ គ្រេក អេតធេសាន់ ។ ឧបសម្ព័ន្ធដែលមាន ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធអស់ទាំងហ្នឹង អាចចាត់ទុកថាឯកសារនុំងគឺដាក់នៅចំពោះមុខអង្គសវនាការដោយមិនធ្វើការអាន ឬក៏ធ្វើសេចក្តីសង្ខេប ។ នេះមិនមែនមានន័យថា ឯកសារផ្សេងទៀត ឬក៏ភស្តុតាងផ្សេងទៀត ដែលមាននៅក្នុងសំណុំរឿងរួចហើយនោះ អាចត្រូវដាក់នៅចំពោះមុខអង្គសាលសវនាការ ដោយធ្វើការអាន ឬមួយក៏ដោយធ្វើសេចក្តីសង្ខេប ។ ហើយនេះគឺជាអ្វីដែលខាងសហព្រះរាជអាជ្ញាបានសម្រេចចិត្តនៅក្នុងករណីនេះ គឺដាក់ឯកសារនោះ នៅចំពោះមុខអង្គសវនាការ ហើយនឹងធ្វើសេចក្តីសង្ខេបទៅលើឯកសារទាំងនោះ ។

ខ្ញុំមិនមានឃើញហេតុផលអ្វីដែលនាំឲ្យជឿថា យើងគួរតែកុំរាប់បញ្ចូល ឬក៏ដាក់បញ្ចូលនូវនីតិវិធីនេះ គឺនីតិវិធីខាងសហព្រះរាជអាជ្ញាបានធ្វើ ឬក៏ដែលមានបំណងចង់ធ្វើនោះ ។ គឺមានតែមេធាវីការពារក្តីទេ ដែលនៅតែទទូចថាពួកគេមិនឯកភាពទៅលើការងារផ្សេងៗទៀត ដែលសាក្សី និងសាក្សីអ្នកជំនាញផ្សេងៗទៀតបានធ្វើ បន្ទាប់ពីរបាយការណ៍នោះត្រូវបានបញ្ចប់កាលពីខែកក្កដា ឆ្នាំ២០០៧នោះ ។ ប៉ុន្តែ នេះគ្រាន់តែជាសេចក្តីលើកឡើងរបស់មេធាវីការពារក្តីតែប៉ុណ្ណោះ ហើយអង្គជំនុំជម្រះគឺមិនបានធ្វើសេចក្តីសម្រេចទៅលើការលើកឡើងរបស់មេធាវីការពារក្តីនោះទេ ។

ផ្ទុយពីនេះទៅវិញ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ជាទូទៅហើយនៅក្នុងករណីនេះទាក់ទងទៅនឹងឧបសម្ព័ន្ធនោះ គឺយើងអាចដោះស្រាយបានដោយចាត់ទុកថាឯកសារនៅក្នុងឧបសម្ព័ន្ធនោះគឺបានដាក់នៅចំពោះមុខអង្គសាលសវនាការរួចហើយ ។ ហើយគឺមេធាវីការពារក្តីអាចលើកឡើងនូវចំណុចណាមួយទាក់ទងទៅនឹងឯកសារណាមួយ បើសិនជាឯកសារនោះមិនអនុលោមទៅតាមវិធាន៨៧ ហើយត្រូវដកចេញនោះ ។ នោះគឺជាចំណុចមួយផ្សេងទៀត ។

ដូច្នេះហើយ សូមដាក់សំណើទៅអង្គសវនាការឲ្យធ្វើការទាត់ចោលនូវលើសេចក្តីជំទាស់របស់

មេធាវីការពារក្តី ។ សូមអរគុណ ។

[១៤:៤០:១០]

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី រ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំនិយាយតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។ គោលបំណងក្នុងការដាក់ឯកសារនៅចំពោះអង្គសវនាការ ដើម្បីធានា ឬក៏ស្វែងរកការពិតអ្វីទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីស្វែងរកការពិតនោះ គឺជាផលប្រយោជន៍សម្រាប់ជនរងគ្រោះ ហើយនិងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផង ។

យើងមានបំណងចង់ដឹងថា នឹងចង់ដឹងនឹងចង់យល់ នឹងដើម្បីទទួលបាននូវសេចក្តីពន្យល់ណាមួយ ហើយលើសពីនេះទៅទៀត គឺយើងមានបំណងចង់មើលឃើញវប្បធម៌នៃការរក្សាភាពសម្ងាត់ ដែលការបិទបាំងនៅរយៈពេលប៉ុន្មានឆ្នាំ ដែលស្ថិតនៅក្នុងភាពស្ងៀមស្ងាត់នេះ ។ ប៉ុន្តែ ភាពបិទបាំងនេះគឺបានបើកត្រដាងហើយនៅថ្ងៃនេះ ។ ហើយវិធានដែលមិនមានសរសេរ ពីព្រោះវិធាននៃភស្តុតាងទាំងអស់គឺអាចទទួលយកបាន គឺដើម្បីព្យាយាមបង្ហាញនូវការពិត ពីព្រោះនៅពេលក្រោយ ប្រសិនបើគោលបំណងក្នុងការឈានទៅដល់ដំណាក់កាលណាមួយទៀត ។ មានន័យថា ដំណាក់កាលនៃការពិភាក្សាគ្នា ខ្ញុំមិនចង់និយាយអំពីការផ្សះផ្សាគ្នានោះទេ គឺខ្ញុំនិយាយចង់អំពីការពិភាក្សាគ្នា ការពិតគឺត្រូវតែបង្ហាញឲ្យពេញលេញ ។

បុគ្គលគ្រប់រូបអាចបញ្ចេញមតិរបស់ខ្លួន។ ដូច្នេះ ខ្ញុំយល់ថានេះគឺជាចំណុចសំខាន់ណាស់ ដែលឯកសារជាភស្តុតាងទាំងប្រាំបួននេះ ដែលអាចមានសារសំខាន់បំផុត ចំពោះជនរងគ្រោះនោះ គួរតែដាក់នៅចំពោះមុខនីតិវិធីនៅក្នុងតុលាការនេះ ។

[១៤:៤២:១១]

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ចង់មានការកត់សម្គាល់អ្វីដែរទេ?

សូមអញ្ជើញ លោក ហ្វ្រង់ស្វ័រ រូ ។ មានបញ្ហាអ្វីចង់តបទេ? លោកហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ទៅតាមការសង្កេត ខ្ញុំមានការសង្កេតមួយចំនួនខ្លីៗ ។ គ្រប់ៗគ្នា

យើងមានការសង្កេតថា នៅពេលណាមួយដែលមេធាវីការពារក្ដីលើកឡើងនូវការជំទាស់គឺយើងមិនចង់បានគូបដិបក្ខដ៏ច្រើននោះទេ ។ ខ្ញុំចាប់ផ្ដើមមានចម្ងល់ ថាតើ តើសិទ្ធិនៃភាពស្មើគ្នាហ្នឹង វាកើតឡើងយ៉ាងណានៅក្នុងសាលសវនាការនេះ នៅពេលដែលសាក្សីត្រូវបានសួរសំណួរ យ៉ាងហោចណាស់ ក៏មានការសួរពិនិត្យដេញដោលចំនួនពីរ ឬក៏បីក្រុមទៀតដែរ ។ ហើយនៅពេលដែលមេធាវីការពារក្ដីលើកឡើងនូវជំទាស់ណាមួយ គឺតែងតែមានយោបល់មតិជំទាស់បី ឬក៏បួន ។

ដូច្នេះ យើងអាចធ្វើការវិនិច្ឆ័យបានដោយខ្លួនឯងហើយ នៅត្រង់ចំណុចនេះ គឺថាមានការឆ្លើយតបចំនួនបី ហើយខ្ញុំមិននិយាយអត់ន័យនោះទេ ។ ប៉ុន្ដែទីមួយ គឺថា ឌុច គាត់រៀបរាប់រួចហើយក្នុងការឆ្លើយតបទៅនឹងសំណួរអ្វីទាំងអស់ទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍ទាំងប្រាំបួននោះ ឬក៏ឯកសារទាំងប្រាំបួននោះ ហើយគាត់ក៏បានបញ្ជាក់ផងដែរថា គាត់បានឯកភាពក្នុងការនិយាយអំពីឯកសារទាំងប្រាំបួននោះ ។

ខ្ញុំចង់ធ្វើបញ្ជាក់ការធានាដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីរបស់ពួកគេទាំងអស់ថា ឌុច នឹងនិយាយអំពីឯកសារទាំងប្រាំបួននេះ ។ លោក លោកស្រី ត្រឹមត្រូវហើយឯកសារអស់ទាំងហ្នឹង គឺជាឯកសារ គឺជាមូលដ្ឋានដើម្បីស្វែងរកការពិត ជាពិសេសខ្ញុំចង់ធ្វើការចង្អុលបង្ហាញថា គាត់បានសម្ភាសន៍រួចមកហើយ ដោយសហចៅក្រមស៊ើបអង្កេត ហើយដែលគាត់បានផ្ដល់ចម្លើយដល់ពួកគាត់ ហើយនៅក្នុងដំណើរការនីតិវិធីនេះ យើងកំពុងតែពិភាក្សាទៅលើចម្លើយដែលគាត់បានប្រគល់ឲ្យពីមុនមក។ហើយព័ត៌មានបន្ថែមទេ ដែលបានទទួលបាននៅក្នុងបរិបទនេះ ប៉ុន្ដែ អ្វីដែលខ្ញុំជំទាស់នោះ គឺមិនមែនទៅលើចំណុចនេះទេ ។

[១៤:៤៥:០៧]

កាលពីថ្ងៃមុន យើងមានការពិភាក្សាគ្នាដំបូងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ហើយបន្ទាប់មកទៀតនៅក្នុងសាលសវនាការជាសាធារណៈ ទៅលើសេចក្ដីសម្រេចចិត្តនៃភាពដែលគួរឲ្យជឿបាន ទៅលើសាក្សីលោក ក្រេក អេតធេសាន់ ដែលជាអ្នកជំនាញនោះ ។ ហើយខ្ញុំបាននិយាយដូច្នេះ ជាការច្បាស់ណាស់ដែលថា ខ្ញុំមិនធ្វើការការតវ៉ាទៅលើភាពគួរឲ្យជឿបានរបស់លោកបណ្ឌិត អេតធេសាន់ ហើយនិងឧបសម្ព័ន្ធផ្សេងៗដែលគាត់ភ្ជាប់ទៅលើរបាយការណ៍របស់គាត់នោះទេ ។ ប៉ុន្ដែ នៅក្នុងបរិបទនេះ គាត់បានឆ្លើយសំណួរទាក់ទងទៅនឹងសំណួររបស់គាត់នោះ ។ ហើយខ្ញុំបាននិយាយចំណុចនេះ យ៉ាងច្បាស់លាស់នៅក្នុងសវនាការសាធារណៈ ហើយខ្ញុំយល់ថា គឺយើងមានកិច្ចឯកភាពព្រមៗគ្នាទៅលើ

ចំណុចនេះ ។ ក៏ប៉ុន្តែ បើនៅពេលនេះ ទោះបីជាការជំទាស់របស់ខ្ញុំ និងការរក្សាសិទ្ធិរបស់ខ្ញុំ ហើយអង្គសវនាការពិចារណាថាសំណួរអាចសួរទៅលើលោក ក្រេក អេតធេសាន់ បានទៅលើមូលដ្ឋាននៃឯកសារដែលគាត់បានដឹង នៅពេលដែលគាត់ធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត នោះជាសេចក្តីសម្រេចរបស់អង្គសវនាការ ។

ខ្ញុំមិនមានមន្ទិលសង្ស័យអ្វីសោះទៅលើសេចក្តីសម្រេចនេះ ប្រសិនបើមានសេចក្តីសម្រេចបែបនោះមែន ។ ហើយមិនមានអ្វីទាក់ទងទៅនឹងយុត្តិសាស្ត្រនោះទេ ទៅតាមការយល់ដឹងរបស់ខ្ញុំ នេះគឺជាលើកទីមួយហើយ ដែលសាក្សីជាអ្នកជំនាញត្រូវបានកោះហៅមកផ្តល់សក្ខីកម្មក្នុងនាម នៅក្នុងពេលដែលគាត់ជាបុគ្គលិកម្នាក់របស់ខាងសហព្រះរាជអាជ្ញា ។ ក៏ប៉ុន្តែ បើសិនជាអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចចិត្តបែបនេះ អ្វីដែលខ្ញុំចង់និយាយ គឺគ្រាន់តែខ្ញុំបង្ហាញអំពីការរក្សាសិទ្ធិរបស់ខ្ញុំទាក់ទងទៅនឹងច្បាប់ ហើយនិងភាពយុត្តិធម៌ ។

ចំណុចចុងក្រោយ ដែលជាចំណុចទីបីរបស់ខ្ញុំ គឺថាប្រសិនបើខាងសហព្រះរាជអាជ្ញា ប្រាថ្នាឲ្យពួកយើងនិយាយអំពីឯកសារ ឬក៏លិខិតទាំងប្រាំបួន ដែល ស៊ូ ម៉េត បានសរសេរមកឲ្យ ឌុច នោះ តើសហព្រះរាជអាជ្ញាមកអង្គសវនាការបានទេ ថាតើហេតុអ្វីបានជាពួកគេមិនស្នើឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការដេញដោលជាមួយ ឌុច ទាក់ទងទៅនឹងលិខិតរបស់ ស៊ូ ម៉េត អស់ទាំងនេះ? ហើយឥឡូវនេះ ខ្ញុំគាំទ្រសំណើដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ថាតើសហព្រះរាជអាជ្ញាអាចពន្យល់ប្រាប់យើងបាននៅពេលនេះ ថាតើហេតុអ្វីបានជាពួកគេមិនព្យាយាមឲ្យធ្វើការកោះហៅលោក ស៊ូ ម៉េត នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ? ហើយហេតុអ្វីបានជាសហព្រះរាជអាជ្ញា មិនធ្វើការកោះហៅលោក ស៊ូ ម៉េត នៅចំពោះមុខអង្គជំនុំជម្រះនេះ? គឺថាយើងអាចសួរសំណួរទៅលើជនជាប់ចោទបាននៅថ្ងៃនេះ ទាក់ទងទៅនឹងមនុស្សម្នាក់ ដែលជាអ្នកសរសេរសំបុត្រអស់ទាំងនោះ ។

[១៤:៤៨:៣៥]

តួនាទីរបស់មេធាវីការពារក្តីនៅក្នុងនីតិវិធីណាក៏ដោយ គឺដើម្បីរក្សានូវសិទ្ធិមនុស្ស នេះគឺជាភារកិច្ចដែលខ្ញុំបាននិយាយពីមុនមកហើយ ដែលសហព្រះរាជអាជ្ញា រីឆាត ហ្គោស្តុន បាននិយាយមេធាវីការពារណា ដែលអាចធ្វើបានដូច្នោះគឺមានន័យថា ដើម្បីការពារសិទ្ធិ ។ ហើយខាងសហព្រះរាជអាជ្ញារបស់យើងនៅទីនេះ បើសិនជាគាត់មានបំណងប្រាថ្នាចង់សួរសំណួរទៅលោក ឌុច គាត់អាចសួរបាន ក៏ប៉ុន្តែ ដំបូងគឺត្រូវធ្វើ ដោយមិនមានវត្តមានរបស់សហសេវិករបស់គាត់គឺលោក ក្រេក អេតធេ

សាន់ ។ ហើយប្រសិនបើអាចធ្វើដូច្នោះ គឺត្រូវធ្វើនៅពេលដែលធ្វើការកោះអញ្ជើញលោក ស៊ូ ម៉េត ជាមុនសិន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកកន្លះម៉ោង ហើយឆ្លៀតក្នុងពេលនៃការសម្រាកនោះ អង្គជម្រះនឹងចេញសេចក្តីសម្រេច ដើម្បីបានដំណើរការនីតិវិធី គឺនឹងចេញសេចក្តីសម្រេចលើបណ្តឹង លើការជំទាស់របស់មេធាវីការពារក្តី ដែលបានលើកឡើងដែលជំទាស់នឹងឯកសារទាំងប្រាំបួន ដែលការសហព្រះរាជអាជ្ញាប៉ុនប៉ងនឹងលើកយកមកពិភាក្សាដេញដោល ។

*[សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:៥១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការតទៅទៀត ។ ដោយលក្ខណៈនៃបញ្ហាមានភាពស្មុគស្មាញ ហើយមិនទាន់ច្បាស់លាស់មុននឹងសម្រេចសេចក្តីអំពីការជំទាស់របស់មេធាវីការពារក្តី អង្គជំនុំជម្រះសូមអញ្ជើញសហព្រះរាជអាជ្ញាឡើងបង្ហាញអំពីខ្លឹមសារនៃឯកសារទាំងប្រាំបួន ពីព្រោះមេធាវីការពារក្តីមិនជំទាស់ទៅនឹងការដាក់ឯកសារទាំងប្រាំបួននេះនៅចំពោះមុខអង្គជំនុំជម្រះទេ ដើម្បីឲ្យមានមូលដ្ឋាននៅក្នុងការពិភាក្សាសម្រេចនៅចុងក្រោយ ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សូមអរគុណលោកប្រធាន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ធ្វើការបំភ្លឺនូវអ្វីដែលអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើឃើញថា គឺយើងសង្កេតឃើញថាគ្មានការជំទាស់ទៅនឹងឯកសារទាំងប្រាំបួនដែលលើកឡើងមុននេះ ហើយស្នើសុំដាក់ចំពោះមុខអង្គសវនាការពីខាងសហព្រះរាជអាជ្ញា ។ ដូច្នេះ សហព្រះរាជអាជ្ញាអាចធ្វើជាសេចក្តីសង្ខេបឬក៏ធ្វើការអានបញ្ជាក់ទៅលើបញ្ហានេះជូនអង្គសវនាការបាន ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺខ្ញុំសូមធ្វើការបំភ្លឺមួយចំណុចប្រសិនបើអនុញ្ញាត ។ តើខ្ញុំយល់ថា អង្គសវនាការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាជាជាងសង្ខេបឯកសារនីមួយៗ គឺអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើការពន្យល់ទៅលើឯកសារទាំងប្រាំបួននោះក្នុងពីរបីប្រយោគដើម្បីបង្ហាញអង្គសវនាការ តើនេះគឺជាអ្វីដែលខ្ញុំយល់ត្រឹមត្រូវដែរឬទេ? សូមអរគុណ ។ ដូច្នេះ សេចក្តីសង្ខេបចំពោះឯកសារទាំងប្រាំបួននោះ ។ ឯកសារនេះគឺជាឯកសារដើមដែលហាក់ដូចជាសរសេរឡើងដោយលេខាកងពល៥០២ គឺ ស៊ូ ម៉េត ហើយលិខិតនេះផ្ញើជូនទៅកាន់ជនជាប់ចោទដែលមានឈ្មោះនៅក្នុងហ្នឹង ។

ឯកសារលិខិតទាំងប្រាំបួននេះ គឺមានកាលបរិច្ឆេទចាប់ពីថ្ងៃ១ ខែមេសា ឆ្នាំ១៩៧៧ ទៅដល់ថ្ងៃ៤ ខែតុលា ឆ្នាំ១៩៧៧ ។ ហើយឯកសារនេះ គឺវាជាប់ពាក់ព័ន្ធទៅនឹងសំណើសុំចម្លើយសារភាពពីស-២១ ហើយស្នើសុំចម្លើយសារភាពពី ស-២១ បញ្ជូនទៅ ស៊ូ ម៉េត ហើយការពិភាក្សាគឺវាបានធ្វើឡើងចំពោះអ្នកជនក្បត់ ឬក៏ខ្មាំងដែលត្រូវបានចាប់ខ្លួនមកពីកងពល៥០២ ហើយត្រូវបានបញ្ជូនទៅ ស-២១។ នៅក្នុងពេលមួយចំនួននោះ យើងឃើញមានចំណារបន្ថែមដែលបានចារនៅលើលិខិតទាំងប្រាំបួននេះ ។

[១៥:៥៥:២៤]

ចំណារទាំងអស់នោះ គឺវាហាក់ដូចជាធ្វើឡើងដោយជនជាប់ចោទ ហើយចំណារមួយចំនួនគឺបានធ្វើការបង្គាប់ និងបញ្ជាទៅដល់អ្នកថ្នាក់ក្រោមលើបញ្ហាសួរចម្លើយ និងបញ្ហាផ្សេងៗទៀត ។

ថាតើអង្គសវនាការយល់ឃើញថា គ្រប់គ្រាន់ដែរ ឬទេ ចំពោះសេចក្តីសង្ខេបរបស់ខ្ញុំលើឯកសារទាំងប្រាំបួននេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

វាហាក់ដូចជាបង្ហាញឲ្យឃើញថា ឯកសារមួយចំនួនដែលបានបង្ហាញថា វាជាទូរលេខ ហើយវាជាឧបសម្ព័ន្ធដែលមាននៅក្នុងរបាយការណ៍របស់លោក អេតធេសាន់ ។ ថាឯកសារដែលលោកបានលើកឡើងនេះ គឺវារួមទាំងឯកសារដែលភ្ជាប់ទៅនឹងរបាយការណ៍របស់ អេតធេសាន់ ឬយ៉ាងណា? ប្រសិនបើឯកសារនោះ វាខុសពីឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធសូមឲ្យលោកផ្តល់នូវលេខ ERN ឬក៏លេខយោងទៅលើឯកសារនេះ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ជាការពិត ឯកសារនេះគឺវាភ្ជាប់ទៅនឹងរបាយការណ៍របស់លោក អេតឆេសាន់ ហើយវាឯកសារទាំងប្រាំបួននេះ គឺវាមានបញ្ចូលនៅក្នុងហ្នឹង ដែលសហព្រះរាជអាជ្ញាមានបំណងក្នុងការដាក់ជូនអង្គសវនាការ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើឯកសារទាំងប្រាំបួននេះ វាឆ្លើយបតទៅនឹងលេខយោងចុងទំព័រ២៨៥ និង២៨៦ ដែរឬទេ? លេខយោង២៨៥ ទាក់ទងទៅនឹងឯកសារពីរ ហើយលេខយោង២៨៦ ទាក់ទងទៅនឹងឯកសារមួយទៀត ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺពិតជាដូច្នោះមែន ។

យើងហាក់ដូចជាឃើញថា វាមានការវ៉ែច្រឡំបន្តិចបន្តួចនៅក្នុងឧបសម្ព័ន្ធនោះ គឺនៅក្នុងឯកសារលេខ E551 ដែលបានផ្តល់បង្ហាញកាលបរិច្ឆេទនៅក្នុងលិខិតនោះ គឺថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ តាមពិតទៅគឺ ថ្ងៃ៣ នោះទេ ។ គឺខ្ញុំនិយាយនេះ គឺយោងជាក់លាក់ឯកសារលេខ៤១ ដែលបានប្រើប្រាស់សរសេរនៅចុងខាងស្តាំ-- ចុងខាងឆ្វេង ហើយថ្ងៃចុះនោះ គឺថ្ងៃ៤ តុលា ឆ្នាំ១៩៧៧ តែតាមពិតទៅគួរតែថ្ងៃ៣ ទៅវិញទេ ។

[១៥:៥៨:៣០]

ខ្ញុំសូមបន្ថែមថា គឺវានៅក្នុងលេខទំព័រ និងលេខឧបសម្ព័ន្ធដែលបានបញ្ជាក់យ៉ាងច្បាស់លាស់ ។ គឺវាជាលិខិតបី-បួន ដែលបានបញ្ជូនទៅ ឌុច ពី ស៊្វ ម៉េត ហើយវាជារបាយការណ៍ដែលមាននៅក្នុង--វាជាឯកសារដែលមាននៅក្នុងរបាយការណ៍ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាតរ៉ាយច៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍៖**

សូមអរគុណ ។ លិខិតនេះ គឺគួរតែចុះថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ គឺជាឯកសារដែលសរសេរយោងនៅក្នុងលេខជើងទំព័រ លេខចុងទំព័រ២៨៦ ឬក៏យ៉ាងម៉េច?

**លោក អាឡិចសាន់ឌឺ ប៉េត៖**

ប្រសិនបើអនុញ្ញាត គឺខ្ញុំនឹងធ្វើការត្រួតពិនិត្យមើលទៅលើបញ្ហានេះបន្តិច ។ បាទ,គឺត្រឹមត្រូវហើយ គឺលេខ២៨៦ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

ជាថ្មីម្តងទៀត ដើម្បីធ្វើការបំភ្លឺបន្ថែមទៅលើចំណុចហ្នឹង ឯកសារបីដែលមានយោងនៅក្នុងលេខយោង២៨៥ និង២៨៦ គឺរៀបរាប់អំពីទូរលេខ មិនមែនជាលិខិតទេ តើត្រឹមត្រូវដែរឬទេ?

**លោក អាឡិចសាន់ឌឺ ប៉េត៖**

គឺត្រឹមត្រូវ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

ជាទូទៅបញ្ហាចោទដែលខ្ញុំលើកឡើងចំពោះលោក អេតឆេសាន់ ប៉ុន្មានថ្ងៃមុននោះ នៅពេលដែលខ្ញុំសួរថា តើអ្នកដែលត្រូវបានគេចាប់ខ្លួននិងបញ្ជូនទៅ ស-២១ ពីអង្គភាពយោធា តើមានអមទៅជាមួយនឹងឯកសារដែលមានការបង្គាប់ផ្សេងៗ ហើយនិងស្តីអំពីបទល្មើស និងការប្រព្រឹត្តិខុសរបស់អ្នកទាំងអស់នោះដែរ ឬទេ? ថាតើនេះគឺភ្ជាប់ទៅនឹងឯកសារត្រឹមត្រូវដែរ ឬទេ?

[១៥:០០:៥៨]

**លោក អាឡិចសាន់ឌឺ ប៉េត៖**

គឺត្រឹមត្រូវ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធទៅនឹងការជំទាស់របស់មេធាវីការពារក្តី ដើម្បីឱ្យបានច្បាស់លាស់ហ្នឹង អង្គជំនុំជម្រះសូមប្រគល់ភារៈនេះទៅលោក ហ្សង់ម៉ាក ដើម្បីមានសំណួរឱ្យបានជាក់លាក់ លម្អិតច្បាស់លាស់អំពីការជំទាស់នេះ តើវាយ៉ាងដូចម្តេច?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ជាដំបូងចំណុចសំខាន់បំផុតនោះ គឺត្រូវនិយាយអំពីស្ថានភាពពិសេសមួយគឺថាយើងចាប់ផ្តើមធ្វើការសួរចម្លើយ សួរដាក់សំណួរទៅអ្នកជំនាញមុននឹងសួរទៅលើជនជាប់ចោទ ។ អ៊ីចឹង

នៅក្នុងដំណាក់កាលនីតិវិធីនេះ ហើយមិនទាន់មានការជំទាស់ទៅលើឯកសារ ការបង្ហាញជូនឯកសារនោះទេ ខ្ញុំយល់ថា នេះគឺជាពេលវេលាមួយសមរម្យដើម្បីធ្វើការសួរទៅលើជនជាប់ចោទ មុននឹងយើងសួរទៅលើលោកសាក្សីដែលជាអ្នកជំនាញនោះ ។ បើអ៊ីចឹងលោកប្រធានអាចពិភាក្សាទៅលើបញ្ហានេះបន្ថែមទៀតនៅពេលក្រោយ ក៏ប៉ុន្តែ អ្វីដែលជាការបញ្ជាក់នោះគឺថាឯកសារដែលជាឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នោះត្រូវបានចាត់ទុកថា ត្រូវបានដាក់នៅចំពោះមុខអង្គសវនាការរួចហើយ ។

ឯកសារទាំងហ្នឹងអាចត្រូវបានប្រើជាឯកសារគាំទ្រទៅលើរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ តើខាងមេធាវីការពារក្តីអាចប្រាប់យើងបានទេ ថាតើគេមានបំណងដូចម្តេច? នៅក្នុងពេលធ្វើការជំទាស់ទៅលើការសួរ ទៅលើ ឬក៏ទៅលើសំណួរដែលខាងសហព្រះរាជអាជ្ញាបានសួរទាក់ទងទៅនឹងឯកសារអស់ទាំងហ្នឹងដែលជាឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធរបស់របាយការណ៍ ។ បើពុំដូច្នោះទេ តើមានហេតុផលអ្វីដែលជាកត្តាអត្តនោម័តក្នុងការលើកឡើងនូវការជំទាស់ទៅលើការប្រើឯកសារដទៃទៀតដែលមានលក្ខណៈដូចគ្នានេះ?

ដើម្បីប្រើជាមូលដ្ឋាននៅក្នុងការសួរទៅលើអ្នកជំនាញ ឬក៏តើមានការមិនយល់ ឬក៏ការភ័ន្តច្រឡំគ្នា ឬទាក់ទងទៅនឹងចំណុចនេះ? ឬតើអ្វីទៅជាគោលបំណងពិតប្រាកដនៃសំណើរបស់លោកនោះ?

[១៥:០៣:៥០]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រម ។ មេធាវីការពារក្តីសូមធ្វើការបញ្ជាក់ចំណុចទាក់ទងទៅនឹងឯកសារដែលភ្ជាប់ជាឧបសម្ព័ន្ធទៅក្នុងរបាយការណ៍អ្នកជំនាញរបស់លោក ក្រេក អេតឆេសាន់ គឺថាយើងមិនមានការជំទាស់ទៅលើចំណុចនេះទេ ។ គឺមិនមានជំទាស់ គឺមិនជំទាស់ទៅលើការសួរសំណួរទាក់ទងទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធនោះទេ ពីព្រោះអីឯកសារទាំងហ្នឹងគឺជាផ្នែកមួយនៃរបាយការណ៍របស់គាត់។ ក៏ប៉ុន្តែទាក់ទងទៅនឹងឯកសារដទៃទៀត មេធាវីការពារក្តីបានថ្លែងថា "បញ្ហានោះគឺកើតចេញមកពីការពិតដែលថាលោក អេតឆេសាន់ បានដឹងអំពីឯកសារថ្មីអស់ទាំងនោះ គឺនៅពេលដែលគាត់កំពុងតែធ្វើការរួមគ្នាជាមួយនឹងក្រុមរបស់សហព្រះរាជអាជ្ញា ហើយជាមន្ត្រីម្នាក់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញានៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ខ្ញុំមិនមើលឃើញគាត់ ថាទុកគាត់ជាទីប្រឹក្សាសម្រាប់ការិយាល័យសហព្រះរាជអាជ្ញាទេ បើសិនជាគាត់ជាទីប្រឹក្សាសម្រាប់ការិយាល័យសហព្រះរាជអាជ្ញាវិញ ទាក់ទងទៅនឹងឯកសារអស់ទាំងហ្នឹង ហើយនៅពេលដែលយើងធ្វើការពិភាក្សាឯកសារអស់ទាំង

ហ្នឹង នៅពេលដំណាក់កាលស៊ើបអង្កេតនោះ ។

ខ្ញុំមិនគិតថាតើហេតុអ្វីបានជាឯកសារថ្មីអស់ទាំងហ្នឹង ថាតើអ្នកជំនាញនេះអាចបង្ហាញនូវភាពអនីកតិបានទេ? ពីព្រោះអីគាត់ គឺគាត់ធ្វើការចូលរួមដោយផ្ទាល់ក្នុងនាមជាសមាជិកម្នាក់របស់ការិយាល័យសហព្រះរាជអាជ្ញា ។ នេះគឺជាបញ្ហារបស់ខ្ញុំ ខ្ញុំអត់មានបញ្ហាអ្វីផ្សេងទៀតទេ នេះគឺជាបញ្ហាតែមួយគត់ ដែលខ្ញុំមាន ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីធ្វើឲ្យបានយល់ច្បាស់ជាងនេះទៅទៀតនោះ អ្វីដែលខ្ញុំយល់នោះ ប្រហែលជាខ្ញុំអាចភ័ន្តច្រឡំ ។ អ្វីដែលលោកប្រាប់នោះ គឺថានេះគឺជាចម្លើយទៅលើចំណុចទាក់ទងទៅនឹងអ្នកជំនាញនោះទេ? អ្វីដែលលោកចង់ប្រាប់មកពួកខ្ញុំនោះ គឺថាចម្លើយទៅលើសំណួរអស់ទាំងនោះ គឺជាសំណួរដែលគេបានសួរទៅលើអ្នកជំនាញនោះ គឺត្រូវធ្វើការវាយតម្លៃទៅតាមវិធីមួយផ្សេងទៀត ដោយហេតុថា តួនាទីរបស់គាត់ហ្នឹង និយាយអំពីតួនាទីរបស់គាត់ ពីព្រោះនៅពេលដែលឯកសារហ្នឹងឯង ត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ប៉ុន្តែ លោកបានជំទាស់ទៅនឹងអង្គហេតុដែលថា សំណួរហ្នឹង នឹងត្រូវបានគេសួរ ឬក៏លើកឡើងនោះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំមានបំណងចង់បាន បញ្ជាក់ឲ្យបានច្បាស់លាស់ថា បញ្ជាក់នូវភាពខុសគ្នាឲ្យបានច្បាស់លាស់អំពីឯកសារទាំងពីរនោះ ។ ដូច្នេះហើយ គឺខ្ញុំចង់ឲ្យមានបង្ហាញឲ្យមានភាពច្បាស់លាស់សម្រាប់គ្រប់ៗគ្នាដែលពាក់ព័ន្ធនៅក្នុងនីតិវិធីនេះ ។ ឯកសារដែលគាត់ទទួលបាននៅពេលក្រោយ ហើយដែលឯកសារហ្នឹង ត្រូវបានយកមកជាផ្នែកមួយសម្រាប់ជាការសួរ ឬក៏ដែលខាងអង្គសវនាការនឹងសួរទៅលើជនជាប់ចោទ ដោយមិនមានវត្តមានរបស់ជនជាអ្នកជំនាញនោះ ខ្ញុំយល់ថានេះ គឺជាដំណោះស្រាយមួយសមរម្យជាង ។ ក៏ប៉ុន្តែ ខ្ញុំអាចទទួលយកនូវការបង្ហាញឯកសារអស់ទាំងនោះ ប្រសិនបើខាងសហព្រះរាជអាជ្ញាធ្វើការសួរទៅលើលោក អេតឆេសាន់ ទាក់ទងទៅលើឯកសារមួយចំនួននេះ ដែលគាត់បានដឹងនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ ចម្លើយរបស់លោក អេតឆេសាន់ ទៅលើសំណួរអស់ទាំងនុ៎ង គឺថាមិនគួរឲ្យតម្លៃពេកនោះទេ ។

[១៦:០៨:៤៥]

ដូច្នេះមានន័យថា គឺថាបើសិនជាយើងមិនឲ្យតម្លៃពេកទៅលើចម្លើយរបស់គាត់ ចំពោះសំណួរ

អស់ទាំងហ្នឹង គឺថាយើងអាចទទួលយកបាន ។ មានន័យថា គឺដើម្បីឲ្យយើងដំណើរការទៅមុខបាន ។ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់អំពីតួនាទីរបស់មេធាវីការពារក្តី គឺថាយើងឯកភាពទៅឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនោះ ប៉ុន្តែ អ្វីដែលមេធាវីការពារក្តីចង់លើកឡើង គឺចង់លើកឡើងអំពីបញ្ហាដែលជាមូល-ដ្ឋានទាក់ទងដែលថា តើអ្វីទៅជាមូលដ្ឋាននៃការកាត់ក្តីដោយយុត្តិធម៌នោះ? គឺមេធាវីការពារក្តីឯកភាពយ៉ាងពេញលេញ សម្រាប់ឲ្យយើងធ្វើការនិយាយគ្នាអំពីឯកសារអស់ទាំងហ្នឹង ហើយនឹងអាចសួរទៅលើជនជាប់ចោទអំពីឯកសារអស់ទាំងនេះ ។ ហើយខ្ញុំចង់រំឭកផងដែរ ទាក់ទងទៅនឹងឯកសារថ្មីអស់ទាំងនេះ ជនជាប់ចោទត្រូវបានសួររួចហើយដោយខាងសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងសំណួរអស់ទាំងហ្នឹង ។ ដូច្នេះ គឺថាគាត់នៅក្នុងស្ថានភាពមួយ ដែលគាត់អាចឆ្លើយទៅនឹងសំណួរផ្សេងៗទៀតបាន ប៉ុន្តែ គឺសំណួរទាក់ទងទៅនឹងគោលការណ៍ទេដែលខ្ញុំចង់លើកឡើងនៅក្នុងពេលនេះ គឺទាក់ទងទៅនឹងតួនាទីបច្ចុប្បន្នរបស់លោក ក្រេក អេតឆេសាន់ ។ គឺថា យើងមានការគោរពយ៉ាងខ្ពង់ខ្ពស់បំផុតសម្រាប់កិច្ចការរបស់លោក ក្រេក អេតឆេសាន់ ដែលគាត់បានធ្វើអស់រយៈពេលជាច្រើនឆ្នាំ ។ យើងមានការគោរពយ៉ាងខ្ពង់ខ្ពស់សម្រាប់សមត្ថភាពរបស់គាត់ជាអ្នកជំនាញ ក៏ប៉ុន្តែ នៅពេលនេះនៅពេលដែលគាត់ចូលរួមដោយផ្ទាល់ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងការចោទប្រកាន់មកលើឌុច គឺពិបាកណាស់សម្រាប់ខ្ញុំ ។ បើសិនជាខ្ញុំមិនចង់និយាយថា អ្វីដែលគាត់និយាយហ្នឹង គឺជាកត្តាអត្តនោម័តិនោះ ។ ប៉ុន្តែ អ្វីៗ គឺវាអាស្រ័យទៅលើសេចក្តីសម្រេចរបស់លោកចៅក្រមតែប៉ុណ្ណោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ដើម្បីសង្ខេបឡើងវិញ ប្រសិនបើអង្គសវនាការកត់សម្គាល់ទៅលើការរក្សាសិទ្ធិរបស់លោក ទៅលើតម្លៃនៃចម្លើយរបស់លោក ក្រេក អេតឆេសាន់ ។ មានន័យថា យើងអាចចាត់ទុកថាលោកដកឡើងវិញនូវសេចក្តីជំទាស់ ដែលលោកបានធ្វើពីមុនមកឬ?

[១៦:១០:៥២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ, ពិតណាស់ ខ្ញុំបាននិយាយចំណុចនេះបានច្បាស់លាស់ណាស់ ។ ដូច្នេះគឺថាកុំឲ្យមានភ័ន្តច្រឡំគ្នាទៀត ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធាន! ខ្ញុំសូមឆ្លើយដោយខ្លីទៅលើចំណុចមួយចំនួន ដែលខ្ញុំមិនមានឱកាសក្នុងការឆ្លើយ

តបកាលពីពេលមុន ។ ទាក់ទងទៅនឹងសំណើរបស់មេធាវីការពារក្ដី ដែលថាភស្ដុតាងរបស់ អេត ឆេសាន់ គឺមានភាពចម្លុតាសាមញ្ញបំផុតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនោះ ។ ខ្ញុំចង់ធ្វើការកែសម្រួលទៅលើចំណុចនេះ ដោយដកស្រង់ពីយុត្តិសាស្ត្រ ដែលបានបង្កើតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺសហព្រះរាជអាជ្ញានឹងប្រឆាំងនឹង ប្រជីនិន*(Brdjanin)* ។ ការពិតដែលថាសាក្សី ភស្ដុតាងរបស់សាក្សី ដែលភាគីណាមួយយកមកបម្រើការនោះ គឺមិនមែនមានន័យថា យើងមិនអាចចាត់ទុកគាត់ជាសាក្សីជំនាញនៅក្នុងការផ្ដល់សក្ខីកម្មបានទេ ។ ចំណុចនេះក៏ទាក់ទងទៅនឹងវិធាន 90D នៃវិធាននីតិវិធីរបស់ អាយស៊ីធីវ៉ាយ ផងដែរ ដែលបញ្ជាក់យ៉ាងច្បាស់លាស់ឲ្យអ្នកស៊ើបអង្កេតទទួលបន្ទុកទៅលើការស៊ើបអង្កេតនោះ ធ្វើការផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីនៅក្នុងដំណើរការនីតិវិធីហើយបំពេញនូវចំណុចផ្សេងៗ ដែលថា សេចក្ដីបារម្ភផ្សេងៗដែលភាគីណាមួយបានលើកឡើងទាក់ទងទៅនឹងអនីគតិនៃសាក្សីជាអ្នកជំនាញ អាចនឹងត្រូវលើកឡើងដោយភាគីនោះនៅក្នុងសំណួររបស់ខ្លួន ហើយនិងនៅក្នុងសិទ្ធិដែលខ្លួន ឬក៏ភាគីមាននៅពេលដែលខ្លួនកោះហៅសាក្សីជំនាញដោយខ្លួនឯង ។ ហើយខ្ញុំបានដឹងថា មេធាវីការពារក្ដីបានកោះហៅអ្នកជំនាញ រ៉ូលចូណាល់ ទាក់ទងទៅនឹងបញ្ហាស្រដៀងគ្នានេះដែរ ហើយការយោងទៅលើចំណុចដែលបានលើកឡើងនេះ គឺតុលាការព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ្វ៉ាន់ដា ក្នុងការប្រឆាំងរបស់សហព្រះរាជអាជ្ញា ដែលខ្ញុំអាចឲ្យលេខយោងពេញលេញបាននៅពេលក្រោយបន្តិចទៀតនោះ ។ នេះគឺជាការអនុវត្តជាទម្លាប់នៅក្នុងតុលាការពិសេសដទៃៗទៀត នៅពេលដែលសាក្សីជាអ្នកជំនាញត្រូវបានបម្រើការនៅក្នុង ជាមួយភាគីណាមួយ គឺថាអាចផ្ដល់សក្ខីកម្ម និងបានធ្វើសក្ខីកម្មបាន ហើយក៏មានសិទ្ធិធ្វើសក្ខីកម្មបែបនេះដែរ ហើយភាគីផ្សេងៗគឺថាអាចមានសិទ្ធិសួរសំណួររបស់គាត់ សួរសំណួរទៅលើជននោះ ដោយសមស្រប ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

[១៦:១៤:00]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ដី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់ធ្វើការបញ្ជាក់បន្តិចថា តើបើសិនជាខ្ញុំយល់បានច្បាស់លាស់មានន័យថា នេះគឺអាស្រ័យទៅលើការដឹងអំពីឯកសារនោះមែនទេ បញ្ជាក់អំពីពេលវេលានៃការដឹងនោះ ។ ប្រសិនបើដូច្នេះមែននឹងអាចជាប្រយោជន៍ បើសិនជាយើងអាចសួរសាក្សីថា តើនៅពេលណា

ទៅដែលគាត់បានដឹងអំពីឯកសារអស់ទាំងនេះ? ដែលមិនមានការបញ្ចូលទៅក្នុងរបាយការណ៍ ហើយដែលវាមានភាពប្រហាក់គ្នា ឬមួយដែលគាត់ប្រហែលជាបានដឹងពីឯកសារអស់នុ៎ងរួចទៅហើយ នៅពេលដែលគាត់សរសេររបាយការណ៍របស់គាត់នោះ ឬនៅក្នុងអំឡុងពេលនៃការស្រាវជ្រាវរបស់គាត់មុនពេលដែលគាត់មកធ្វើការនៅជាមួយការិយាល័យសហព្រះរាជអាជ្ញានោះ ។ សូមអរគុណ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំនឹងឆ្លើយទៅលើសំណួររបស់ខាងសហព្រះរាជអាជ្ញា ហើយបន្ទាប់ទៀតនឹងឆ្លើយនូវសំណួររបស់មេធាវី ។

ប្រសិនបើលោក អេតឆេសាន់ បានដឹងឯកសារអស់ទាំងហ្នឹងមុនពេលដែលគាត់សរសេររបាយ-ការណ៍ ហើយប្រសិនបើគាត់មិនប្រើរបាយការណ៍ ឯកសារអស់ទាំងហ្នឹងទេ មានន័យថា ការគាំទ្រដែលខ្ញុំចង់និយាយហ្នឹង គឺថាគាត់ជឿថាឯកសារហ្នឹងមិនចាំបាច់ដើម្បីបញ្ចូលទៅក្នុងរបាយការណ៍របស់គាត់ទេ ។ ដូចនេះដែរ ខ្ញុំមើលទៅថាតើយើងនឹងជជែកគាត់អំពីអ្វីទេ បើសិនជាករណីបែបនេះកើតមាននោះ? យើងត្រូវផ្តោតអារម្មណ៍ទៅលើឯកសារ ដែលលោក ក្រេក អេតឆេសាន់ បានជ្រើសរើសបញ្ចូលទៅក្នុងរបាយការណ៍របស់គាត់ ហើយពិនិត្យមើលលើឯកសារអស់ទាំងនុ៎ង ។

ឥឡូវនេះ ខ្ញុំចង់ឆ្លើយទៅនឹងសំណួររបស់លោក អាឡិចសាន់ឌឺ ប៊ែត ។ ខ្ញុំក៏មានសកម្មភាពដែរនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា គឺជាការពិតណាស់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ខ្ញុំសូមទោស ដែលខ្ញុំនិយាយអំពីចំណុចនេះឡើងវិញគឺតុលាការព្រហ្មទណ្ឌអន្តរជាតិអាស្រ័យទៅលើប្រព័ន្ធខំមិនឡូ ប៉ុន្តែសហព្រះរាជអាជ្ញាជាទៀងទាត់បាននាំយកសាក្សីរបស់គាត់ គឺមានន័យថា បានយកអ្នកស៊ើបអង្កេតរបស់គាត់ជាសាក្សី គឺអ្នកដែលបានចុះតាមមូលដ្ឋាន បានធ្វើការស៊ើបអង្កេត ។ ហើយជាទូទៅនៅពេលចាប់ផ្តើមនៃសវនាការ អ្នកស៊ើបអង្កេតអស់ទាំងហ្នឹងឯង ត្រូវបានគេសួរសំណួរ ហើយនឹងត្រូវបានគេសួរសំណួរឆ្លងពីចៅក្រមផងដែរ ។ ក៏ប៉ុន្តែយើងមិនមែនស្ថិតនៅក្នុងប្រព័ន្ធសវនាការបែបនេះទេ ។

នៅក្នុងសវនាការដែលយើងមានកំពុងតែមានបច្ចុប្បន្ននេះ គឺយើងមិនមែនប្រឈមមុខនឹងការសួរទៅលើអ្នកស៊ើបអង្កេតទេ គឺថាគាត់ជាមនុស្សម្នាក់ដែលជាអ្នកជំនាញ ហើយដែលបានធ្វើការទៅលើបញ្ហាទាក់ទងទៅនឹងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ឯការិយាល័យសហព្រះរាជអាជ្ញាបានជ្រើសរើសអ្នកជំនាញនេះ ដែលគាត់មានភាពល្បីល្បាញនោះឲ្យមកធ្វើការនៅក្នុងការិយាល័យ

របស់សហព្រះរាជអាជ្ញា ។ ដូច្នេះ ក្នុងនាមសហសេវិកនោះ គឺគាត់នឹងផ្តល់អនុសាសន៍ដល់លោកអ្នក ដែលនេះជាវិធីសាស្ត្រធម្មតា ហើយនឹងផ្តល់ឱកាសឲ្យការិយាល័យសហព្រះរាជអាជ្ញាធ្វើការរួមគ្នាក្នុង រយៈពេលមួយឆ្នាំនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ។ នេះគឺជាបញ្ហាដែលខ្ញុំយល់ថាវាកើតមាន ។

អ៊ីចឹងប្រសិនបើយើងលើកបញ្ហានេះ អំពីចំណុចផ្សេងវិញ ខ្ញុំចង់ធ្វើការនិយាយលើកឡើង តែទៅ លើចំណុចដែលថា លោក អេតឆេសាន់ និងតំណែងរបស់គាត់ មុនពេលដំណាក់កាលនៃការស៊ើបអង្កេត មានន័យថារហូតដល់ខែកក្កដា ឆ្នាំ២០០៧នោះ តួនាទីនោះ ទោះបីជាគាត់ជាផ្នែកមួយរបស់ការិយាល័យ សហព្រះរាជអាជ្ញាក៏ដោយ ក៏គាត់មិនមានឥទ្ធិពលអ្វីទៅលើជំនាញរបស់គាត់ដែរ ប៉ុន្តែនៅខណៈនេះ នៅ ពេលដែលគាត់ចូលរួមនៅក្នុងការិយាល័យរបស់សហព្រះរាជអាជ្ញា ហើយគាត់ចូលរួមនៅក្នុងការចោទ ប្រកាន់នៅក្នុងករណីនេះ សូមកុំប្រាប់ខ្ញុំថា មិនមានការបារម្ភទាក់ទងទៅនឹងអំឡុងពេល ដែលគាត់ ធ្វើការនោះ ហើយគាត់ជាអ្នកជំនាញដែលមានអនីគតិនោះ ។ ខ្ញុំឯកភាពទៅនឹងអ្វីដែលលោកចៅក្រម ឡាវែន៍ បានលើកទាក់ទងទៅនឹងអំឡុងពេលនៃដំណាក់កាលស៊ើបអង្កេត ហើយខ្ញុំក៏បានព្រមព្រៀងផង ដែរថា យើងចាត់ទុកចម្លើយដែលបានផ្តល់ដោយលោក ក្រេក អេតឆេសាន់ ដោយមិនឲ្យតម្លៃខ្ពស់ពេក។ ប៉ុន្តែនេះ គឺមិនមែនមានន័យថា យើងវាយបង្អាប់ទៅលើគាត់នោះទេ ។ ប៉ុន្តែ គ្រាន់តែយើងត្រូវធ្វើការ ពិចារណាថា នៅក្នុងដំណាក់កាលស៊ើបអង្កេត គាត់គឺជាទីប្រឹក្សាឲ្យការិយាល័យសហព្រះរាជអាជ្ញា ហើយយើងត្រូវធ្វើការបង្ហាញអ្វីដែលថាជាដំណាក់កាលដំណើរការរបស់គាត់នោះ ។ គឺថាគាត់បានជួយ ការិយាល័យសហព្រះរាជអាជ្ញា ដើម្បីផ្តល់ការគាំទ្រដល់ការចោទប្រកាន់មកលើជនជាប់ចោទ ហើយខ្ញុំ អត់មានបញ្ហាទៅលើចំណុចនេះទេ ឲ្យតែធ្វើការបញ្ជាក់ឲ្យបានច្បាស់ ។ ហើយនៅទីនេះ គឺថាខ្ញុំបាន បញ្ជាក់យ៉ាងច្បាស់កាលពីសប្តាហ៍មុន ថាគាត់ជាផ្នែកមួយរបស់ការិយាល័យសហព្រះរាជអាជ្ញា កាល ពីសប្តាហ៍មុន ។ ដូច្នេះ គឺថាយើងមិនត្រូវលាក់មុខនៅពីក្រោយអង្គហេតុនេះទេ ។

[១៦:២០:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមានការកត់សម្គាល់បន្តិចដោយសារ ការជជែកថ្ងៃនេះ តាម ការយល់ឃើញរបស់ខ្ញុំបាទ ហាក់ដូចជាចំណាយពេលឥតប្រយោជន៍ច្រើន ។ ដោយហេតុថាកាលពីថ្ងៃ

ទី២១ ខែឧសភា ឆ្នាំ២០០៩ មានន័យថាសប្តាហ៍មុនេះ យើងបានជជែកគាត់រួចហើយអំពីបញ្ហានេះ រហូតលោកប្រធានធ្វើការប្រជុំនិងចេញសេចក្តីសម្រេចថែមទៀត ។ អ៊ីចឹង ការយល់ឃើញរបស់ខ្ញុំបាទ យល់ឃើញថា ការជជែកឡើងវិញ គឺនាំឲ្យខាតពេលវេលា តែចំណុចដែលសំខាន់មេធាវីការពារជំទាស់ មិនឲ្យខាងលោកព្រះរាជអាជ្ញាលើកឡើងលើឯកសារដែលលោកប្រធានសម្រេចហើយនេះឬយ៉ាងម៉េច?

អ៊ីចឹង ខ្ញុំបាទចង់ដឹងថាសេចក្តីសម្រេចពីមុនរួចហើយ ឬក៏វាមានសេចក្តីប្លែកទៅទៀត លើការបកប្រែជួនកាលខ្ញុំបាទស្តាប់មិនបានពេញលេញទេ តែការយល់ឃើញរបស់ខ្ញុំបាទ យល់ឃើញថា ការជជែកនេះ គឺជាការជជែកឡើងវិញដដែល ។ ជាការកត់សម្គាល់របស់ខ្ញុំបាទ គឺឃើញប៉ុណ្ណឹង ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:២៣:០៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកពេលរសៀលហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសផ្អាកសវនាការដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តទៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនទៅ ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃស្អែកវេលាម៉ោងប្រាំបួនព្រឹក ។ ហើយលោក ក្រេក អេតឆេសាន់ ដោយសារនីតិវិធីនៅបន្តទៀត អ៊ីចឹងអង្គជំនុំជម្រះសូមអញ្ជើញមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកជាបន្ត ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៤នាទី]*